សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# សន្តិកម្មតាមច្បាប់

ស្រាវជ្រាវចាប់ពីថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក.ម៉ុន អេងឡាយ**

**ក.ឈិត ស្រីលេន**

សាស្ត្រាចារ្យណែនាំ

លោកជំទាវ **ម៉ួយ ធីតា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ម៉ុន អេងឡាយ** និងនាងខ្ញុំឈ្មោះ **ឈិត ស្រីលែន** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រឆ្នាំទី៤ ក្រុម L4A11 ជំនាន់ទី២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ សូមគោរពការដឹងគុណយ៉ាងអនេកប្បការ ចំពោះអ្នកមានគុណទាំងទ្វេមាន **លោកឪពុក អ្នកម្ដាយ** ជាទីគោរពយ៉ាងខ្ពង់ខ្ពស់បំផុតរបស់កូនដែលលោកបានផ្ដល់កំណើត ក្ដីស្រលាញ់ ភាពកក់ក្ដៅ បង្រៀនកូនឲ្យចេះស្មោះត្រង់ ធ្វើអំពើល្អ ដើម្បីឲ្យកូនក្លាយជាកូនល្អ សិស្សល្អ និង ពលរដ្ឋគំរូក្នុងសង្គម រួមទាំងឲ្យកូនបានរស់រានមានជីវិតដោយស្រណុកសុខស្រួល អ្វីដែលដិតជាប់ក្នុងចិត្តជានិច្ចរបស់កូននោះ គឺ លោកទាំងពីរបានខិតខំទាំងថ្ងៃទាំងយប់ គ្មានពេលសម្រាកគ្រប់គ្រាន់ ដើម្បីបានប្រាក់កាសក្នុងការទំនុកបម្រុងសព្វគ្រប់បែបយ៉ាង ក្នុងគោលបំណងតែម៉្យាងគត់គឺឲ្យកូនបានក្រេបជញ្ជក់នូវចំណេះដឹង ដើម្បីជាស្ពានបំភ្លឺផ្លូវនាពេលអនាគត ។

សូមគោរពថ្លែងអំណរគុណដល់ **ឯកឧត្តមបណ្ឌិត សាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងគណៈគ្រប់គ្រង ព្រមទាំងសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានយកចិត្តទុកដាក់បង្ហាត់បង្រៀន និងផ្ដល់ចំណេះដឹងដល់ពួកយើងជានិស្សិតទាំងអស់គ្នា ព្រមទាំងរិះរកគ្រប់វិធីសាស្ត្របង្រៀនដើម្បីឲ្យសិស្សបានឆាប់ចាប់លើចំណុចនីមួយៗ ងាយចងចាំ ទទួលបានពុទ្ធិផ្នែកច្បាប់ សម្រាប់ឲ្យសិស្សនិស្សិតទាំងអស់បានអភិវឌ្ឍខ្លួនក្លាយជាបញ្ញាវ័ន្តមួយរូបក្នុងសង្គមជាតិ។

ជាពិសេសសូមគោរពថ្លែងអំណរអរគុណ លោកជំទាវ សាស្ត្រាចារ្យ **ម៉ីយ ធីតា** ដែលជាព្រឹទ្ធបុរសរងមហាវិទ្យាល័យនីតិសាស្ត្រ និងជាទីប្រឹក្សាអមក្រសួងយុត្តិធម៌ លើសពីនោះ លោកជំទាវជាសាស្ត្រាចារ្យណែនាំលើប្រធានបទសារណារបស់នាងខ្ញុំទាំងពីរ ដោយលោកជំទាវបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញ ណែនាំ កែសម្រួល ក្នុងការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះតាំងពីចាប់ផ្ដើមរហូតដល់សម្រេចជាលទ្ធផល។

ជាចុងក្រោយ យើងខ្ញុំទាំងពីរសូមគោរពការដឹងគុណ និងសូមលើកម្រាមដៃបួងសួងដល់ព្រះរតនត្រ័យសូមលោកជួយមើលថែរក្សា លោកឪពុក អ្នកម្ដាយ ឯកឧត្តមបណ្ឌិត សាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ បុគ្គលិកទាំងអស់ជួបប្រទះតែភាពសុខសប្បាយ មានសុខភាពល្អ និងជួបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្នុងរយៈពេលបួនឆ្នាំ នៃការសិក្សាមុខជំនាញបរិញ្ញាបត្រនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចកន្លងមកនេះ នាងខ្ញុំទាំងពីរបានខិតខំប្រឹងប្រែងក្រេបជញ្ជក់នូវពុទ្ធិផ្នែកនីតិសាស្ត្រដើម្បីសម្រេចបំណងដែលប៉ងប្រាថ្នាក្នុងការទទួលបានសិទ្ធិដោយស្វ័យប្រវត្តិក្នុងការតាក់តែងសារណាបញ្ចប់ការសិក្សា ដើម្បីទទួលបានបទពិសោធន៍ជាច្រើនទៀតក្នុងការបំភ្លឺផ្លូវឈានទៅរកវិស័យមុខជំនាញដែលជាក្តីស្រមៃរបស់នាងខ្ញុំទាំងពីរនាក់នាពេលអនាគត។

បន្ទាប់ពីឆ្លងកាត់ការសិក្សាថ្នាក់បរិញ្ញាបត្រច្បាប់មក នាងខ្ញុំទាំងពីរមានចំណូលចិត្តទោរទៅរកផ្នែកនីតិគ្រួសារដែលនឹងជាកត្តាឲ្យយើងទាំងពីរបានជ្រើសរើសយកប្រធានបទស្តីពី **សន្តតិកម្មតាមច្បាប់** មកធ្វើការសិក្សាស្រាវជ្រាវ ក្នុងគោលបំណងទុកជាស្នាដៃបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ រួមទាំងបន្សល់ទុកឯកសារសម្រាប់ប្អូនៗនិស្សិតជំនាន់ក្រោយៗបានស្វែងយល់បន្ថែម។

នៅក្នុងសង្គមយើងនាពេលបច្ចុប្បនេះ នៅក្នុងគ្រួសារនីមួយៗអាចកើតមានទំនាស់អំពីការបែងចែកទ្រព្យសម្បត្តិរបស់បុគ្គលដែលបានស្លាប់ទៅ បើមតកជនមិនបានបន្សល់ទុកនូវលិខិតបណ្តាំនោះទេ។ ហេតុនេះទើបប្រទេសកម្ពុជាយើងបានចងក្រងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ឡើង ដើម្បីជួយសម្រួលនិងកាត់បន្ថយវិវាទទ្រព្យសម្បត្តិរវាងសមាជិកគ្រួសារ ដែលក្នុងនោះ គន្ថីទី៨ បានបញ្ញត្តិយ៉ាងច្បាស់អំពីផ្នែកសន្តតិកម្មតាមច្បាប់។

ជាចុងក្រោយនាងខ្ញុំទាំងពីរសង្ឃឹមយ៉ាងខ្លាំងថា ចំពោះសមិទ្ធផលនេះផងដែរនឹងអាចចែករំលែកក្នុងការបង្កើនចំណេះដឹងដល់អ្នកគ្រប់រូបដែលមានចំណាប់អារម្មណ៍លើផ្នែកសន្តតិកម្មតាមច្បាប់នេះដូចជារូបយើងទាំងពីរ។ ទោះជាយ៉ាងណាក៏ដោយ យើងទាំងពីរទទួលស្គាល់ថា វាមិនអាចចាត់ទុកជាស្នាដៃមួយដែលល្អឥតខ្ចោះនោះទេ រូបនាងខ្ញុំទាំងពីររីករាយនឹងមតិរិះគន់ពីសំណាក់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្សនិស្សិត និងអ្នកស្រាវជ្រាវទាំងអស់ លើកំហុសឆ្គងអក្ខរាវិរុទ្ធ ឬ ចំណុចណាដែលខ្វះខាតនូវអត្ថន័យដែលកើតមានដោយមានបំណងឬអចេតនាក្តីក្នុងន័យដើម្បីបំពេញចំណុចខ្វះចន្លោះអត្ថបទនេះនិងបំពេញបន្ថែមឲ្យអត្ថបទមួយនេះកាន់តែមានអត្ថន័យប្រសើរឡើងនេះទៅទៀត។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ..................................................... ១

## ជំពូកទី១
## សញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់

**១.១ បទដ្ឋានគតិយុត្តពាក់ព័ន្ធ** ..................................................... ៣

១.១.១ រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ..................................................... ៣

១.១.២ ច្បាប់ភូមិបាល ឆ្នាំ ២០០១ ..................................................... ៣

១.១.៣ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ..................................................... ៤

**១.២ ការកំណត់អំពីខ្លឹមសារនៃសន្តតិកម្មតាមច្បាប់** ..................................................... ៤

១.២.១ និយមន័យនៃសន្តតិកម្មតាមច្បាប់ ..................................................... ៥

១.២.២ ចរិតលក្ខណៈនៃសន្តតិកម្មតាមច្បាប់ ..................................................... ៥

**១.៣ លក្ខណៈសម្បត្តិនៃការទទួលបានសិទ្ធិនិងផ្តាច់សិទ្ធិជាសន្តតិជន** ..................................................... ៥

១.៣.១ គុណសម្បត្តិនៃការទទួលបានសិទ្ធិជាសន្តតិជន ..................................................... ៦

១.៣.១.១ ស្ថានភាពជាទារកក្នុងគភ៌ ..................................................... ៦

១.៣.១.២ រូបវន្តបុគ្គល ..................................................... ៦

១.៣.២ លក្ខខណ្ឌនៃការផ្តាច់សិទ្ធិជាសន្តតិជន ..................................................... ៧

១.៣.២.១ ករណីអភ័ព្វបុគ្គល ..................................................... ៧

១.៣.២.២ ជនដែលបានផ្តាច់ពីមត៌ក ..................................................... ៨

**១.៤ អានុភាពនៃសន្តតិកម្ម** ..................................................... ៨

១.៤.១ ការចាប់ផ្តើមនៃសន្តតិកម្ម ..................................................... ៨

១.៤.២ ពេលវេលាបើកសន្តតិកម្ម ..................................................... ៩

១.៤.២.១ មរណភាពនៃបុគ្គល ..................................................... ៩

១.៤.២.២ ករណីបាត់ខ្លួន ..................................................... ៩

១.៤.២.៣ ទីកន្លែងបើកសន្តតិកម្ម ..................................................... ១០

## ជំពូកទី២
## ការបែងចែកមត៌កនៃសន្តតិកម្មតាមច្បាប់

**២.១. លំដាប់នៃសន្តតិជន** ..................................................... ១២

២.១.១. សន្តតិជនលំដាប់ទី១ ..................................................... ១៣

២.១.២. សន្តតិជនលំដាប់ទី២ ..................................................... ១៣

២.១.៣. សន្តតិជនលំដាប់ទី៣ ........ ១៤
២.១.៤. សន្តតិជនជំនួស ........ ១៤
២.១.៥. សន្តតិជនជានិច្ច ........ ១៥
**២.២.ការកំណត់ចំណែកមត៌កតាមលំដាប់សន្តតិជន** ........ ១៦
២.២.១.ករណីមានសន្តតិជនប៉ុន្តែគ្មានសហព័ទ្ធ ........ ១៦
២.២.១.១. សន្តតិជនលំដាប់ទី១( បច្ឆាញាតិ) ........ ១៦
២.២.១.២. សន្តតិជនលំដាប់ទី២ ........ ១៧
២.២.១.៣. សន្តតិជនលំដាប់ទី៣ ........ ១៨
២.២.២.ករណីមានសន្តតិជនជានិច្ច(មានសន្តតិជននិងមានសហព័ទ្ធ) ........ ១៩
២.២.២.១. ករណីមានតែសន្តតិជនជានិច្ច ........ ១៩
២.២.២.២. សន្តតិជនជានិច្ចនិងសន្តតិជនលំដាប់ទី១ ........ ២០
២.២.២.៣. សហព័ទ្ធនិងសន្តតិជនលំដាប់ទី២ ........ ២០
២.២.២.៤. សហព័ទ្ធនិងសន្តតិជនលំដាប់ទី៣ ........ ២០
**២.៣ ភាពសម្រួលចំណែកមត៌កនៃសន្តតិកម្មតាមច្បាប់** ........ ២២
២.៣.១ ផលប្រយោជន៍ពិសេស ........ ២២
២.៣.១.១ ផលប្រយោជន៍ពិសេសមានតម្លៃតិចជាងចំណែកមត៌ក ........ ២២
២.៣.១.២ ផលប្រយោជន៍ពិសេសមានតម្លៃស្មើនឹងចំណែកមត៌ក ........ ២៣
២.៣.១.៣ ផលប្រយោជន៍ពិសេសមានតម្លៃលើសពីចំណែកមត៌ក ........ ២៤
២.៣.២ ករណីមានប្រទានកម្ម ........ ២៥
២.៣.២ ករណីវិភាគទាន ........ ២៦
**២.៤ ភាគបម្រុង** ........ ២៧
២.៤.១ សញ្ញាណទូទៅនៃភាគបម្រុង ........ ២៧
២.៤.១.១.អ្នកដែលមានសិទ្ធិលើភាគបម្រុង ........ ២៧
១.៤.១.២ ការកំណត់អំពីចំណែកនៃភាគបម្រុង ........ ២៨
២.៤.២ វិធីកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ........ ២៨
២.៤.២.១ ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង ........ ២៩
២.៤.២.២ លំដាប់នៃការកាត់បន្ថយ ........ ៣១
២.៤.៣ ការរំលត់សិទ្ធទាមទារឲ្យកាត់បន្ថយ ........ ៣៤
២.៤.៣.១ ការបោះបង់ចោលភាគបម្រុង ........ ៣៤
២.៤.៣.២ ករណីជាសហសន្តតិជន ........ ៣៥

## ជំពូកទី៣
## ការជម្រះបញ្ជីសន្តតិកម្មតាមច្បាប់

**៣.១ ការយល់ព្រមទទួលយកនិងការបោះបង់ចោលសន្តតិកម្ម** ....................................៣៦
៣.១.១ ការយល់ព្រមទទួលយកសន្តតិកម្ម ....................................៣៦
៣.១.១.១ ទាំងស្រុង....................................៣៧
៣.១.១.២ មានកម្រិត ....................................៣៧
៣.១.២ ការបោះបង់នូវសន្តតិកម្ម ....................................៣៨
**៣.២ របបនៃការគ្រប់គ្រង និង នីតិវិធីនៃការបែងចែកសន្តតិកម្មតាមច្បាប់**....................................៣៨
៣.២.១ ការគ្រប់គ្រងមត៌ក....................................៣៨
៣.២.២ ការបែងចែកមត៌ក....................................៣៩
៣.២.២.១ តាមការពិភាក្សារួមគ្នា....................................៣៩
៣.២.២.២ តាមតុលាការ ....................................៤០
៣.២.៣ អានុភាពនិងការធានាលើការទទួលខុសត្រូវ....................................៤០
៣.២.៣.១ អានុភាពនៃសន្តតិកម្ម ....................................៤០
៣.២.៣.២ ការធានាលើទំនួលខុសត្រូវ ....................................៤១
៣.២.៤ ការសម្រួលរវាងម្ចាស់បំណុល....................................៤១
**៣.៣ អំពីស្ថានភាពពិសេសនៃសន្តតិកម្មតាមច្បាប់** ....................................៤៣
៣.៣.១ អំពីនត្តិភាពនៃសន្តតិជន....................................៤៣
៣.៣.១.១ នីតិបុគ្គលមត៌ក....................................៤៣
៣.៣.១.២ មត៌កក្លាយជារបស់រដ្ឋ....................................៤៤
៣.៣.១.៣ ជនដែលមាននិស្ស័យពិសេស....................................៤៤
៣.៣.២ អំពីបដិទាននៃសន្តតិកម្ម....................................៤៤
**៣.៤ ការអនុវត្តជាក់ស្តែងនៃការបែងចែកមត៌ក**....................................៤៦
**សេចក្តីសន្និដ្ឋាន**....................................៤៩
**អនុសាសន៍**....................................៥១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

នៅក្នុងសកលលោកយើងពីសម័យកាលមួយទៅសម័យកាលមួយ ការបែងចែកទ្រព្យសម្បត្តិគឺមានតាំងពីយូរយង់ណាស់មកហើយ ដោយសង្កេតឃើញថា គ្រួសារនីមួយៗតែងតែមានបន្សល់ទុកទ្រព្យសម្បត្តិសម្រាប់ឲ្យសមាជិកគ្រួសារដែលជាសាច់ញាតិ បងប្អូន កូន ក្មួយ ទទួលស្នងបន្ត ។ ប៉ុន្តែការបែងចែកទ្រព្យសម្បត្តិនេះគឺស្ថិតនៅក្នុងស្ថានភាពស្មុគស្មាញនៅឡើយ ។

ដោយឡែក យើងក្រឡេកមកមើលតថភាពប្រទេសកម្ពុជាយើងនាពេលបច្ចុប្បន្ន ក្រោយពីទទួលបានសន្តិភាពពេញលេញ ប្រទេសកម្ពុជាមានការរីកចម្រើនលើគ្រប់វិស័យ នៅក្នុងនោះផងដែរ កម្ពុជាបានចងក្រងច្បាប់ និងបទដ្ឋានគតិយុត្តជាច្រើន ដោយគោរពតាមច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជាដែលមានចែងក្នុងគោលបំណង ការពារសន្តិសុខសណ្តាប់ធ្នាប់សង្គមសាធារណៈ និងការពារផលប្រយោជន៍ឯកជន។ ជាក់ស្តែងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ គន្ថីទី៧ បានចែងអំពី ទ្រព្យសម្បត្តិ ទំនាក់ទំនងញាតិលោហិត ដើម្បីធ្វើឲ្យសិទ្ធិនិងកាតព្វកិច្ចរបស់បុគ្គលម្នាក់ៗមានតម្លាភាព និង យុត្តិធម៌និងស្របតាមច្បាប់។ ចំពោះទំនាក់ទំនងសិទ្ធិនិងទ្រព្យរបស់មនុស្សកំពុងនៅរស់រានមានជីវិត និង បុគ្គលដែលបានមរណភាពទៅហើយ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាក៏បានបញ្ញត្តិផងដែរព្រោះថានៅពេលដែលបុគ្គលដែលបាត់បង់នូវបុគ្គលភាពគតិយុត្ត មិនអាចយកនូវសិទ្ធិនិងទ្រព្យសម្បត្តិទៅតាមខ្លួនបានទេ ។ ប៉ុន្តែគ្រាន់តែការផ្ទេរមត៌កនេះស្ថិតក្រោមរូបភាពផ្សេងគ្នាបើ បុគ្គលនៅរស់ បានធ្វើការផ្លាស់ប្តូរ ឬផ្ទេរទ្រព្យសម្បត្តិ ឲ្យទៅបុគ្គលនៅរស់ ដូចជា ការលក់ ការដូរ ប្រទានកម្មឬអំណោយ ផ្ទុយទៅវិញ ការផ្ទេរមត៌ករបស់អ្នកស្លាប់ មកឲ្យអ្នកមានជីវិត ត្រូវធ្វើក្រោមរូបភាពជា សន្តតិកម្ម។

របបសន្តតិកម្ម ត្រូវបានបែងចែកជា ២ ប្រភេទ គឺ គោលការណ៍ទទួលយកបន្តដោយស្វ័យប្រវត្តិ និង គោលការណ៍ជម្រះបញ្ជី។[1] គោលការណ៍ទទួលយកបន្តដោយស្វ័យប្រវត្តិ គឺជាគោលការណ៍ដែលសន្តតិជនត្រូវទទួលយកទាំងស្រុងនូវសិទ្ធិនិងករណីកិច្ចទាំងអស់របស់មតកជន។ ដូច្នេះ សន្តតិជនបានទទួលបន្តនូវឋានៈរបស់មតកជនតែម្តង។ ក្នុងករណីដែលមតកជននោះបានបន្សល់ទុកកាតព្វកិច្ចច្រើនពេក(ទ្រព្យអកម្ម) ប្រសិនបើសន្តតិជនទទួលនូវកាតព្វកិច្ចទាំងនោះ នឹងធ្វើឲ្យខូចខាតប្រយោជន៍យ៉ាងធ្ងន់ធ្ងរដោយសារសន្តតិកម្ម ។ ដូច្នេះហើយបានជាយើងបង្កើតឲ្យមានរបបបោះបង់សន្តតិកម្ម ឬការយល់ព្រមដោយមានកម្រិត ដើម្បីជៀសវាងនូវស្ថានភាពនេះ ។ នោះគឺគោលការណ៍ជម្រះបញ្ជី គឺតម្រូវឲ្យជម្រះនូវសិទ្ធិនិងកាតព្វកិច្ចជាមុនសិន ហើយសន្តតិជនអាចតែទទួលមត៌កតែក្នុងករណី ដែលសល់តែទ្រព្យសកម្មតែប៉ុណ្ណោះ ហើយករណីនៅសល់ទ្រព្យអកម្មច្រើនពេកនោះតម្រូវឲ្យប្រកាសក្ស័យធននៃមត៌ក។ ដោយហេតុថានីតិវិធីនេះមានលក្ខណៈស្មុគស្មាញ

[1] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី,គន្ថីទី៨ ទី៩,ទំព័រ ១

អស់សោហ៊ុយ និងចំណាយពេលវេលាច្រើន ទើបក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា បាន បញ្ញត្តិយកគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ ដោយមានការអនុញ្ញាតឲ្យសន្តតិជនមានសិទ្ធិជ្រើសរើស ទទួលយកទាំងស្រុង ឬ ទទួលយកដោយមានកម្រិត ឬ ក៏អាចមានសិទ្ធិសម្រេចចិត្តលះបង់សន្តតិកម្មរបស់ខ្លួន តែម្តងក៏បាន។

នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិយ៉ាងលំអិតអំពីទំនាក់ទំនង ញាតិ ខ្សែស្រឡាយ របស់មតកជន និង កូនចៅជំនាន់ក្រោយពីលំដាប់នៃការទទួលមត៌ក រួមទាំងមានចែងពីអ្នក ដែលត្រូវទទួលជំនួសផងដែរ ។ សន្តតិកម្មបានបែងចែកជា ២ប្រភេទ ផ្សេងគ្នា គឺ ទីមួយ សន្តតិកម្មតាមច្បាប់ និងទីពីរគឺ សន្តតិកម្មតាមមតកសាសន៍។ សន្តតិកម្មតាមមតកសាសន៍គឺជាសន្តតិកម្មដែលធ្វើឡើងដោយផ្អែក ទៅតាមឆន្ទៈរបស់មតកជន(សន្តតិកម្មមានបណ្តាំ)។ ចំណែកសន្តតិកម្មតាមច្បាប់គឺជាសន្តតិកម្មដែលបង្កើត ឡើងផ្អែកតាមបញ្ញត្តិច្បាប់។[2]

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានអនុម័តតាំងពីថ្ងៃទី០៨ ខែធ្នូ ២០០៧ និងបានដាក់ឲ្យអនុ វត្តនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១១ ហើយថែមទាំងមានការផ្សព្វផ្សាយពីសំណាក់អ្នកច្បាប់ហើយក្តី ប៉ុន្តែការយល់ ដឹងរបស់ប្រជាពលរដ្ឋទូទៅនៅមានកម្រិតស្តួចស្តើងនៅឡើយ ។ ជាពិសេស ពួកយើងជានិស្សិតសិក្សាជំនាញ នីតិសាស្ត្របានយល់ឃើញថា សន្តតិកម្មនេះពិតមានសារៈសំខាន់នៅក្នុងជីវភាពប្រចាំថ្ងៃ ដែលត្រូវតែមានស្វែង យល់បន្ថែម។ នៅក្នុងសន្តតិកម្មនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបែងចែកសន្តតិកម្មពីរប្រភេទគឺសន្តតិកម្ម មតកសាសន៍ដោយយកគោលការណ៍គោរពតាមឆន្ទៈរបស់មតកជន និងសន្តតិកម្មតាមច្បាប់ដោយគោរពតាម បញ្ញត្តិច្បាប់បើអវត្តមានលិខិតបណ្តាំរបស់មតកជននោះ។ ការសិក្សាស្រាវជ្រាវនិងចងក្រងអត្ថបទនេះពួកយើង នឹងលើកឡើងតែផ្អែកសន្តតិកម្មតាមច្បាប់តែប៉ុណ្ណោះ។

ដើម្បីពន្យល់អំពីប្រធានបទ សន្តតិកម្មតាមច្បាប់ នឹងខ្លឹមសារនានាដែលបានចែងក្នុងក្រមនេះឲ្យបាន ល្អិតល្អន់ ស៊ីជម្រៅ និងកាន់តែជាក់ច្បាស់ យើងនឹងធ្វើការបែងចែកអត្ថបទនេះជា ៣ជំពូក ដូចខាងក្រោម៖

**ជំពូកទី១ សញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់**

**ជំពូកទី២ ការបែងចែកមត៌កនៃសន្តតិកម្មតាមច្បាប់**

**ជំពូកទី៣ ការជម្រះបញ្ជីសន្តតិកម្មតាមច្បាប់**

[2] មាត្រា ១១៤៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

# ជំពូកទី១

# សញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់

ដើម្បីធ្វើការសិក្សាលើសន្តតិកម្មតាមច្បាប់ យើងនឹងបកស្រាយពី អត្ថន័យ និងចរិតលក្ខណៈ រួមទាំង អត្ថិភាពនិងនត្ថិភាពនៃសន្តតិជនដែលមានសិទ្ធិក្នុងការស្នងមត៌ក ព្រមទាំងអានុភាពនៃសន្តតិកម្មតាមច្បាប់។ ក្នុងចំណុចនេះយើងនឹងបែងចែក ដូចជា ចំណុច ១.១ បកស្រាយពី “ បទដ្ឋានគតិយុត្តពាក់ព័ន្ធ ” ចំណុច ១.២ បកស្រាយ“ ការកំណត់អំពីខ្លឹមសារនៃសន្តតិកម្មតាមច្បាប់” ចំណុច ១.៣ បកស្រាយ “ លក្ខណៈសម្បត្តិនៃការទទួលបានសិទ្ធិនិងផ្តាច់សិទ្ធិជាសន្តតិជន ” និងចំណុចចុងបញ្ចប់ក្នុងជំពូកទី១ ១.៤ បកស្រាយអំពី “ អានុភាពនៃសន្តតិកម្ម ”។

## ១.១ បទដ្ឋានគតិយុត្តពាក់ព័ន្ធ

ជាទូទៅ គ្រប់បទដ្ឋានគតិយុត្តនិងច្បាប់នានាដែលបានអនុម័តមកសុទ្ធតែមានកម្មវត្ថុបំណងទៅតាមវិស័យនីមួយៗនៃច្បាប់ឬវិធាននោះ។ ចំពោះសន្តតិកម្មតាមច្បាប់នេះវិញ តាមរយៈការសង្កេតទៅឃើញថា បទដ្ឋានដែលចែងពាក់ព័ន្ធមាន ១.២.១ “ រដ្ឋធម្មនុញ្ញ១៩៩៣ ”,១.២.២ “ ច្បាប់ភូមិបាល ២០០១ ” ,១.២.៣ “ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ”។

### ១.១.១ រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣

គ្រប់ច្បាប់បទប្បញ្ញត្តិទាំងអស់បានតាក់តែងមកគឺត្រូវអនុលោមតាមច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា នោះគឺ រដ្ឋធម្មនុញ្ញ បើពុំនោះទៀតសោត ច្បាប់និងបទដ្ឋានគតិយុត្តនឹងអធម្មនុញ្ញភាព។

រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ នៅជំពូកទី៣ បានចែងអំពីការទទួលស្គាល់និងគោរពសិទ្ធិមនុស្សតាមរយៈការផ្តល់សិទ្ធិសេរីភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាពនិងករណីកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌ សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ឬស្ថានភាពឯទៀតឡើយ។[3] រដ្ឋធម្មនុញ្ញ ១៩៩៣ ក៏មានការទទួលស្គាល់លើសិទ្ធិលើដីធ្លី តាមរយៈជនណាក៏ដោយ ទោះបីជាបុគ្គលក្តី ជាសមូហភាពក្តីមានសិទ្ធិជាម្ចាស់កម្មសិទ្ធិ គឺមានតែរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមានសញ្ជាតិខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។[4]

### ១.១.២ ច្បាប់ភូមិបាល ឆ្នាំ ២០០១

ក្នុងនោះផងដែរ មានច្បាប់មួយទៀតក្រៅពីច្បាប់កំពូលនៃព្រះរាជាណាក្រកម្ពុជានោះគឺមានច្បាប់ភូមិបាល ២០០១ ដែលចែងអំពី កម្មសិទ្ធិឯកជនស្របច្បាប់លើដីធ្លី ។

[3] មាត្រា ៣១ , កថាខណ្ឌទី២ នៃធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

[4] មាត្រា ៤៤ ,កថាខណ្ឌទី១ នៃធម្មនុញ្ញព្រះរាជាចក្រកម្ពុជា ឆ្នាំ១៩៩៣

ច្បាប់នេះបានបង្កើតឡើងក្នុងគោលបំណងកំណត់អំពីរបបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងធានាការពារសិទ្ធិនិងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុស្របតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣នៃព្រះរាជាណាកច្រកម្ពុជា ។[5] ជាមួយគ្នានេះផងដែរ ច្បាប់នេះក៏បានផ្តល់សិទ្ធិដល់ជនគ្រប់រូបត្រូវតែគោរពទ្រព្យសម្បត្តិរដ្ឋនិងកម្មសិទ្ធិឯកជនស្របច្បាប់លើអចលនវត្ថុ។ ហើយអ្នកដែលមានសិទ្ធិលើកម្មសិទ្ធិដីធ្លីនៃព្រះរាជាណាចក្រកម្ពុជា គឺមានតែរូបវន្តបុគ្គលសញ្ជាតិខ្មែរតែប៉ុណ្ណោះ។[6]

### ១.១.៣ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

បុគ្គលម្នាក់ៗសុទ្ធតែមានសិទ្ធិឯកជនស្មើៗគ្នា ដែលត្រូវបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ១៩៩៣ និងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ បានបង្កើតឡើងនូវគោលការណ៍នៃការបង្កើត ការផ្ទេរ និងការកែប្រែនូវសិទ្ធិប្រត្យក្សដែលជាសិទ្ធិគ្រប់គ្រងលើវត្ថុដោយចំពោះ នឹងអាចមានការអះអាងចំពោះបុគ្គលដទៃទៀតបាន ។ នៅត្រង់ចំណុចនេះមានន័យថា ជាការផ្ទេរទ្រព្យសម្បត្តិពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត ដោយរួមទាំងការផ្ទេរទ្រព្យសម្បត្តិពីបុគ្គលដែលស្លាប់ទៅបុគ្គលដែលមានជីវិត ព្រោះនៅពេលបុគ្គលណាម្នាក់ស្លាប់ប្រាកដណាស់ថា បុគ្គលនោះនឹងបន្សល់នៅទ្រព្យសម្បត្តិ ត្រូវតែមានញាតិជាអ្នកស្នងបន្ត ។ ហេតុនេះហើយបាន ក្នុងគន្ថីទី៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានបញ្ញត្តិអំពី “សន្តតិកម្ម” ក្នុងការការពារឆន្ទៈបុគ្គលដែលបានមរណភាព និងបុគ្គលដែលមានសិទ្ធិទទួលបានឬស្នងបន្តនូវចំណែកមត៌ក។

នៅក្នុងគន្ថីទី៨ នៃក្រមដដែលនេះ ពិតជាដើរតួចម្បងក្នុងការកំណត់សន្តតិជនតាមច្បាប់ដើម្បីការពារផលប្រយោជណ៍របស់បុគ្គលទាំងឡាយដេលជាញាតិស្របតាមច្បាប់របស់មតកជន ក្រៅពីការបែងចែកមត៌កតាមរយៈឆន្ទៈរបស់មតជន( មតកសាសន៍)។

## ១.២ ការកំណត់អំពីខ្លឹមសារនៃសន្តតិកម្មតាមច្បាប់

ក្នុងចំណុច ១.២ នេះ នឹងសិក្សាឲ្យកាន់តែស៊ីជម្រៅលើ ១.២.១ “ និយមន័យនៃសន្តតិកម្មតាមច្បាប់ ” និង ១.២.២ “ ចរិតលក្ខណៈនៃសន្តតិកម្មតាមច្បាប់ ”។

### ១.២.១ និយមន័យនៃសន្តតិកម្មតាមច្បាប់

អត្ថន័យនៃពាក្យ “សន្តតិកម្ម” យោងតាមក្រមរដ្ឋប្បវេណី មានន័យថា ការផ្ទេរនូវសិទ្ធិនិងករណីកិច្ចរបស់មត៌កជនទៅឲ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈឬតាមច្បាប់។[7] “មតកជន” ត្រូវបានឲ្យនិយមន័យថាជន ឬ បុគ្គលបានដែលបានទទួលមរណភាពឬបានស្លាប់ទៅហើយ។[8] រីឯ ជនដែលបានទទួលនូវសិទ្ធិនិង

---

[5] មាត្រា១ នៃច្បាប់ភូមិបាល ២០០១

[6] មាត្រា ៨ ,កថាខណ្ឌទី១ នៃច្បាប់ភូមិបាល ២០០១

[7] សទ្ទានុក្រមរដ្ឋផ្នែករដ្ឋប្បវេណី ,ទំព័រ ២១ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[8] សទ្ទានុក្រមរដ្ឋផ្នែករដ្ឋប្បវេណី, ទំព័រ ១៧, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

ករណីកិច្ចរបស់មត៌កជនតាមរយៈសន្តតិកម្ម [9] គឺជា "សន្តតិជន" ឬ ជាជនដែលទទួលទ្រព្យសម្បត្តិពីអ្នកស្លាប់។[10] លើសពីនេះ សន្តតិជន អាចជាបុគ្គលតែម្នាក់ ឬបុគ្គលច្រើននាក់ ដែលអាចជា កូន ចៅ ប្រពន្ធ ឪពុក ម្ដាយ ជីដូន ជីតា និងបងប្អូនបង្កើត។ល។

ពាក្យ "សន្តតិកម្មតាមច្បាប់" គឺជាសន្តតិកម្មដែលធ្វើឡើងដោយស្វ័យប្រវត្តិ ទោះធ្វើក្នុងឆន្ទៈឬក្រៅឆន្ទៈរបស់មតកជនក៏ដោយ។[11]

ជារួមមក សន្តតិកម្មតាមច្បាប់ សំដៅលើការផ្ទេរទ្រព្យសម្បត្តិទាំងឡាយណា (សិទ្ធិ និងករណីកិច្ចនៃទ្រព្យទាំងស្រុង) របស់បុគ្គលណាម្នាក់ដែលបានស្លាប់ទៅហើយឲ្យទៅបុគ្គលម្នាក់ ឬ ច្រើននាក់ដែលត្រូវបានចាត់ទុកជាសន្តតិជនតាមច្បាប់រួមមាន កូន ចៅ ប្រពន្ធ ឪពុក ម្ដាយ ជីដូន ជីតា និងបងប្អូនបង្កើត ដោយសារគ្មានលិខិតបណ្ដាំរបស់មតកជនអំពីវិធីនៃការបែងចែកចំណែកមតក ។ ដូច្នេះ រាល់ការបែងចែកចំណែកមតករបស់មតកជន ត្រូវផ្អែកតាមបញ្ញត្តិនៃច្បាប់នៃក្រមរដ្ឋប្បវេណី ដោយមិនពិចារណាលើឆន្ទៈរបស់មតកជនកាលមានជីវិតឡើយ។

### ១.២.២ ចរិតលក្ខណៈនៃសន្តតិកម្មតាមច្បាប់

យោងតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ សន្តតិកម្មតាមច្បាប់ មានលក្ខណៈ២ប្រភេទគឺចាប់បង្ខំឲ្យអនុវត្ត និងការគោរពលើឆន្ទៈបុគ្គលឯកជន។

- ការចាប់បង្ខំឲ្យអនុវត្ត ៖ គឺសន្តតិជនមិនអាចធ្វើការទាមទារមត៌កឬធ្វើការផ្លាស់ប្ដូរលំដាប់តាមតែចិត្តនោះទេគឺតម្រូវឲ្យគោរពតាមបទប្បញ្ញត្តិច្បាប់ដែលចែងក្នុងក្រមរដ្ឋប្បវេណី គន្ថីទី៨។
- ការគោរពតាមឆន្ទៈបុគ្គលឯកជន៖សន្តតិជននៅតែមានសិទ្ធិទទួលបានភាគនៃវិភាគទានដែលខ្លួនបានជួយទំនុកបម្រុងមតកជន ឬ ការបង្កើនសេដ្ឋកិច្ចដោយការមើលថែរក្សាជំនួញ ការថែទាំព្យាបាលមតកជនដោយតាមរយៈការដាក់ពាក្យស្នើសុំឲ្យតុលាការចេញសេចក្ដីសម្រេច បើករណីការពិភាក្សាមិនចុះសម្រុងគ្នា។[12]

លើសពីនេះទៀត ចរិតលក្ខណៈនៃសន្តតិកម្មតាមច្បាប់នេះក៏បានចែងផងដែរថា សន្តតិជននៅតែមានសិទ្ធិក្នុងការទទួលយល់ព្រម ឬបដិសេធដោយការបោះបង់ក្នុងការទទួលចំណែកមត៌ករបស់មតកជន តាមការសម្រេចចិត្តរបស់សន្តតិជន ក្នុងករណីទទួលបានដោយផ្នែក ឬ ទាំងអស់នៃមត៌កក៏ដោយ។ នៅត្រង់ចំណុចនេះ

[9] សទ្ទានុក្រមក្រមរដ្ឋផ្នែករដ្ឋប្បវេណី,ទំព័រ ២១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[10] លោកមេធាវី អ៊ីវ ប៉ូលី លោកស្រីមេធាវី ទេព បូផល,ដកស្រង់ពី,សន្តតិជន

[11] លោក ខាន់ សុខា និង លោកស្រី ឌី លីឡា,សៀវភៅសន្តតិកម្មនិងអច្ច័យទាន

[12] មាត្រា១១៦៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាកច្រកម្ពុជា ឆ្នាំ២០០៧

ដើម្បីការពារផលប្រយោជន៍សន្តតិជន ព្រោះពេលខ្លះមត៌កត្រូវទទួលនោះអាចជាកាតព្វកិច្ចច្រើនជាងផលប្រយោជន៍ ដែលធ្វើឲ្យប៉ះពាល់ដល់ជីវភាពរបស់សន្តតិជននោះ ។

## ១.៣ លក្ខណៈសម្បត្តិនៃការទទួលបានសិទ្ធិនិងផ្តាច់សិទ្ធិជាសន្តតិជន

ក្រោយពីបានសិក្សាលើចរិតលក្ខណៈក៏ដូចជាបទដ្ឋានគតិយុត្តិមកនៅក្នុងចំណុចបន្ទាប់នេះយើងនឹងបកស្រាយលើលក្ខខណ្ឌដែលអាចឲ្យសន្តតិជនទទួលបានសិទ្ធិពេញលេញជាសន្តតិជន “ ១.៣.១” ។ ផងដែរនោះយើងនឹងសិក្សាលើលក្ខខណ្ឌ ដែលនាំឲ្យសន្តតិជនណាម្នាក់បាត់បង់សិទ្ធិជាសន្តតិជនក្នុងការមានសិទ្ធិទទួលបានចំណែកមត៌ក“១.៣.២”។

### ១.៣.១ គុណសម្បត្តិនៃការទទួលបានសិទ្ធិជាសន្តតិជន

លក្ខខណ្ឌចាំបាច់ ដើម្បីទទួលបានសិទ្ធិជាសន្តតិជនបានគឺជននៃត្រូវជាបុគ្គលនៅរស់រានបានជីវិតដល់ថ្ងៃចាប់ផ្តើមសន្តតិកម្ម[13] ទោះជាក្នុងករណីស្ថានភាពជាទារកក្នុងគភ៌“១.៣.១.១” ឬជារូបវន្តបុគ្គល“១.៣.១.២”

#### ១.៣.១.១ ស្ថានភាពជាទារកក្នុងគភ៌

បុគ្គលដែលមានជីវិតទើបអាចក្លាយជាសន្តតិជនបាន ករណីនេះមានអញ្ញត្រកម្ម ទារកក្នុងគភ៌របស់ម្តាយ ក៏អាចមានសិទ្ធិជាសន្តតិជនបានដែរ តែលក្ខខណ្ឌទារកក្រោយពេលកើតមកត្រូវអាចរស់រានមានជីវិត ជាគោលការណ៍ ទារកក្នុងគភ៌នឹងត្រូវទទួលបានសន្តតិកម្មគិតចាប់ពីពេលបើកសន្តតិកម្ម[14] នេះមិនមែនមានន័យថា ទារកអាចបើកសន្តតិកម្ម ដោយគិតពីការចាប់កំណើតចេញពីគភ៌ម្តាយនោះទេ។ ការតាក់តែងច្បាប់នេះឡើងបានធ្វើឲ្យទារកក្នុងគភ៌ក៏ទទួលបានផលប្រយោជន៍ដែលខ្លួនគួរតែបានផងដែរ ដោយក្នុងឋានៈជាសន្តតិជននៃសន្តតិកម្ម។

#### ១.៣.១.២ រូបវន្តបុគ្គល

យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានបញ្ញត្តិអំពីបុគ្គលដែលក្លាយជាម្ចាស់សិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនបាន លុះត្រាតែជារូបវន្តបុគ្គលដែលមានជីវិតក្រោយការកើត។[15] រូបវន្តបុគ្គលក្នុងន័យនេះ សំដៅទៅលើមនុស្សពិតតាមធម្មជាតិដែលផ្ទុយទៅនឹងនីតិបុគ្គល។[16] ជាការពិតណាស់ សន្តតិជនដែលជារូបវន្តបុគ្គល មិនត្រឹមមានជីវិតរស់រាននោះទេ សន្តតិជនក៏ត្រូវមានសមត្ថភាពគ្រប់គ្រាន់តាមផ្លូវច្បាប់ និងលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីក្លាយជាប្រធាននៃសិទ្ធិនិងកាតព្វកិច្ចនៃសន្តតិកម្មផងដែរ ពោលគឺមិនមែនជាបុគ្គល

[13] មាត្រា ១១៤៩, កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[14] មាត្រា៩ កថាខណ្ឌទី២,កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[15] មាត្រា៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[16] សទ្ទានុក្រមផ្នែករដ្ឋប្បវេណី,ទំព័រ ១៩ ,ក្រមរដ្ឋប្បវេណីនៃព្រះរាជាចក្រកម្ពុជាឆ្នាំ២០០៧

ដែលច្បាប់បានហាមឃាត់[17] ដើម្បីធ្វើការគ្រប់គ្រងចាត់ចែងទៅលើចំណែកមត៌ក ដែលជាចំណែករបស់ខ្លួនបាន សន្តតិជននោះក៏តម្រូវឲ្យមានអាយុយ៉ាងហោចណាស់១៨ឆ្នាំផងដែរ។[18]

ប៉ុន្តែក្នុងករណីដែលក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានលើកលែងដល់សន្តតិជន ដែលមិនទាន់គ្រប់អាយុ ១៨ឆ្នាំ ក៏អាចមានសិទ្ធិក្នុងការចាត់ចែងចំណែកមត៌កបានដែរ ដូចជាករណីអត្តាធិនភាពដែលបានមកពី តុលាការ ដោយមូលហេតុអាចឯករាជ្យលើខ្លួនឯងបាន តាមរយៈការស្នើរសុំរបស់សាមីខ្លួន ឬ ការយល់ឃើញថា មានផលប្រយោជន៍ចំពោះអនីតិជននោះ។ [19] លក្ខខណ្ឌផ្សេងទៀតក្នុងការទទួលអត្តាធិនភាពដោយពុំចាំបាច់ មានការប្រកាសពីតុលាការគឺ អនីតិជនទាំងឡាយណាដែលបានរៀបអាពាហ៍ពិពាហ៍រួចឬអាចរៀប អាពាហ៍ពិពាហ៍ហើយតែលែងលះគ្នាវិញក៏អានុភាពនៃអត្តាធិន ភាពនៅតែមានដដែល។

ករណីដែលសន្តតិជនជាជនបរទេស ដែលមិនមានសញ្ជាតិខ្មែរ ហើយត្រូវទទួលបានចំណែកមត៌កតាម សន្តតិកម្ម ឬតាមអច្ច័យទានដែលជាដីធ្លី ហើយមិនមែនជាអគាសហកម្មសិទ្ធិចាប់ពីជាន់ទី១ឡើងទៅ គឺពុំអាច ទទួលបានចំណែក សន្តតិកម្មនោះបានឡើយ។ ប្រសិនបើសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ សុទ្ធតែពុំមានសញ្ជាតិខ្មែរនោះទេ ដីធ្លីដែលជាចំណែកមត៌ក ត្រូវបម្លែងក្លាយជាទ្រព្យនីតិបុគ្គល ធ្វើការគ្រប់គ្រង ចាត់ចែងចំណែកមត៌កនោះដោយសន្តតិជនទាំងអស់នោះក្នុងនាមជាជានីតិបុគ្គលនោះ ។[20] ក្នុងរយៈពេល ៣ (បី) ខែ នីតិបុគ្គលនោះត្រូវធ្វើការលក់ចំណែកមត៌កដែលជាដីធ្លីនោះ ដោយមានការយល់ព្រមទាំងអស់គ្នា ឬ ដោយមានកម្រិតពីសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ។រីឯថ្លៃដែលទទួលបានពីការលក់ ចំណែកមត៌កក្នុងមានជានីតិបុគ្គលនោះនឹងក្លាយជាចំណែកមត៌កធ្វើការចែកឲ្យសន្តតិជនដែលមិនមានសញ្ជាតិ ខ្មែរទាំងនោះ រីឯនីតិបុគ្គលខាងលើ នឹងត្រូវបញ្ចប់ភារកិច្ច ហើយត្រូវរំលាយចោល។

ផ្ទុយទៅវិញ ប្រសិនបើដីធ្លីដែលគ្រប់គ្រងចាត់ចែងដោយសន្តតិជន ដែលមិនមានសញ្ជាតិខ្មែរទាំងអស់ ក្នុងនាមជានីតិបុគ្គល មិនបានលក់ដីធ្លី ក្នុងរយៈពេល៣ (បី) ខែគិតចាប់ពីពេលដែលសន្តតិជនដែលមាន លំដាប់សន្តតិកម្មមុនទាំងអស់នោះ យល់ព្រមទាំងស្រុង ឬ បានយល់ព្រមដោយមានកម្រិតក្នុងការចាត់ចែង លក់ ដូច្នេះសន្តតិជនដែលមានលំដាប់ក្រោយបន្ទាប់ដែលមានសញ្ជាតិខ្មែរ នឹងទទួលបានចំណែកមត៌កដែល

[17] មាត្រា ១១៤៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[18] មាត្រា ១៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[19] មាត្រា២១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[20] មាត្រា៦ នៃច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស

ជាដីធ្លីនោះ រីឯនីតិបុគ្គលនោះត្រូវចាត់ទុកថាគ្មានអត្ថិភាព។ [21] ក្នុងករណីសន្តតិជនដែលមានលំដាប់ក្រោយបន្ទាប់ពុំមានសញ្ជាតិខ្មែរ ចំណែកមត៌កដែលជាដីធ្លីនោះនឹងក្លាយជាកម្មសិទ្ធិរបស់រដ្ឋ។[22]

### ១.៣.២ លក្ខខណ្ឌនៃការផ្តាច់សិទ្ធិជាសន្តតិជន

នៅក្នុងចំណុចនេះ យើងនឹងធ្វើការសិក្សាពី កត្តាដែលនាំឲ្យសន្តតិជនបាត់បង់សិទ្ធិជាសន្តតិជន ដែលមាន “ ករណីអភ័ព្វបុគ្គល” ឬ “ករណីជនត្រូវបានផ្តាច់ពីមត៌ក” ។

#### ១.៣.២.១ ករណីអភ័ព្វបុគ្គល

ពាក្យ “អភ័ព្វបុគ្គល” សំដៅលើបុគ្គលទាំងឡាយណាដែលបាត់បង់លក្ខណៈសម្បត្តិនូវសិទ្ធិជាសន្តតិជន និងមិនអាចទទួលបានចំណែកមត៌កទាំងអស់ ដោយសារបុគ្គលទាំងនោះបានប្រព្រឹត្តិ នូវអំពើណាមួយដូចខាងក្រោម ៖

**ទី១** បុគ្គលដែលទទួលទោស ឬដោយសារចេតនាធ្វើឃាត ឬប៉ុនប៉ងធ្វើឃាតលើមតកជន ឬលើជនដែលមានលំដាប់សន្តតិកម្មមុន ឬ លំដាប់ស្មើគ្នាទោះបីជាដោយផ្ទាល់ក្តី ឬប្រយោលក្តី។

**ទី២** បុគ្គលដែលដឹងអំពីការសម្លាប់មតកជនតែមិនរាយការណ៍ ឬ មិនបានប្តឹង។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះមិនអាចវិនិច្ឆ័យអំពើល្អ ឬអាក្រក់បាន ឬករណីអ្នកសម្លាប់ជា សហព័ទ្ធ ឬញាតិលោហិតខ្សែផ្ទាល់របស់បុគ្គលនោះ។

**ទី៣** បុគ្គលដែលបានរារាំងមតកជនក្នុងការធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ ស្តីពីសន្តតិកម្មដោយការឆបោក ឬគំរាមកំហែង។

**ទី៤** បុគ្គលដែលបានធ្វើឲ្យមតកជនធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ ស្តីពីសន្តតិកម្មដោយការឆបោក ឬគំរាមកំហែង។

**ទី៥** បុគ្គលដែលបានក្លែង កែបន្លំ បំផ្លាញចោល ឬ លាក់ទុកនូវលិខិតមតកសាសន៍ ស្តីពីសន្តតិកម្មរបស់មតកជន។[23]

#### ១.៣.២.២ ជនដែលបានផ្តាច់ពីមត៌ក

បុគ្គលដែលបានប្រព្រឹត្តិនិងស្ថិតក្នុងលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់ ដោយមតកជនកាលនៅរស់បានដាក់ពាក្យប្តឹងទៅតុលាការព្រមទាំងមានសេចក្តីសម្រេចរបស់តុលាការតាមរយៈការស្នើពាក្យសុំរបស់ម្ចាស់បណ្តាំ ឬអ្នកប្រតិបត្តិមតកសាសន៍ក្នុងការផ្តាច់សិទ្ធិភាគបម្រុងរបស់សន្តតិជនមានដូចខាងក្រោម៖

---

[21] មាត្រា ១១៥៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[22] មេធាវី អ៊ីវ ប៉ូលី,សៀវភៅ សន្តតិកម្ម ឆ្នាំ២០១០ ,ទំព័រ ៨

[23]មាត្រា ១១៥០ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

1. បុគ្គលដែលបានធ្វើបាបចំពោះមតកជន។
2. បុគ្គលដែលបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ។
3. បុគ្គលដែលអាចមើលថែទាំមតកជនពេលមានជំងឺ ប៉ុន្តែមិនមកមើលថែទាំ
4. បុគ្គលដែលបានទទួលសាលក្រម ឬសាលដីកាផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត
5. បុគ្គលដែលបានប្រព្រឹត្តិអំពើល្មើសធ្ងន់ធ្ងរ គួរឲ្យកត់សម្គាល់ជាអាទិ៍។[24]

## ១.៤ អានុភាពនៃសន្តតិកម្ម

ក្នុងចំណុចនេះនឹងបកស្រាយពីផលគតិយុត្ត ក្នុងច្បាប់ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ ដែលចែងអំពីការចាប់ផ្តើមសន្តតិកម្ម អំពីចំណុច ២.៣.១“ ពេលវេលាបើកសន្តតិកម្មតាមច្បាប់”និង សិក្សាលើ ចំណុច ២.៣.២ “ទីកន្លែងបើកសន្តតិកម្ម”។

### ១.៤.១ ការចាប់ផ្តើមនៃសន្តតិកម្ម

សន្តតិកម្មត្រូវចាប់ផ្តើមដោយមរណភាពរបស់មតកជន[25] ត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិច្បាប់។ នេះមានន័យថាមិនទទួលស្គាល់នៅពេលដែលមតកជននៅរស់នោះទេ។

នៅពេលដែលសន្តតិកម្មច្បាប់ចាប់ផ្តើម មានតួនាទីយ៉ាងសំខាន់នៃការចែកចំណែកដល់សន្តតិជនដែលស្របច្បាប់ ករណីមតកជនមិនបានបង្ហាញឆន្ទៈច្បាស់លាស់មួយក្នុងទំហំនិងកម្រិតនៃទ្រព្យសម្បត្តិទាំងនោះ ដោយហេតុមតកជនទទួលមរណភាពដោយចៃដន្យ ឬ ភ្លាមៗ ដូចជា គ្រោះថ្នាក់ចរាចរណ៍រហូតបាត់បង់ជីវិត ជំងឺគាំងបេះដូង ជាដើម។ ម៉្យាងវិញទៀត មតកជន មិនបានបន្សល់ទុកលិខិតបណ្តាំ ប៉ុន្តែគ្មានសុពលភាពគតិយុត្តក្នុងការយកមកប្រើប្រាស់បានឡើយ។

### ១.៤.២ ពេលវេលាបើកសន្តតិកម្ម

ការបើកសន្តតិកម្មគឺនៅពេលមតកជនបានទទួលមរណភាពឬការបាត់ខ្លួននោះសន្តតិកម្មនឹងត្រូវបានចាប់ផ្តើម។

#### ១.៤.២.១ មរណភាពនៃបុគ្គល

ដើម្បីបញ្ជាក់អំពីបុគ្គលម្នាក់បានស្លាប់ លុះត្រាតែមានការឆ្លងកាត់ការពិនិត្យកោសល្យវិច័យដោយអ្នកជំនាញ និង ចេញលិខិតបញ្ជាក់មរណភាពរបស់បុគ្គលនោះដោយមន្ត្រីអត្រានុកូលដ្ឋាន។ ការបែងចែកទ្រព្យ

24 មាត្រា ១១៥១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

25 មាត្រា១១៤៥ ,កថាខណ្ឌ១ ,នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

សម្បត្តិរបស់មតកជនអាចធ្វើការបែងចែកបាន លុះត្រាតែ មតកជនបានទទួលមរណភាព បើមិនដូច្នោះទេ នឹងគ្មានការបើកសន្តតិកម្មឡើយ។[26]

**១.៤.២.២ករណីបាត់ខ្លួន**

ក្រៅពីមរណភាពរបស់បុគ្គលណាម្នាក់ ការបាត់ខ្លួនពីលំនៅដ្ឋានក្នុងរយៈពេលក៏យូរគ្មានការផ្តល់ដំណឹងអ្វីសោះដល់សាច់ញាតិ ការបាត់សូន្យឈឹងមិនដឹងថា បុគ្គលនោះបានជួបគ្រោះថ្នាក់ដល់ស្លាប់ ឬ រស់ អ្នកដែលទទួលបានផលប្រយោជន៍ស្របតាមផ្លូវច្បាប់ (សន្តតិជន)ដូចជា សហព័ទ្ធ អ្នកទទួលបានប្រាក់ធានារ៉ាប់រង អច្ច័យលាភី អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល និង ឪពុកម្តាយដែលទទួលបានផលប្រយោជន៍( សន្តតិកម្ម)អាចចាប់ផ្តើមសន្តតិកម្មបានដោយគោរពតាមលក្ខខណ្ឌចំនួន២(ពីរ)៖

ក.**ការបាត់ខ្លួនធម្មតា** ៖ អ្នកដែលបានប្រយោជន៍ពាក់ព័ន្ធ អាចដាក់ពាក់សុំឲ្យតុលាការប្រកាសការបាត់ខ្លួនរបស់បុគ្គលនោះ ដោយសារការបាត់របស់បុគ្គលនោះពុំដឹងច្បាស់ថារស់ឬទទួលមរណភាពក្នុងកំឡុងពេល៥ឆ្នាំ ។

ខ.**ការបាត់ខ្លួនក្នុងស្ថានភាពពិសេស**៖ ការបាត់ខ្លួន ឬ ការមិនបានដំណឹងពីបុគ្គលនោះក្នុងអំឡុងពេល១ឆ្នាំ ក្រោយពីចប់ព្រឹត្តិការណ៍ពិសេស(គ្រោះថ្នាក់) អាចជា សង្គ្រាម ការលិចនាវា ការរញ្ជួយដី អគ្គីភ័យ ស៊ូណាមិ ( រលកយក្ស) ការរអិលផ្ទាំងទឹកកកពីភ្នំ ។ល។ ដូចនេះលក្ខខណ្ឌទាំងនេះ ក៏ជាលក្ខខណ្ឌនៃការប្រកាសការបាត់ខ្លួនផងដែរ ដោយតុលាការប្រកាសតាមពាក្យសុំរបស់អ្នកដាក់ពាក្យសុំ។[27]

ក្នុងនោះផងដែរ ការប្រកាសការបាត់ខ្លួនក៏ត្រូវឆ្លងកាត់នីតិវិធីការដាស់តឿនជាសាធារណៈ [28] ក្នុងគោលបំណងដើម្បីផ្តល់ឱកាស និងអនុញ្ញាតឲ្យបុគ្គលដែលដឹងដំណឹងពីការស្លាប់ ឬ រស់ របស់បុគ្គលដែលត្រូវប្រកាសបាត់ខ្លួនរាយការណ៍មកបុគ្គលដែលពាក់ព័ន្ធ។ បន្ទាប់មកអ្នកដាក់ពាក្យសុំដាក់បានត្រឹមត្រូវ និងតុលាការចេញដីកាសម្រេចចូលជាស្ថាពរ ត្រង់ន័យនេះដីការបស់តុលាការមានតម្លៃស្មើសំបុត្រមរណភាព [29] ហើយថ្ងៃដែលចេញសេចក្តីសម្រេចប្រកាសអំពីការបាត់ខ្លួន ត្រូវចាត់ទុកជាពេលវេលានៃការបើកសន្តតិកម្មតាមច្បាប់។

**១.៤.២.៣ ទីកន្លែងបើកសន្តតិកម្ម**

ដោយយោងទៅតាមក្រមរដ្ឋប្បវេណី២០០៧ *កន្លែងដែលជាទីតាំងនៃជីវភាពរស់នៅនៃបុគ្គលម្នាក់ៗ ត្រូវបានយកធ្វើជាលំនៅដ្ឋាន។* [30] លំនៅដ្ឋានរបស់មតកជននៅពេលមរណភាព ជាកន្លែងសន្តតិកម្មត្រូវចាប់

[26] មាត្រា ១១៤៥ ,កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[27] មាត្រា ៤១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[28] មាត្រា ៤២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[29] មាត្រា ៤៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[30] មាត្រា ៣៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ផ្ដើម។[31] នៅក្នុងករណីមតកជនមានលំនៅដ្ឋានច្រើន ឬមិនមានទីសំណាក់ច្បាស់លាស់ ទីសំណាក់ចុងក្រោយដែលមតកជនបានមរណភាពនៅទីនោះ ត្រូវបានចាត់ទុកជាលំនៅដ្ឋានចុងក្រោយ[32]ដើម្បីមានភាពងាយស្រួលដល់តុលាការក្នុងការដោះស្រាយវិវាទមួយនេះនិងជូនដំណឹងដល់សាធារណៈជនទទួលបានប្រសិទ្ធិភាពខ្ពស់នៅពេលចាប់ផ្ដើមសន្តតិកម្ម។

[31] មាត្រា ១១៤៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[32] មាត្រា ៣៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

# ជំពូកទី២

# ការបែងចែកមត៌កនៃសន្តតិកម្មតាមច្បាប់

# ជំពូកទី២

# ការបែងចែកមត៌កនៃសន្តតិកម្មតាមច្បាប់

ក្រោយពីបានសិក្សាលើសញ្ញាណទូទៅនៃជំពូកទី១ រួចហើយ បន្តទៅទៀតនេះ យើងនឹងធ្វើការបកស្រាយអំពី ២.១ "លំដាប់នៃសន្តតិជន" ចំណុច ២.២ "ការកំណត់ចំណែកមត៌កនៃសន្តតិកម្មតាមច្បាប់" ចំណុច ២.៣ "ភាពសម្រួលចំណែកមត៌កនៃសន្តតិកម្មតាមច្បាប់" និងចំណុចចុងក្រោយនៃជំពូកនេះ ២.៤ "ភាគបម្រុង"។

## ២.១. លំដាប់នៃសន្តតិជន

កាលណាយើងនិយាយអំពីសន្តតិកម្មតាមច្បាប់ នោះប្រាកដជាត្រូវពិចារណាលើបុគ្គលដែលមានសិទ្ធិស្របច្បាប់ដែលអាចទទួលបានសិទ្ធិនិងករណីកិច្ចរបស់ជនដែលបានទទួលមរណភាពឬបានបាត់ខ្លួនទៅ ហើយសន្តតិជននោះនឹងអាចទទួលបានចំណែកមត៌ករបស់មតកជនតាមបញ្ញត្តិច្បាប់។

ចំពោះលំដាប់នៃសន្តតិជនក្នុងការទទួលបានចំណែកមត៌កគឺជាកត្តាដ៏សំខាន់ក្នុងការបែងចែកឋានានុក្រមបុគ្គលដែលមានសិទ្ធិក្នុងការចូលរួមទទួលបានចំណែករបស់មតកជន។ យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា លំដាប់នៃសន្តតិជនមាន ៣( បី)លំដាប់ រួមមាន បច្ឆាញាតិ បុព្វញាតិ និងសាខាញាតិ។ សន្តតិជនលំដាប់ទី១ សំដៅលើ បច្ឆាញាតិផ្ទាល់ ដែលជាកូនរបស់មតកជនដោយមានទាំងកូនបង្កើត និងកូនសុំផងដែរ។ សន្តតិជនលំដាប់ទី២ សំដៅលើបុព្វញាតិផ្ទាល់របស់មតកជន មានដូចជា ឪពុក ម្តាយ ជីដូន ជីតា។ ចំណែកឯ លំដាប់សន្តតិជនលំដាប់ទី៣ សំដៅដល់សាខាញាតិដែលជាបងប្អូនបង្កើតរបស់មតកជនដែលមានឪពុកម្តាយរួមគ្នា ឬ អាចរួមតែម្តាយឬឪពុកតែម្ខាង។

ជាមួយគ្នានេះ យើងក៏នឹងបកស្រាយអំពី សន្តតិកម្មជំនួស ហើយនឹង បុគ្គលចុងក្រោយដែលច្បាប់មិនបានរាប់បញ្ចូលជាសន្តតិជននោះគឺសហព័ទ្ធរបស់មតកជនជាសន្តតិជនជានិច្ច។

### ២.១.១. សន្តតិជនលំដាប់ទី១

សន្តតិជនលំដាប់ទី១ សំដៅដល់បច្ឆាញាតិ ដែលជាកូនរបស់មតកជន ក្នុងការទទួលបានអាទិភាពក្នុងការទទួលបានចំណែកមត៌កមុនសន្តតិជនលំដាប់ទី២ និងទី៣ បើទោះបីជាកូនរបស់មតកជននោះ ជាកូនបង្កើត ឬកូនសុំក្តី ក៏មានសិទ្ធិទទួលបានចំណែកមត៌កស្មើៗគ្នាដូចនឹងកូនបង្កើតដែរ។[33] នៅត្រង់បញ្ញត្តិនេះ មានន័យថា ទោះស្ថិតក្នុងស្ថានភាពណាក៏ដោយ ចំណែកមត៌ករបស់សន្តតិជនត្រូវបានទៅកូនបង្កើតឬ កូនសុំ កូនដែលកើតដោយចំណងអាពាហ៍ពិពាហ៍របស់មតកជនស្របច្បាប់រវាងសហព័ទ្ធនិង មតកជន ឬ កូនកើតក្រៅ

[33] មាត្រា១១៥៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ២០០៧

ចំណងអាពាហ៍ពិពាហ៍( កូនឥតខាន់ស្លា) ប៉ុន្តែត្រូវតែជាកូនដែលមានបុគ្គភាពទទួលស្គាល់ដោយច្បាប់[34]ដោយមានភស្តុតាងតាមរយៈការចុះសំបុត្រកំណើតនៅមេឃុំ ឬចៅសង្កាត់ ស្ថិតក្នុងដែនដី ឬសង្កាត់របស់ខ្លួនតាំងនៅរបស់ឪពុក ឬ ម្តាយ ក្នុងកំឡុងពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃដែលកូនកើត[35]ទើបអាចក្លាយជាសន្តតិជនបាន។

ចំពោះកូនសុំផងដែរក៏មានសិទ្ធិទទួលបានចំណែកមត៌កស្មើគ្នានិងកូនបង្កើតដែរ ប៉ុន្តែមានលក្ខណៈខុសគ្នាបន្តិច ត្រង់ ករណីកូនសុំពេញលេញ ញាតិភាពតាមផ្លូវច្បាប់ជាមួយឪពុកម្តាយបង្កើតត្រូវបានបញ្ចប់[36] ជាហេតុធ្វើឲ្យកូននោះមិនអាចទទួលបានចំណែកមត៌កពីឪពុកម្តាយបង្កើតនោះទេ មានន័យថា អាចទទួលបានចំណែកមត៌កត្រឹមឪពុកម្តាយចិញ្ចឹមប៉ុណ្ណោះ ។ ចំណែកឯ កូនសុំធម្មតា ឬ សុំកូនមិនពេញលេញ ញាតិភាពរវាងកូនសុំនិងឪពុកម្តាយបង្កើតត្រូវបន្តអត្ថិភាព[37] ពោល គឺអាចទទួលបានចំណែកមត៌កបានឪពុកម្តាយចិញ្ចឹម និង ឪពុកម្តាយបង្កើតទាំងពីរ។

### ២.១.២. សន្តតិជនលំដាប់ទី២

ការលេចឡើងនៅសន្តតិជនលំដាប់ទី២ក្នុងការទទួលបានចំណែកមត៌កបានលុះត្រាតែមិនមានវត្តមានបច្ចាញាតិជាសន្តតិជនលំដាប់ទី១ ( កូន) នោះបុព្វញាតិខ្សែផ្ទាល់ជិតជាងគេ(ថ្នាក់ទី១) របស់មត៌កជនត្រូវក្លាយជាសន្តតិជនលំដាប់ទី២។[38] សន្តតិជនលំដាប់ទី២ សំដៅដល់ ឪពុកម្តាយ (ថ្នាក់ទី១) ជីដូនជីតា (ថ្នាក់ទី២) របស់មតកជន។ ក្នុងនោះផងដែរច្បាប់បានកំណត់យកបុព្វញាតិដែលជិតជាងគេ នឹងក្លាយជាបុគ្គលមានអាទិភាពក្នុងការស្នងមត៌ក នោះសន្តតិជនលំដាប់ទី២ គឺ ឪពុកម្តាយរបស់មតកជន។ ហើយមានករណីខ្លះ ជីដូនជីតារបស់មតកជន( ថ្នាក់ទី២)ក៏អាចក្លាយជាសន្តតិជនលំដាប់ទី២បានដែរ ដោយគិតរួមទាំង ជីដូនជីតាខាងម្តាយ ឬខាងឪពុករបស់មតកជន ករណីឪពុកម្តាយរបស់មតកជនបានមរណភាព ។

ការបែងចែកចំណែកមត៌កនេះ គឺត្រូវបែងចែកចំណែកស្មើៗគ្នា បើករណី ឪពុកម្តាយរបស់មតកជននៅមានជីវិតរស់នៅទាំងពីរ មត៌កត្រូវបានបែងចែកស្មើៗគ្នា បើឪពុកម្តាយរបស់មតកជននៅរស់តែម្នាក់ឯង នោះមត៌កត្រូវទទួលយកទាំងអស់តែម្នាក់ឯងគត់ ដោយមិនមានការបែងចែកទៅឲ្យបុគ្គលណានោះទេ។

---

[34] សេចក្តីកំណត់ក្រមរដ្ឋប្បវេណីនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, គន្លឹទី៨ និង៩ ,ទំព័រ ១៤

[35] មាត្រា៩៨៥ , កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[36] មាត្រា ១០១៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[37] មាត្រា ១០២៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[38] មាត្រា ១១៥៩,កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

មួយវិញទៀត បើគ្មានឪពុកម្តាយនោះមត៌កត្រូវរុញទៅឲ្យជីដូនជីតាខាងឪពុក ឬ ខាងម្តាយ ដែលនៅមានជីវិតនូវចំណែកស្មើៗគ្នា គឺមានន័យថា ធ្វើការបែងចែកទៅតាមសមាមាត្រនៃចំនួនសន្តតិជន។[39]

ដូច្នេះ នៅក្នុងសន្តតិជនលំដាប់ទី២ នេះអាចសរបញ្ជាក់ឲ្យឃើញថា មិនមានបទប្បញ្ញត្តិពីសន្តតិកម្មជំនួសឡើយ។

**២.១.៣. សន្តតិជនលំដាប់ទី៣**

សន្តតិជនលំដាប់ទី៣ មានសិទ្ធិទទួលបានសន្តតិកម្មពីមតកជនបានលុះត្រាតែបច្ចាញាតិខ្សែផ្ទាល់(កូនរបស់មតកជន) និងបុព្វញាតិផ្ទាល់របស់មតកជន(ឪពុកម្តាយ) ពុំមានវត្តមានឬបាត់សិទ្ធិក្នុងការទទួលបានចំណែកមត៌កនោះ ទើប ច្បាប់បានបញ្ញត្តិយកបងប្អូនបង្កើតរបស់មតកជនក្នុងការស្នងមត៌ក។[40]នៅក្នុងករណីមានបងប្អូនបង្កើតច្រើន នោះបងប្អូនបង្កើតត្រូវទទួលបានចំណែកមត៌កតាមស្មើៗគ្នា ឬបែងចែកចំណែកមត៌កទៅតាមសមាមាត្រនៃចំនួនបងប្អូនបង្កើតរបស់មតកជន ។ ផ្ទុយទៅវិញ បើបងប្អូនបង្កើតនោះមានឪពុកឬម្តាយផ្សេងគ្នាទៅនឹងមតកជននៃចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុកម្តាយទាំងសងខាង នោះមានសិទ្ធិទទួលបានចំណែកមត៌កត្រឹមតែ១ភាគ២ប៉ុណ្ណោះ។[41] ចំពោះញាតិផ្សេងទៀត ក្រៅពីជនរៀបរាប់ខាងលើ ដូចជា ពូ មីង ឬបងប្អូនជីដូនមួយរបស់មតកជនគ្មានសិទ្ធិទទួលបានសន្តតិកម្មបានទេ តែអញ្ញត្រកម្មបើក្នុងករណីបុគ្គលនោះជាជនមាននិស្ស័យពិសេសទៅនឹងមតកជន។ [42] បើសន្តតិកម្មនោះមិនមានអ្នកស្នងនោះទេ សន្តតិជនមាននិស្ស័យនោះអាចដាក់ពាក្យស្នើសុំទៅតុលាការ ជនមាននិស្ស័យពិសេសអាចទទួលបានចំណែកមត៌កបើតុលាការយល់ឃើញថា សមហេតុផល។[43]

**២.១.៤. សន្តតិជនជំនួស**

សន្តតិជនជំនួស គឺជា បច្ចាញាតិនៃជនដែលបាត់បង់លក្ខណៈសម្បត្តិជាសន្តតិជនក្នុងការស្នងមត៌ក។ សន្តតិជនជំនួសនោះ អាចត្រូវជា កូន ចៅ នៃសន្តតិជនដែលបាត់បង់លក្ខណៈសម្បត្តិនោះអាចជា អភ័ព្វបុគ្គល ឬ ជនដែលផ្តាច់ពីមត៌ក។ សន្តតិកម្មជំនួស អាចកើតមានឡើងក្នុងករណី នៅពេលមានសន្តតិជនជាអភ័ព្វ

[39] មាត្រា ១១៥៩,កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[40] មាត្រា ១១៦០,កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[41] មាត្រា ១១៦០,កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[42] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧,គន្លឹ៨និង៩, ទំព័រ ១៩
[43] មាត្រា ១២៩៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

បុគ្គល ឬ ជនដែលផ្ដាច់ចេញពីមត៌ក និងករណីដែលជនទទួលមរណភាពមុន ឬ ស្របពេលជាមួយនឹងមតកជន នោះសន្តតិកម្មជំនួសនឹងកើតមានឡើង។[44]

បើក្នុងលក្ខខណ្ឌដែលកូនរបស់មតកជនបានស្លាប់ក្រោយក្រោយពេលចាប់ផ្តើមសន្តតិកម្ម សន្តតិជនបានមរណភាពនោះទទួលសន្តតិកម្មរបស់មតកជន នាំឲ្យកូនរបស់ជនមរណភាពនៃមតកជននោះនឹងទទួលសន្តតិកម្មបន្តទៀត។[45]

ចំពោះករណីកូនស្មុំរបស់មតកជន មាន ២ ករណី៖

- បើកូនស្មុំរបស់មតកជនមានកូនដែលកើតមុនពេលកូនស្មុំធម្មតានោះបានក្លាយជាកូនស្មុំរបស់មតកជននោះកូនរបស់កូនសុំនោះមិនអាចជាក្លាយជាសន្តតិជនជំនួសបានទេ ដោយសារកូនមិនមែនជាបច្ឆាញាតិផ្ទាល់(ចៅ)របស់មតកជន។
- បើកូនស្មុំរបស់មតកជនមានកូនកើតក្រោយមុនពេលកូនស្មុំធម្មតារបស់មតកជននោះក្លាយជាកូនសុំរបស់មតកជននោះ កូនរបស់កូនសុំនោះនឹងក្លាយជាសន្តតិជនជំនួស ព្រោះជាបច្ឆាញាតិផ្ទាល់(ចៅ) របស់មតកជនដែលមិនអាចត្រូវបានហាមឃាត់ការស្នងមត៌កនេះឡើយ។[46]

សន្តតិកម្មជំនួសអាចធ្វើបន្តបន្ទាប់បានសម្រាប់បច្ឆាញាតិផ្ទាល់របស់មតកជន ប្រសិនបើមានហេតុដូចបានកំណត់ខាងលើ ដូចជាករណីរបស់មតកជនបានទទួលមរណភាព នោះកូនរបស់ចៅ ( ចៅទួតរបស់មតកជន) នឹងក្លាយជាសន្តតិជនជំនួស។[47] សន្តតិជនជំនួស ទទួលបានចំណែកស្មើគ្នានៃចំណែកមត៌កដែលសន្តតិជនទទួលបានដោយមិនថា សន្តតិជនជំនួសនោះជាកូនបង្កើត ឬកូនសុំទេ។[48]

សន្តតិកម្មជំនួស អាចអនុវត្តចំពោះសន្តតិជនលំដាប់ទី៣ដែលត្រូវបងប្អូនបង្កើតរបស់មតកជនបាន ប៉ុន្តែច្បាប់បានទទួលស្គាល់ត្រឹមតែមួយតំណប៉ុណ្ណោះ។[49]

### ២.១.៥. សន្តតិជនជានិច្ច

បើយើងនិយាយអំពីសហព័ទ្ធ សហព័ទ្ធមិនមានទំនាក់ទំនងជាបុព្វញាតិ បច្ឆាញាតិ ឬសាខាញាតិនៃមតកជនដូចសន្តតិជនដទៃទៀតក៏ដោយ ក៏ប៉ុន្តែសហព័ទ្ធមានសិទ្ធិស្របច្បាប់ក្នុងការទទួលបានចំណែកមត៌ក

---

[44] មាត្រា ១១៥៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[45] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧,គន្លឹ៨និង៩ ,ទំព័រ ១៥

[46] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, គន្លឹ៨និង៩ , ទំព័រ ១៦

[47] មាត្រា ១១៥៧ ,កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[48] មាត្រា ១១៥៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[49] សេចក្តីកំណត់មាត្រានីមួយៗនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧,គន្លឹ៨និង៩,ទំព័រ ១៦

នៃមតកជនដែលក្រមរដ្ឋប្បវេណីបានកំណត់ហើយត្រូវបានហៅថាសហព័ទ្ធជានិច្ចនៃមតកជន។[50] ពាក្យ“ជានិច្ច”មានន័យថាភាពគ្មានពាក់ព័ន្ធនឹងអត្ថិភាពរបស់សន្តតិជនផ្សេងព្រមទាំងលំដាប់នៃសន្តតិកម្ម។

ក្នុងនោះផងដែរ មិនខ្វល់ថា មានសន្តតិជន ឬ គ្មានសន្តតិជនផ្សេងទៀតក៏ដោយ ក៏សហព័ទ្ធត្រូវបានច្បាប់ទទួលស្គាល់សិទ្ធិទទួលបានសន្តតិកម្ម ជាពិសេសេ សហព័ទ្ធនោះទទួលបានចំណែកមត៌កដែលជាចំណែកនៃទ្រព្យដោយឡែកនិងទ្រព្យរួមរបស់មតកជន។

បើក្នុងករណីសហព័ទ្ធក្លាយជាសន្តតិជន និងមានបុគ្គលសន្តតិជនផ្សេងទៀត ទោះបីជាសន្តតិជននោះជាបុព្វញាតិ បច្ឆាញាតិ ឬសាខាញាតិ ឬ ក៏បងប្អូនបង្កើតក៏ដោយ ក៏សន្តតិជនជានិច្ចមានលំដាប់ស្មើគ្នានឹងសន្តតិជននោះនឹងទទួលបានចំណែកមត៌កស្មើគ្នា។

អញ្ញត្រកម្ម បើសហព័ទ្ធនៃមតកជនជាអភ័ព្វបុគ្គលឬជាជនដែលត្រូវផ្តាច់ចេញពីមត៌កក៏មិនអាចក្លាយជាសន្តតិជនទទួលបានសន្តតិកម្មបានឡើយ។

## ២.២.ការកំណត់ចំណែកមត៌កតាមលំដាប់សន្តតិជន

នៅក្នុងចំណុចនេះ យើងធ្វើការសិក្សាយើងពីរចំណុចសំខាន់ ២.២.១.“ករណីមានសន្តតិជនប៉ុន្តែគ្មានសហព័ទ្ធ” និងចំណុចមួយទៀត ២.២.២.“ករណីមានសន្តតិជនជានិច្ច ” (មានសន្តតិជននិងមានសហព័ទ្ធ) ។

### ២.២.១.ករណីមានសន្តតិជនប៉ុន្តែគ្មានសហព័ទ្ធ

ដោយយោងតាមសទ្ធានុក្រមនៃក្រមរដ្ឋប្បវេណី សំដៅដល់ញាតិលោហិតក្នុង៦ថ្នាក់ សហព័ទ្ធ និងញាតិពន្ធក្នុង៣ថ្នាក់។ ដូច្នេះ ញាតិនៃមតកជន នឹងត្រូវបានចំណែកមត៌កតាមការកំណត់របស់ច្បាប់ដូចបានរៀបរាប់ខាងក្រោម៖

#### ២.២.១.១. សន្តតិជនលំដាប់ទី១( បច្ឆាញាតិ)

សន្តតិជនលំដាប់ទី១ គឺ សំដៅដល់កូនរបស់មតកជនដែលបច្ឆាញាតិខ្សែផ្ទាល់ត្រូវទទួលបានចំណែកស្មើៗគ្នា។ ការបែងចែកមត៌កតាមចំនួនសន្តតិជនជាកូនរបស់មតកជនជាក់ស្តែង ទោះបីជាសន្តតិជននោះជាបច្ឆាញាតិ(កូនបង្កើត)កូនសុំធម្មតាឬកូនសុំពេញលេញគឺនៅតែទទួលបានចំណែកមត៌កស្មើៗគ្នាប៉ុន្តែប្រសិនបើសន្តតិជនមានតែម្នាក់ មិនចាំបាច់មានការបែងចែកឡើយ។ កូនក្រៅអាពាហ៍ពិពាហ៍ក៏ត្រូវទទួលបានចំណែកមត៌កស្មើគ្នានឹងកូនបង្កើតដោយមានចំណងអាពាហ៍ពិពាហ៍ដែរ។[51]

[50] មាត្រា ១១៦១,កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[51] សេចក្តីកំណត់មាត្រានីមួយៗក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧,គន្លឹ៨និង៩, ទំព័រ ១៥

រូបមន្តនៃការគណនាចំណែកមត៌ករបស់សន្តតិជននីមួយៗស្មើនឹងមត៌កសរុបចែកនឹងចំនួនសន្តតិជនដែលមាន។[52]

$$\text{ចំណែកមត៌កនៃសន្តតិជននីមួយៗ} = \frac{\text{មត៌កសរុប}}{\text{ចំនួនសន្តតិជនសរុប}}$$

**ឧទាហរណ៍ទី១៖** មតកជនមានកូនបង្កើតចំនួន ២នាក់គឺ កូនឈ្មោះ ក និងកូនសុំចំនួន ១ នាក់។ នាំឲ្យកូនទាំង៣ នាក់របស់មតកជនត្រូវទទួលបានចំណែកមត៌កស្មើគ្នានៃចំណែកមត៌កសរុបទាំងអស់ដែលមានរបស់មតកជន។

→ មត៌កដែលសន្តតិជនត្រូវទទួលបានម្នាក់ៗគឺ $\frac{\text{មត៌កសរុប}}{\text{ចំនួនសន្តតិជន(៣)នាក់}}$=១/៣

ដូចនេះ សន្តតិជន ម្នាក់ៗទទួលបានចំណែក ១/៣ ស្មើៗគ្នា ។

**ឧទាហរណ៍ទី២ ៖** មតកជនមានកូនបង្កើតចំនួន២នាក់គឺ ក និង ខ និងកូនសុំ ចំនួន ១នាក់គឺ គ។ ខណៈពេលបើកសន្តតិកម្ម ខ បានទទួលមរណភាព ប៉ុន្តែ ខមានកូន២ នាក់ គឺ ខ១និងខ២។ ចំណែកកូនសុំ គ ជាជនផ្តាច់ចេញពីមត៌ក ហើយ គ មានកូន ២នាក់ គឺ គ១និងគ២។ ដូចនេះ សន្តតិជន ខ និងគ មិនអាចទទួលចំណែកមត៌កបានទេ។ នៅក្នុងករណីនេះ នឹងមានលេចឡើងនូវសន្តតិកម្មជំនួស ពេលដែលសន្តតិជនទទួលស្លាប់ ឬ ដោយសារបុព្វហេតុណាមួយ( ដោយការផ្តាច់ចេញពីមត៌ក) ជាអាទិ៍ នោះចំណែកមត៌កនឹងបានទៅលើកូនរបស់សន្តតិជនវិញ។

→ មត៌កដែលសន្តតិជនត្រូវទទួលបានម្នាក់ៗគឺ

ចំណែកមត៌កសរុបនៃមតកជន ÷ សន្តតិជន(៣)នាក់=

- ចំណែក របស់ ក គឺ ១/៣ (មួយភាគបី)
- ចំណែក ១/៣ (មួយភាគបី) របស់ ខ ត្រូវបែងចែកឲ្យកូនចំនួន ២នាក់ ជា ខ១និងខ២ដោយទទួលបានម្នាក់ទទួលបាន ចំណែកមត៌ក ១/៦( មួយភាគប្រាំមួយ) ។
- ចំណែក ១/៣ (មួយភាគបី) របស់ គ ត្រូវបែងចែកឲ្យកូនចំនួន ២នាក់ ជា គ១និងគ២ដោយ ម្នាក់ៗទទួលបាន ចំណែកមត៌ក ១/៦( មួយភាគប្រាំមួយ) ។

### ២.២.១.២. សន្តតិជនលំដាប់ទី២

ករណីមតកជនពុំមានបច្ឆាញាតិផ្ទាល់ទេ នោះបុព្វញាតិផ្ទាល់គឺឪពុកម្តាយរបស់មតកជន ត្រូវក្លាយជាសន្តតិជនលំដាប់ទី២។ ចំណែកមត៌ករបស់សន្តតិជននីមួយៗត្រូវមានចំណែកស្មើៗគ្នា ករណីមតកជនមាន

[52] មាត្រា ១១៥៦,កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ឪពុកម្តាយច្រើននាក់(តាមរយៈកូនសុំធម្មតា)។ [53] ករណីសន្តតិជនមិនមានឪពុកម្តាយនោះសន្តតិជនជាជីដូនជីតានឹងក្លាយជាសន្តតិជនបន្តទទួលចំណែកមត៌កស្មើៗគ្នា។

**ឧទាហរណ៍ទី១** លោក ក ជាបុរសមិនទាន់បានរៀបការនិងមិនមានកូនទេ មានតែឪពុកម្តាយ។ នៅពេលបើកសន្តតិកម្ម នោះឪពុកម្តាយនឹងក្លាយជាសន្តតិជន ត្រូវទទួលបានចំណែកមត៌កស្មើៗគ្នា។

→ មត៌កដែលសន្តតិជនត្រូវទទួលបានម្នាក់ៗគឺ $\frac{\text{ចំណែកមត៌កសរុបនៃមត៌កជន}}{\text{សន្តតិជន(២)នាក់}}$ =១/២

ដូចនេះ ឪពុកម្តាយទទួលបានចំណែក ១/២ ស្មើៗគ្នា។

**ឧទាហរណ៍ទី២** មតកជនមិនមានឪពុកម្តាយទេ(ស្លាប់)នោះមត៌កនេះត្រូវស្នងបន្តដោយជីដូនជីតាខាងម្តាយនិងខាងឪពុក ប៉ុន្តែករណីនេះជីដូនខាងឪពុកបានទទួលមរណភាព ចំណែកឯជីតាខាងម្តាយក៏បានមរណភាពផងដែរ។

ដូចនេះ សន្តតិជនមានចំនួន ២ នាក់ដែលទទួលបានចំណែកមត៌កដោយសមាមាត្រស្មើៗគ្នា ចំនួនៈ

→ មត៌កដែលសន្តតិជនត្រូវទទួលបានម្នាក់ៗគឺ $\frac{\text{ចំណែកមត៌កសរុបនៃមត៌កជន}}{\text{សន្តតិជន(២)នាក់}}$ =១/២

ដូចនេះ ជីដូនជីតា ទទួលបានចំណែក ១/២ ស្មើៗគ្នា

### ២.២.១.៣. សន្តតិជនលំដាប់ទី៣

សាខាញាតិថ្នាក់ទី២នឹងក្លាយជាសន្តតិជនក្នុងការទទួលសន្តតិកម្មនៅពេលមិនវត្តមានកូនរបស់មតកជននិងឪពុកម្តាយក្នុងការស្នងចំណែកមត៌ក។ សាខាញាតិនៅទីនេះសំដៅដល់បងប្អូនបង្កើតរបស់មតកជន (សន្តតិជនលំដាប់ទី៣)ក្នុងការទទួលចំណែកមត៌ក បើករណីមានបងប្អូនច្រើននាក់ ចំណែកមត៌កនឹងត្រូវបែងចែកស្មើៗគ្នា លើកលែងតែជាសន្តតិជននោះជាបងប្អូនបង្កើតដែលមានឪពុកឬម្តាយតែម្ខាង (ស្ត្រី ឬ បុរសដែលបានលែងលះនិងមានកូនជាមួយសហព័ទ្ធមុន(ប្តីឬប្រពន្ធ)មុនពេលរៀបការជាមួយសហព័ទ្ធក្រោយ)ត្រូវទទួលបានចំណែកមត៌កតែពាក់កណ្តាល(១/២)នៃបងប្អូនបង្កើតដែលមានឪពុកម្តាយរួមតែប៉ុណ្ណោះ។[54]

**ឧទាហរណ៍** លោក X មានបងប្អូនបង្កើត ២(ពីរ) នាក់ គឺ Z និងY និងមានបងប្អូនរួមឪពុក P ម្នាក់ ក្នុងករណីនេះសន្មតថា គាត់មិនមានបច្ឆាញាតិនិងបុព្វញាតិទេ ។ ដូច្នេះ សន្តតិជនទទួលបានមត៌កមាន ៣(បី)នាក់ នូវចំណែកដូចខាងក្រោមៈ

→ មត៌កដែលសន្តតិជនត្រូវទទួលបានម្នាក់ៗគឺ $\frac{\text{ចំណែកមត៌កសរុបនៃមត៌កជន}}{\text{៥ ចំណែក}}$

[53] មាត្រា ១១៥៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[54] មាត្រា ១១៥៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

សម្គាល់៖ ហេតុដែលចែកដល់ ៥ ចំណែកព្រោះ P បានត្រឹមពាក់កណ្តាលនៃបងប្អូនបង្កើត Z និង Yប៉ុណ្ណោះ។

- សន្តតិជន Zទទួលបានចំណែក២/៥នៃមត៌កសរុបរបស់មតកជន
- សន្តតិជនYទទួលបានចំណែក២/៥នៃមត៌កសរុបរបស់មតកជន
- សន្តតិជន Pទទួលបានចំណែក១/៥នៃមត៌កសរុបរបស់មតកជន

**២.២.២.ករណីមានសន្តតិជនជានិច្ច(មានសន្តតិជននិងមានសហព័ទ្ធ)**

**២.២.២.១. ករណីមានតែសន្តតិជនជានិច្ច**

ទោះបីជាសហព័ទ្ធ ស្ថិតក្នុងកាលៈទេសៈណាក៏ដោយ គាត់នៅតែមានសិទ្ធិចូលរួមក្នុងការទទួលចំណែកមត៌កដូចនិងលំដាប់ទាំងបីនៃសន្តតិជនផងដែរ លើកលែងតែគាត់ក្លាយជាបុគ្គលដែលច្បាប់ហាមឃាត់។ ជាងនេះទៅទៀត សហព័ទ្ធនឹងត្រូវទទួលចំណែកមត៌កទាំងអស់តែម្នាក់ឯងគត់ប្រសិនបើមតកជនមិនមានសន្តតិជនផ្សេងទៀត។

ជាកិច្ចបន្ត ខាងក្រោមនេះយើងនឹងធ្វើរៀបរាប់ដែលជាករណីមានសន្តតិជនជានិច្ចហើយនិងមានសន្តតិជនផ្សេងទៀត(សន្តតិជនទាំងបីថ្នាក់)៖

**២.២.២.២. សន្តតិជនជានិច្ចនិងសន្តតិជនលំដាប់ទី១**

ដោយយោងតាមក្រមរដ្ឋប្បវេណីបានបញ្ញត្តិថា ករណីមតកជនមានសហព័ទ្ធនិងបច្ឆាញាតិផ្ទាល់ជាកូននីមួយៗនៃមតកជននឹងក្លាយជាសន្តតិជន នោះសន្តតិជនទាំងពីរនាក់នឹងចូលរួមបែងចែកនូវចំណែកស្មើៗគ្នា។[55]

**ឧទាហរណ៍១** លោក ក មានសហព័ទ្ធ ខ រួមទាំងមានកូនចំនួន ៣នាក់ X, Yនិងកូនសុំ Z ។ ដោយសន្មតថា លោក ក បានស្លាប់ នោះសន្តតិកម្មនឹងចាប់ផ្តើម ដែលសន្តតិជនមានសិទ្ធិស្របច្បាប់ក្នុងការទទួលរួមមាន ខ, X, Y, Z។ ដូច្នេះ សន្តតិជនទទួលបានមត៌កមាន ៤(បួន)នាក់ នូវចំណែកដូចខាងក្រោម៖

$\rightarrow$ មត៌កដែលសន្តតិជនត្រូវទទួលបានម្នាក់ៗគឺ $\frac{\text{ចំណែកមត៌កសរុបនៃមត៌កជន}}{\text{៤ចំណែក}}$ =១/៤

ដូចនេះ សន្តតិជន ខ, X, Y, Z បានចំណែក ១/៤ ស្មើៗគ្នា។

ឧទាហរណ៍ទី២ ករណីនេះ Y ជាកូនប្រពន្ធមុនរបស់មតកជន ក, មតកជន ក និងសហព័ទ្ធ ខ មានកូនបង្កើត ២ នាក់ គឺ X និង Z ប៉ុន្តែ Z ជាអភ័ព្វបុគ្គលនិងមានកូន២ នាក់។

ដូច្នេះ សន្តតិជនទាំងអស់មានចំនួន ៤ នាក់ ដែលទទួលបានចំណែក ដូចខាងក្រោម

- សហព័ទ្ធ ខ បានចំណែក ១/៤នៃមត៌កសរុប(ពាក់កណ្តាលនៃមត៌ករបស់មតកជន)

[55] មាត្រា ១១៦២នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

- សន្តតិជន X ជាកូនបង្កើត ទទួលបានចំណែក ២/២០ ឬ ១/១០
- សន្តតិជន Y ជាកូនសុំ ទទួលបានចំណែក ១/២០
- សន្តតិជន Z ជាអភ័ព្វបុគ្គល $\left(\frac{២}{២០}\right) \Rightarrow$ធ្លាក់ទៅលើកូនរបស់ Z គឺ Z១ Z២ នៅចំណែកស្មើគ្នា = ១/៤០

### ២.២.២.៣. សហព័ទ្ធនិងសន្តតិជនលំដាប់ទី២

ក្រមរដ្ឋប្បវេណីបានបញ្ញត្តិយ៉ាងច្បាស់ថា សហព័ទ្ធនិងបុព្វញាតិរបស់មតកជនជាសន្តតិជនគឺទទួលបានចំណែកមត៌កស្មើៗគ្នាដោយកំណត់ សហព័ទ្ធទទួលបាន ១/៣(មួយភាគបី) , ចំណែកឪពុកនិងចំណែកម្តាយទទួលបាន ២/៣ (ពីរភាគបី)។[56] ប៉ុន្តែបើមតកជនមានតែឪពុក ឬ ម្តាយតែម្ខាងនៅរស់វិញនោះ សហព័ទ្ធនិងឪពុកម្តាយដែលនៅរស់នោះត្រូវទទួលបានចំណែកស្មើគ្នាគឺ ១/២(មួយភាគពីរ)។[57]

ក្នុងនោះផងដែរ ជាករណីកម្រដែលមតកជនមានឪពុកម្តាយច្រើនរូប(តាមរយៈកូនសុំធម្មតា) ចំណែកមត៌ករបស់សហព័ទ្ធគឺនៅតែ ១/៣(មួយភាគបី) ដដែល តែចំណែកឪពុកម្តាយវិញច្រើននាក់គឺ២/៣(ពីរភាគបី) ដែលតម្រូវចែកសមាមាត្រតាមចំនួនសន្តតិជនជាបុព្វញាតិនោះ។

**ដោយភ្ជាប់ជាមួយអត្ថន័យខាងលើ** ករណី មតកជនមិនមានឪពុកម្តាយជាសន្តតិជនទេនោះ ជីដូនជីតាជាសន្តតិជនបន្តយកមត៌ក ទោះបីមត៌កធ្លាក់ដល់សន្តតិជនណាក៏ដោយក៏សហព័ទ្ធរបស់មតកជនត្រូវទទួលបានចំណែកមត៌កពាក់កណ្តាលនៃមត៌កសរុបរបស់មតកជនដដែលហើយសម្រាប់ចំណែកនៅសល់ពីសហព័ទ្ធនឹងធ្វើការបែងចែកនូវចំណែកស្មើៗគ្នារវាងជីដូនជីតា។

⇒ ចំណែកមត៌កនៃសន្តតិជននិងសហព័ទ្ធត្រូវទទួលបានគឺ

- សហព័ទ្ធ ទទួលបានចំណែកមត៌ក ១/២(មួយភាគពីរ)នៃចំណែកទាំងមូល
- ជីដូនជីតាទាំងសងខាងម្តាយនិងឪពុកនៃមតកជន ទទួលបានចំណែកនៅសល់ ១/២(មួយភាគពីរ) បែងចែកស្មើៗគ្នា គឺ១/៨(មួយភាគប្រាំបី)។

### ២.២.២.៤. សហព័ទ្ធនិងសន្តតិជនលំដាប់ទី៣

ក្នុងករណីដែលសន្តតិជនជាសហព័ទ្ធ និងបងប្អូនបង្កើត ឬ សន្តតិជនជំនួសបងប្អូនបង្កើត( ក្មួយប្រុស ឬក្មួយស្រី) មិនមានបុព្វញាតិផ្ទាល់ក្រៅពីឪពុកម្តាយ នោះចំណែកមត៌ករបស់សហព័ទ្ធគឺ ១/២(មួយភាគពីរ) ចំណែកឯមត៌ករបស់បុព្វញាតិផ្ទាល់ក្រៅពីឪពុកម្តាយរបស់មតកជន ឬ បងប្អូនបង្កើតរបស់បងប្អូនបង្កើតរបស់

[56] មាត្រា ១១៦២ ចំណុច ខ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[57] មាត្រា ១១៦២ ចំណុច គ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

មតកជនឬអ្នកទទួលសន្តតិកម្មជំនួសនជះ គឺ ១/២(មួយភាគពីរ)។[58] មានន័យថា ប្រសិនបើតែសហព័ទ្ធនិង ជីដូនជីតាឬបងប្អូនបង្កើត ឬសន្តតិជនជំនួស បងប្អូនបង្កើត នោះសហព័ទ្ធទទួលបានចំណែក១/២ (មួយភាគពីរ) និងសន្តតិជនផ្សេងទៀត បាន១/២(មួយភាគពីរ)ផងដែរ។

ក្នុងករណីនេះ ក៏មានគោលការណ៍សន្តតិកម្មជំនួសមកអនុវត្តផងដែរ ចំពោះបងប្អូនបង្កើតជាសន្តតិជនបានទទួលមរណភាពឬជាអភ័ព្វបុគ្គលឬជនដែលផ្តាច់ចេញពីមត៌ក ដូច្នេះ កូនដែលបងប្អូនបង្កើតនៃមតកជនឬអាចហៅថាជាក្មួយនៃមតកជននឹងក្លាយជាសន្តតិជនជំនួស តែអនុវត្តបានត្រឹមតែមួយតំណប៉ុណ្ណោះ។[59]

**ឧទាហរណ៍** មតកជន ក មានសហព័ទ្ធ ខ និងបងប្អូនបង្កើតឪពុកម្តាយរួមគ្នា A និង B ។ នៅពេលមតកជន ក មករៀបអាពាហ៍ពិពាហ៍និង ខ មានបានរៀបកាជាមួយសហព័ទ្ធមុន មានកូន ២ នាក់គឺ ក$_{១}$ និង ក$_{២}$ ចំណែកសហព័ទ្ធ ខ ក៏មានកូនជាមួយសហព័ទ្ធផ្សេងមានកូន ២នាក់គឺ ខ$_{១}$ និង ខ$_{២}$ ផងដែរ។

ចំណែកមត៌កនៃសន្តតិជននិងសហព័ទ្ធត្រូវទទួលបានគឺ

- ខ ត្រូវទទួលបានចំណែក ១/២(មួយភាគពីរ)នៃចំណែកទាំងមូល
- ចំណែកនៅសល់ពាក់កណ្តាលទៀត១/២(មួយភាគពីរ)ត្រូវបែងចែកឲ្យបច្ឆាញាតិជាកូនរបស់មតកជន ក ។
    - ចំពោះចំណែក កូន A និង B បានចំណែកស្មើៗគ្នានៃ ១/២(មួយភាគពីរ) ចំណែកកូនដែលរួមឪពុកនិងម្តាយតែម្ខាងបានតែពាក់កណ្តាលនៃចំណែកកូនឪពុកម្តាយរួមគ្នា។

តាង Xជាចំណែកមត៌ករបស់សន្តតិជននីមួយៗ

ដោយ ក$_{១}$ និង ក$_{២}$ ខ$_{១}$ និង ខ$_{២}$ បានចំណែក ១/២នៃA ឬ B

នាំឲ្យ ១/២ = X + X +X/២ + X/២ +X/២ + X/២

១/២ = ២X + ២X⇒X = 1/8

នាំឲ្យ ក$_{១}$ , ក$_{២}$ , ខ$_{១}$ , ខ$_{២}$ = ១/២នៃX = ១/១៦ , ចំណែក A និង B = X = ១/៨

**ដូច្នេះ** សហព័ទ្ធទទួលបានចំណែកមត៌ក ១/២(មួយភាគពីរ)នៃចំណែកទាំងមូល

ចំណែកមត៌ករបស់បងប្អូនបង្កើតឪពុកម្តាយរួមគ្នា A និង B ម្នាក់ៗទទួលបាន១/៨(មួយភាគប្រាំបី) នៃចំណែកមត៌កសរុប។

[58] មាត្រា ១១៦២ ,ចំណុច គ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[59] មាត្រា១១៦០ ,សេចក្តីកំណត់មាត្រានីមួយៗក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧,គន្លឹ៨និង៩, ទំព័រ ១៩

ចំណែកមត៌ករបស់បងប្អូនរួមឪពុក ក១ និង ក២ ម្នាក់ៗទទួលបាន១/១៦ (មួយភាគដប់ប្រាំមួយ) នៃចំណែកមត៌កសរុប។

ចំណែកមត៌ករបស់បងប្អូនរួមម្តាយ ខ១ និង ខ២ ម្នាក់ៗទទួលបាន១/១៦ (មួយភាគដប់ប្រាំមួយ) នៃចំណែកមត៌កសរុប។

## ២.៣ ភាពសម្រួលចំណែកមត៌កនៃសន្តតិកម្មតាមច្បាប់

ភាពសម្រួលចំណែកមត៌កសំដៅដល់ ភាពសមភាពត្រឹមត្រូវជាក់ស្តែងនៃចំណែកមត៌ករបស់សហសន្តតិជន ដើម្បីឲ្យសមស្របទៅនឹងករណីមានអ្នកទទួលផលប្រយោជន៍ពិសេសផ្សេងៗ ដោយតម្រូវឲ្យសងមកវិញនូវចំណែកទាំងនោះ ។

នៅក្នុងផ្នែកនៃចំណុចនេះ យើងនឹងបកស្រាយអំពី ការទទួលបានផលប្រយោជន៍ពិសេស ភាគនៃវិភាគទាន និងប្រទានកម្ម។

### ២.៣.១ ផលប្រយោជន៍ពិសេស

នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិថា នៅក្នុងចំណោមសហសន្តតិជនទាំងអស់ បើមានបុគ្គលណាដែលទទួលបានប្រទានកម្មនៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬ ស្ថានការណ៍ផ្សេងទៀត ឬដើម្បីមូលធននៃជីវភាពរស់នៅ ឬដែលបានទទួលអច្ច័យទានពីមតកជននោះ ។

នៅក្នុងចំណោមសហសន្តតិជនណាម្នាក់ បុគ្គលទទួលបានផលប្រយោជន៍ពិសេសនោះ នៅពេលបើកសន្តតិកម្ម តម្លៃសរុបនៃមត៌កនៃមតកជនមាន គឺ

- ត្រូវបូកបញ្ចូលនូវតម្លៃនៃប្រទានកម្មហើយចំនួនទឹកប្រាក់ដែលនៅសេសសល់ក្រោយពីការដកតម្លៃនៃប្រទានកម្ម ឬអច្ច័យទាននោះចេញ គឺជាចំណែកមត៌ករបស់បុគ្គលនោះ។

ដូច្នេះ យើងអាចកំណត់បានរូបមន្ត ៖

| |
|---|
| ទ្រព្យដែលចាត់ទុកជាមត៌ក = ប្រទានកម្ម + អច្ច័យទាន + តម្លៃសរុបនៃមត៌កពេលចាប់ផ្តើម |

#### ២.៣.១.១ ផលប្រយោជន៍ពិសេសមានតម្លៃតិចជាងចំណែកមត៌ក

បើផលប្រយោជន៍ពិសេសដែលសន្តតិជនណាម្នាក់ទទួលបានពីមតកជន មិនគ្រប់ចំនួនចំណែកមត៌កត្រូវទទួលបាន ។ នៅពេលចាប់ផ្តើមសន្តតិកម្ម នោះសន្តតិជននៅតែមានសិទ្ធិក្នុងការទទួលចំណែកមត៌ក ដែលនឹងត្រូវទទួលបានចំណែកមត៌កបន្ថែមទៀត ដើម្បីបង្គ្រប់ចំនួនចំណែកមត៌ករបស់សន្តតិជននោះ។

**ឧទាហរណ៍១** មតកជនមានកូនចំនួន៣ នាក់ គឺ ក ខ និងគ ដែលមតកជនបានបន្សល់ទុកមត៌កចំនួន ៣.០០០ ដុល្លាអាមេរិក ។ នៅពេលមតកជននៅរស់ គាត់បានផ្តល់ផលប្រយោជន៍ពិសេសទៅសន្តតិជន ខ នៅឱកាសអាពាហ៍ពិពាហ៍ ចំនួន ៦០០ ដុល្លាអាមេរិច។

ដោយយោងតាមមាត្រា ១១៦៣នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ទ្រព្យដែលចាត់ទុកជាមត៌ក = ទ្រព្យសម្បត្តិនាពេលចាប់ផ្តើមសន្តតិកម្ម($៣.០០០) + ផលប្រយោជន៍ពិសេស ($៦០០) = $៣.៦០០

នាំឲ្យ ចំណែកមត៌ករបស់សន្តតិជនទាំង ៣ ម្នាក់ៗ ទទួលបាន $១.២០០

ចំណែក ចំណែកមត៌ក ខ = $១.២០០ - $៦០០ =$៦០០ ដើម្បីបង្គ្រប់ចំណែកមត៌កដែល ខ ត្រូវទទួលបាន ។

ដូច្នេះ ចំណែកមត៌ក ក និង គ ទទួលបានស្មើៗគ្នាចំនួន $១.២០០ និង ចំណែកមត៌ក ខ ទទួលបាន $៦០០

### ២.៣.១.២ ផលប្រយោជន៍ពិសេសមានតម្លៃស្មើនឹងចំណែកមត៌ក

បើតម្លៃប្រទានកម្ម ឬ អច្ច័យទានស្មើគ្នានឹងតម្លៃនៃចំណែកមត៌កសហសន្តតិជននោះពុំអាចទទួលយកចំណែកមត៌កនោះបានឡើយ។[60]

**ឧទាហរណ៍១** មតកជន ក មានកូនចំនួន៤ នាក់ គឺ X, Y, Z, P,ដែល ក បានបន្សល់ទុកមត៌កចំនួន ៥.៥០០ ដុល្លារអាមេរិក ។ នៅពេលលោក ក នៅរស់គាត់បានផ្តល់ផលប្រយោជន៍ពិសេសទៅសន្តតិជន X នៅឱកាសអាពាហ៍ពិពាហ៍ទទួលបានផលប្រយោជន៍ពិសេសចំនួន $២.០០០ និង Y បានផលប្រយោជន៍ពិសេស ចំនួន $៥០០ ។

ដោយយោងតាមមាត្រា ១១៦៣នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ទ្រព្យដែលចាត់ទុកជាមត៌ក = ទ្រព្យសម្បត្តិនាពេលចាប់ផ្តើមសន្តតិកម្ម($៥.៥០០) + ផលប្រយោជន៍ពិសេសរបស់ ($៥០០) + ផលប្រយោជន៍ពិសេសរបស់ X ($២.០០០) = $៨.០០០

⇒ សន្តតិជនទាំង៤នាក់ទទួលបានចំណែក១/៤នៃមត៌កទាំងអស់ =

$\frac{៨.០០០}{៤}$=$២.០០០

ដូច្នេះ ចំណែកមត៌កសន្តតិជន Z, P បានទទួលបានចំនួន $២.០០០ស្មើៗគ្នា

- Y ទទួលបន្តផលប្រយោជន៍ពិសេសចំនួន$៥០០

  នោះ ចំណែកមត៌ក Y =$២.០០០– $៥០០ = $១.៥០០

[60] មាត្រា ១១៦៣ , ចំណុចទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

- X ទទួលបានផលប្រយោជន៍ពិសេសចំនួន $២.000 នោះចំណែកមត៌ក X=$២.000 – $២.000=00 គឺមិនអាចទទួលយកបានទេ។

### ២.៣.១.៣ ផលប្រយោជន៍ពិសេសមានតម្លៃលើសពីចំណែកមត៌ក

ទោះបីជាតម្លៃនៃផលប្រយោជន៍ពិសេសរួមមានដូចជាប្រទាន ឬ អច្ច័យទានដែលសហសន្តតិជនបានទទួលមានចំនួនលើសពីតម្លៃនៃចំណែកមត៌កក៏ដោយ សហសន្តតិជននោះពុំចាំបាច់បង្វិលមកវិញនូវទ្រព្យសម្បត្តិដែលទាក់ទងនឹងប្រទានកម្មដើម្បីសហសន្តតិជនផ្សេងទៀតឡើយ លើកលែងតែត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាពបម្រុង។[61]

ករណីដែលមិនចាំបាច់ឲ្យបង្វិលនូវភាគលើសវិញទេ តម្លៃនៃចំណែកមត៌កជាក់ស្តែងរបស់សហសន្តតិជនផ្សេងទៀតនៅពេលចាប់ផ្តើមសន្តតិកម្ម ត្រូវធ្វើការគណនានូវតម្លៃនៃចំណែកមត៌ករបស់មតកជនមានជាក់ស្តែងតាមភាគចំណែករបស់សន្តតិជនម្នាក់ៗត្រូវទទួលបាន។[62]

រូបមន្ត ចំណែកមត៌កជាក់ស្តែងដែលសន្តតិជនត្រូវទទួលបាន =

$$\frac{\text{តម្លៃនៃទ្រព្យសម្បត្តិមតកជនពេលចាប់ផ្តើមសន្តតិកម្ម}}{\text{តម្លៃសរុបនៃចំណែកមត៌កសន្តតិជន}} \times \text{ចំណែកមត៌ករបស់សន្តតិជន}$$

**ឧទាហរណ៍** មតកជន ក មានកូនចំនួន ៣ នាក់ A , B, C បានបន្សល់ទុកមត៌កចំនួន$១.000 ប៉ុន្តែ កាល ក មានជីវិត បានផ្តល់ផលប្រយោជន៍ពិសេសទៅ B $១.000 និង C $៤00 ។

យោងតាមមាត្រា ១១៦៣ ទ្រព្យចាប់ផ្តើមសន្តតិកម្ម = $១.000 + $១.000 + $៤00 = $២.៤00

សន្តតិជនម្នាក់ៗទទួលបានចំណែកមត៌កស្មើៗគ្នា ចំនួន $៨00

ប៉ុន្តែ B បានផលប្រយោជន៍ពិសេស $១.000 > លើសពីចំណែកមត៌កត្រូវទទួលបាន $៨00(–$២00)

ដូច្នេះ មិនអាចទទួលយកបានទេ តែមិនចាំបាច់បង្វិលសងវិញទេ ព្រោះគោរពតាមឆន្ទៈ មតកជន ក ។

ហើយ C បានផលប្រយោជន៍ពិសេស $៤00 < ចំណែកមត៌កត្រូវបាន ដូច្នេះ C ត្រូវបាន $៤00 បន្ថែមទៀត។

ដោយហេតុថាមត៌កសរុបរបស់សន្តតិជននីមួយៗមានចំនួន($៨00+ $៤00 = $១២00)ដែលលើសចំនួនមត៌កសរុបនាពេលចាប់ផ្តើមសន្តតិកម្ម មានតែ $១.000 ដូច្នេះ A និង C ត្រូវទទួលបានចំណែកមត៌កតាមសមាមាត្រ $\frac{\$៤00}{\$៨00}$ នៃ $១.000 រវាង A និង C ។

---

[61] មាត្រា ១១៦៥ , ចំណុចទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២00៧

[62] មាត្រា ១១៦៥ , សេចក្តីកំណត់មាត្រានីមួយៗក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២00៧,គន្លឹ៨និង៩, ទំព័រ ២៦

តម្លៃសរុបនៃចំណែកមត៌ក(សហ)សន្តតិជន= $១២០០

នាំឲ្យ ចំណែកមត៌កជាក់ស្តែង A = $\frac{៨០០}{១.២០០}$×$១.០០០ = $៦៦៦.៦៦ និង

ចំណែកមត៌កជាក់ស្តែង C =$១.០០០ – ៦៦៦.៦៦= $៣៣៣.៣៣

### ២.៣.២ ករណីមានប្រទានកម្ម

កិច្ចសន្យាដែលភាគីម្ខាងជាអ្នកទទួល (បដិគ្គាហក) បានទទួលនូវទ្រព្យសម្បត្តិពីអ្នកឲ្យ( ទាយក) ដោយពុំគិតថ្លៃ ហៅថា ប្រទានកម្ម។[63] ក្នុងករណីដែល បដិគ្គាហក ឬ អ្នកដែលទទួលផលប្រយោជន៍ពិសេស បានចាត់ចែងទ្រព្យសម្បត្តិ ដែលបានទទួលដោយប្រទានកម្មមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ ក្នុងករណីដែលទ្រព្យនោះបានបាត់បង់ វិនាសមុនពេលចាប់ផ្តើមសន្តតិកម្ម ជាអាទិ៍ នោះវិធីក្នុងកាគណនាតម្លៃនៃប្រទានកម្ម ត្រូវគណនាទៅតាមតម្លៃនៅពេលចាត់ចែង ឬនៅពេលដែលបានបាត់បង់ ឬ វិនាសនោះ ។ ប្រសិនបើតម្លៃកម្មវត្ថុនៃប្រទានកម្ម ឬ តម្លៃវត្ថុមានការផ្លាស់ប្តូរដោយសារសកម្មភាពផ្សេងៗរបស់បដិគ្គាហក ឬ អ្នកទទួលផលប្រយោជន៍ពិសេសនោះ តម្លៃកម្មវត្ថុនៃប្រទានកម្ម ឬ តម្លៃវត្ថុត្រូវគណនាដោយគិតក្នុងពេលចាប់ផ្តើមសន្តតិកម្មនោះ។ ការប្រាក់និងផលចំណេញដែលកើតចេញពីប្រទានកម្មដែលសន្តតិជននោះបានទទួលពុំត្រូវបានគណនាចូលក្នុងតម្លៃនោះឡើយ។[64]

ចំពោះ តម្លៃផលប្រយោជន៍ពិសេស មានការកើនឡើង គឺ តម្រូវយកតម្លៃថ្ងៃធ្វើប្រទានកម្មមកធ្វើការគណនា បើតម្លៃផលប្រយោជន៍ពិសេសមានការធ្លាក់ចុះ គឺ តម្រូវយកតម្លៃនៅថ្ងៃបើកសន្តតិកម្មមកធ្វើការគណនា។

**ឧទាហរណ៍** មុនពេលមរណភាព លោក ក គាត់បានឲ្យដី ទៅកូន ក មួយកន្លែងមានតម្លៃ $១០០.០០០ ។ យោងតាមមាត្រា ១១៦៤ នៃក្រមរដ្ឋប្បវេណី នៅពេលចាប់ផ្តើមសន្តតិកម្ម៖

- បើតម្លៃដីកើនឡើងត្រូវធ្វើការគណនាតម្លៃដីជាប្រទានកម្មតាមតម្លៃដើមដែលមតកជន ក បានឲ្យ។
- បើតម្លៃដីធ្លាក់ចុះ ត្រូវធ្វើការគណនាតម្លៃដីជាប្រទានកម្មតាមតម្លៃជាក់ស្តែងនៃថ្ងៃបើកសន្តតិកម្ម។

[63] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧,សទ្ទានុក្រមផ្នែករដ្ឋប្បវេណី,ទំព័រ ១៤

[64] មាត្រា ១១៦៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ២.៣.២ ករណីវិភាគទាន

បើមានបុគ្គលណាម្នាក់បានធ្វើវិភាគទានពិសេសដើម្បីថែរក្សាឬបង្កើនទ្រព្យសម្បត្តិរបស់មតកជន ដោយការផ្តល់សេវាកម្មលើកិច្ចការរបស់មតកជន ឬ ដោយការផ្តល់តាវកាលិកលើទ្រព្យសម្បត្តិ ឬ ដោយការថែទាំព្យាបាលមតកជន ឬដោយវិធីផ្សេងទៀត ។[65]

នោះ បើសន្តតិជនណាម្នាក់បានធ្វើវិភាគទានពិសេសតម្លៃមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ដោយដកនឹងវិភាគទានត្រូវចាត់ទុកជាមត៌ក ។

| |
|---|
| រូបមន្ត មត៌កជាក់ស្តែង(១) = មត៌កចាប់ផ្តើមសន្តតិកម្ម – ភាគនៃវិភាគទាន |

ហើយចំនួនទឹកប្រាក់នៃចំណែកមត៌កដែលបានគណនាតាមបញ្ញត្តិនៃផ្នែកទី១ (សន្តតិជន) និងផ្នែកទី២ (សន្តតិកម្មរបស់សហព័ទ្ធ) បូកនឹងវិភាគទាន ត្រូវជាចំណែកមត៌ករបស់ជន ដែលបានធ្វើវិភាគទាននោះ។[66]

| |
|---|
| រូបមន្ត ចំណែកមត៌កនៃអ្នកធ្វើវិភាគទាន = $\frac{\text{មត៌កជាក់ស្តែង(១)}}{\text{ចំនួនសន្តតិជន}}$+ភាគនៃវិភាគទាន |
| ឬ រូបមន្ត ចំណែកមត៌កនៃអ្នកធ្វើវិភាគទាន = $\frac{\text{មត៌កចាប់ផ្តើមសន្តតិកម្ម– ភាគនៃវិភាគទាន}}{\text{ចំនួនសន្តតិជន}}$+ភាគនៃវិភាគទាន |

**ឧទាហរណ៍** មតកជន ក មានកូនចំនួន ៣នាក់ X, Y, Z នៅពេលមតកជន ក នៅរស់ បានផ្តល់អំណោយឲ្យទៅ X ចំនួន $៥.000 និង Y បានចេញព្យាបាលជំងឺ មតកជន ក ចំនួន $១0.000។ នៅពេលចាប់ផ្តើមសន្តតិកម្មបានបន្សល់ទុក មត៌កចំនួន $២៣.000។

មត៌កសរុប= $២៣.000+ $៥.000 - $១0.000 = $១៨.000

ចំណែកមត៌ករបស់ X = ($១៨.000 ÷ ៣) - $៥.000= $១.000

ចំណែកមត៌ករបស់ Y = ($១៨.000 ÷ ៣) + $១0.000= $១៦.000

ចំណែកមត៌ករបស់ Z = $១៨.000 ÷ ៣ =$៨.000

[65] មាត្រា ១១៦៦, កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២00៧

[66] មាត្រា ១១៦៦, កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២00៧

## ២.៤ ភាគបម្រុង

ភាគបម្រុង គឺជា ចំណែកមួយដែលត្រូវបម្រុងទុកឱ្យអ្នកដែលមានសិទ្ធិលើភាគបម្រុងតាមច្បាប់កំណត់។ ភាគបម្រុង គឺជាចំណែកបម្រុងទុកដែលត្រូវរាប់បញ្ចូលទាំងមត៌ក និងទ្រព្យសម្បត្តិមួយចំនួនដែលមានមុនពេលមរណភាពរបស់មតកជន ដូចជាប្រទានកម្ម និងតម្លៃនៃផលប្រយោជន៍ពិសេស ដោយហេតុថា ប្រសិនបើទ្រព្យសម្បត្តិដែលជាមូលដ្ឋានសម្រាប់គណនាភាគបម្រុងនេះត្រូវបានកំណត់ត្រឹមមត៌ក នោះអាចមានករណីមួយចំនួន ដែលមតកជនគាត់អាចចាត់ចែងទ្រព្យសម្បត្តិបានតាមរយៈប្រទានកម្មជាដើម ដែលអាចធ្វើឱ្យប៉ះពាល់ដល់ចំណែករបស់សន្តតិជន។

### ២.៤.១ សញ្ញាណទូទៅនៃភាគបម្រុង

របបនៃភាគបម្រុងនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ គឺជាការធានានៃចំណែកមត៌កដែលកំណត់ជាក់លាក់ដោយច្បាប់ចំពោះជនទាំងឡាយណាដែលជាសន្តតិជន ដោយមូលហេតុថា ទោះបីជាមតកជនមានសិទ្ធិសេរីភាពក្នុងការធ្វើមតកសាសន៍ក៏មិនអាចធ្វើបំពានទៅលើសន្តតិជនបានដែល ដោយច្បាប់បានទទួលស្គាល់អោយសន្តតិជនធ្វើការបដិសេធនូវសេរីភាពក្នុងការធ្វើមតកសាសន៍នេះ ពេលសន្តតិជននោះទទួលរងការរំលោភបំពានសិទ្ធិលើភាគបម្រុងរបស់ខ្លួន។

របបនៃភាគបម្រុងមានតួនាទីក្នុងការសម្របសម្រួលសន្តតិកម្មតាមច្បាប់និងសន្តតិកម្មតាមមតកសាសន៍និងការធានាកុំអោយមាននូវការបំពានទៅលើចំណែកមត៌ក។ មូលហេតុផ្សេងៗដែលអាចអោយខ្លាចជាការបំពានលើភាគបម្រុងនោះគឺករណីមានអច្ច័យទាន ឬ ប្រទានកម្មកំណត់មួយចំនួនពេលមតកជននៅរស់ ឬការទទួលបានផលប្រយោជន៍ពិសេស ឬការកំណត់ចំណែកមត៌កតាមមតកសាសន៍។

#### ២.៤.១.១.អ្នកដែលមានសិទ្ធិលើភាគបម្រុង

ក្រមរដ្ឋប្បវេណីកម្ពុជាបានកំណត់យកជនមួយចំនួនដែលជាប់ទំនាក់ទំនងញាតិយ៉ាងជិតស្និទ្ធិជាមួយនិងមតកជនជាអ្នកមានសិទ្ធិលើភាគបម្រុង។

អ្នកដែលមានសិទ្ធិលើភាគបម្រុងរួមមាន៖ បច្ឆាញាតិផ្ទាល់ ឬ ឪពុកម្តាយ ឬជីដូនជីតានិងសហព័ទ្ធរបស់មតកជន។ មានន័យថាអ្នកដែលត្រូវបានកំណត់ទុកថានឹងក្លាយជាសន្តតិជនផ្អែកតាមបញ្ញត្តិនៃចំណែកមត៌កដែលច្បាប់បានកំណត់ នឹងក្លាយជាអ្នកមានសិទ្ធលើភាគបម្រុង ។

ចំពោះសន្តតិជនដែលបានរៀបរាប់ខាងលើរួមទាំងសន្តតិជនជំនួសរបស់បច្ឆាញាតិផ្ទាល់ក៏ជាបុគ្គលដែលមានសិទ្ធិលើភាគបម្រុងនេះដែរ។[67]

[67] មាត្រា១២៣០ , កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ប៉ុន្តែ សន្តតិជនបងប្អូនបង្កើត និងសន្តតិជនជំនួសរបស់បងប្អូនបង្កើត(ក្មួយរបស់មតកជន)មិនអាចក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុងបានទេ ទោះបីជាត្រូវបានកំណត់ទុកថានឹងក្លាយជាសន្និជនក៏ដោយ។

### ១.៤.១.២ ការកំណត់អំពីចំណែកនៃភាគបម្រុង

យោងតាមមាត្រា១២៣០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ចំណែកនៃភាគបម្រុងត្រូវបានកំណត់ដូចខាងក្រោមៈ

- ១ភាគ៣ (មួយភាគបី) នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីដែលមានតែសន្តតិជនជាឪពុកម្តាយ ឬជីដូនជីតា ប៉ុណ្ណោះ (មិនមានកូន និងមិនមានសហព័ទ្ធ) ភាគបម្រុង គឺត្រូវមាន ១ភាគ៣ នៃទ្រព្យសម្បត្តិរបស់មតកជន។
- ១ភាគ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីផ្សេង។ មានន័យថា សន្តតិជនជាបច្ឆាញាតិឬសហព័ទ្ធជាសន្តិជន នោះភាគបម្រុងត្រូវមានពាក់កណ្តាល នៃទ្រព្យសម្បត្តិរបស់មតកជន។

ក្នុងករណីពិសេស អ្នកដែលមានសិទ្ធិលើភាគបម្រុងច្រើននាក់ត្រូវធ្វើការបែងចែកមត៌កដែលចាត់ទុកជាភាគបម្រុងនោះទៅតាមសមាមាត្រនៃចំណែកភាគបម្រុង។

### ២.៤.២ វិធីកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

អ្នកមានសិទ្ធិលើភាគបម្រុង និងអ្នកទទួលបន្តសិទ្ធិ(ប្រតិសិទ្ធ) អាចទាមទារអោយធ្វើការកាត់បន្ថយអច្ច័យទានដែលទទួលបានទ្រព្យសម្បត្តិ ឬផលប្រយោជន៍ពិសេស ដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់បានត្រឹមកម្រិតដែលចាំបាច់ ដើម្បីរក្សាភាគបម្រុងនោះ។[68]

សិទ្ធិទាមទារឲ្យកាត់បន្ថយបង្គ្រប់ភាគបម្រុង គឺជា "សិទ្ធិបង្កើតទំនាក់ទំនងគតិយុត្ត"ដូច្នេះអច្ច័យទាន ឬប្រទានកម្ម ត្រូវបាត់បង់អានុភាពដោយស្វ័យប្រវត្តិដែលបានបំពានភាគបម្រុងនោះក្នុងករណីដែលអ្នកមានសិទ្ធិបានអនុវត្តសិទ្ធិរបស់ខ្លួន។ការកំណត់បែបនេះគឺដើម្បីទុកសិទ្ធិដល់ជនដែលត្រូវបានបំពានភាគបម្រុងអាចយកសិទ្ធិ ដែលជាកម្មវត្ថុនៃការកាត់បន្ថយនោះមកធ្វើជារបស់ខ្លួនបានដោយធ្វើការទាមទារឲ្យកាត់បន្ថយអច្ច័យទាន។

ទោះបីយ៉ាងណាក៏ដោយ ក៏ច្បាប់មិនបានចាប់បង្ខំដែរ ប្រសិនបើអ្នកមានសិទ្ធិលើភាគបម្រុងមិនធ្វើការទាមទារសិទ្ធិនោះទេ មតកសាសន៍នោះនិងមានសុពលភាពពេញលេញ។

[68] មាត្រា១២៣៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ការទាមទារ គឺធ្វើត្រឹមតែការបង្ហាញឆន្ទៈជាការគ្រប់គ្រាន់ហើយ លើកលែងតែពុំមានការយល់ព្រមពីភាគីម្ខាងទៀត នោះអ្នកត្រូវបានបំពានសិទ្ធិអាចដាក់ពាក្យបណ្ដឹងទៅតុលាការ។

### ២.៤.២.១ ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

ភាគបម្រុង គឺជាចំណែកសមាមាត្រនៃមត៌កដែលមាន។ បើមូលដ្ឋាននៃទ្រព្យសម្បត្តិសម្រាប់ការគណនាភាគបម្រុងនេះត្រូវបានកម្រិតត្រឹមតែមត៌កនោះអាចមានករណីមតកជនធ្វើប្រទានកម្មទ្រព្យសម្បត្តិយ៉ាងច្រើនមុនពេលស្លាប់ ដើម្បីជៀសវាងប្រព័ន្ធនៃភាគបម្រុងនេះបាន។ ហេតុនេះហើយ ការគណនាភាគបម្រុងត្រូវបញ្ចូលនូវទ្រព្យសម្បត្តិមួយចំនួន ដែលមានមុនពេលមតកជន ដូចជាប្រទានកម្ម និងតម្លៃនៃផលប្រយោជន៍ពិសេសជាដើម។

ការគណនាភាគបម្រុងត្រូវបានគណនា ដោយយកទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ផ្ដើមសន្តតិកម្ម បូកតម្លៃនៃផលប្រយោជន៍ពិសេស និងតម្លៃនៃទ្រព្យសម្បត្តិប្រទានកម្ម ហើយដកចំនួនប្រាក់សរុបនៃបំណុល (កាតព្វកិច្ច)ចេញ ។[69]

| |
|---|
| ទ្រព្យជាមូលដ្ឋានក្នុងការគណនាភាគបម្រុង = ទ្រព្យពេលចាប់ផ្ដើមសន្តតិកម្ម + តម្លៃនៃផលប្រយោជន៍ពិសេស + តម្លៃនៃប្រទានកម្ម - ចំនួនសរុបនៃកាតព្វកិច្ច |

#### ក. ប្រទានកម្មដែលជាមូលដ្ឋាននៃគណនាភាគបម្រុង

គឺជាកិច្ចសន្យាដែលភាគីម្ខាងបង្ហាញឆន្ទៈផ្ដល់អោយភាគីម្ខាងទៀតនៃទ្រព្យសម្បត្តិដោយមិនយកថ្លៃ ហើយភាគីម្ខាងយល់ព្រមទទួល។

ប្រទានកម្មដែលត្រូវយកមកគណនាភាគបម្រុងត្រូវអនុលោមតាមមាត្រា ១២៣២ ក្រមរដ្ឋប្បវេណី គឺជាប្រទានកម្មដែលធ្វើឡើងក្នុងអំឡុងពេល១ឆ្នាំមុនពេលចាប់ផ្ដើមសន្តតិកម្ម។[70] ហេតុដែលបានចែងបែបនេះ ដើម្បីការពារកុំឲ្យមានការបំពានមិនត្រឹមត្រូវដល់ផលប្រយោជន៍របស់អច្ឆ័យលាភី និងដើម្បីឲ្យមានសុវត្ថិភាពក្នុងកិច្ចការជំនួញ។[71] ប្រទានកម្មដែលបានធ្វើឡើងដោយភាគីសងខាង ដោយបានដឹងថានឹងមានការប៉ះពាល់ដល់ផលប្រយោជន៍របស់អ្នកមានសិទ្ធិលើភាគបម្រុង។[72] អំពើនៃការបំពាននេះមិនត្រូវបានកំណត់អំឡុងពេលនោះទេ ហើយដើម្បីអាចដឹងថាមានការបំពានឬមិនបំពានគឺត្រូវយកទ្រព្យសម្បត្តិសរុបរបស់មតកជនពេលធ្វើប្រទាន

[69] មាត្រា១២៣១,កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[70] មាត្រា១២៣២,កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[71] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ , គន្លឹះទី៨ ទី៩,ទំព័រ ៩២

[72] មាត្រា១២៣២,កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

កម្ម និងតម្លៃទ្រព្យសម្បត្តិដែលធ្វើប្រទានកម្មមកធ្វើការប្រៀបធៀបគ្នា។[73] មួយវិញទៀត កាតព្វកិច្ចដែលមិនយកតម្លៃវិញត្រូវចាត់ទុកជាប្រទានកម្ម។[74]

**ឧទាហរណ៍៖** លោក A បានឲ្យក្មួយស្រីនូវទូរសព្ទមួយគ្រឿងតម្លៃ $៥០០ ជាការលើកទឹកចិត្តដល់នាងពេលដែលប្រលងជាប់សញ្ញាបត្របឋមភូមិ។ ទូរសព្ទតម្លៃ $ ៥០០គឺជាប្រទានកម្ម។

### ខ. ទ្រព្យដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

កម្មវត្ថុនៃការកាត់បន្ថយភាគបម្រុងគឺ អច្ច័យទាន ការកំណត់ចំណែកមត៌កតាមមតកសាសន៍ ការទទួលបានផលប្រយោជន៍ពិសេសនិងប្រទានកម្មដែលបានកំណត់ក្នុងមាត្រា១២៣២(ប្រទានកម្មដែលជាមូលដ្ឋានក្នុងគណនាភាគបម្រុង)។[75] ទ្រព្យសម្បត្តិជាកម្មវត្ថុនៃការកាត់បន្ថយភាគបម្រុង ដែលជាអច្ច័យទានរបស់សន្តតិជន ការកំណត់ចំណែកមត៌កនិងកាទទួលផលប្រយោជន៍ពិសេសនោះ ប្រសិនបើសន្តតិជនដែលត្រូវបានគេកាត់បន្ថយនោះត្រូវបានបំពានភាគបម្រុងរបស់ខ្លួននោះអាចបដិសេធការទាមទារនេះបាន។

កាលណាអ្នកមានសិទ្ធលើភាគបម្រុង យល់ឃើញថាមានការបំពានណាមួយចំពោះសិទ្ធិរបស់ខ្លួន និងមានការទាមទារអោយមានការគណនាភាគបម្រុង ប៉ុន្តែបើគ្រាន់តែគណនាភាគបម្រុងនោះយើងមិនអាចដឹងបានថាតើមានការបំពានភាគបម្រុងសំណាក់សន្តតិជនដទៃទៀតនោះទេ ហើយមិនអាចដឹងថា តើអ្នកមានសិទ្ធិបំពានលើភាគបម្រុងអាចទាមទារទឹកប្រាក់ចំនួនប៉ុណ្ណានោះដែរ។ ដូច្នេះចាំបាច់ណាស់យើងត្រូវធ្វើការគណនាចំនួនទឹកប្រាក់ដែលត្រូវកាត់បន្ថយបង្គ្រប់ភាគបម្រុង។

### គ. ចំនួនទឹកប្រាក់នៃការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

ចំនួនទឹកប្រាក់នៃការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់នៃភាគបម្រុងគឺជាចំនួនទឹកប្រាក់ដែលត្រូវបានគណនា ដោយយកចំនួនទឹកប្រាក់នៃភាគបម្រុង ដកចំនួនសរុបនៃទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិលើភាគបម្រុងទទួលបានដោយសន្តតិកម្ម និងចំនួននៃផលប្រយោជន៍ពិសេសហើយបូកបញ្ចូលចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលបុគ្គលនោះត្រូវទទួលខុសត្រូវដោយសន្តតិកម្ម។[76]

---

[73] មាត្រា១២៣២,កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[74] មាត្រា១២៣២,កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[75] មាត្រា១២៣៣នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[76] មាត្រា១២៣៤ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ២.៤.២.២ លំដាប់នៃការកាត់បន្ថយ

ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយភាគបម្រុងទាំងនោះរួមមាន អច្ច័យទាន ការកំណត់ចំណែកមត៌កសាសន៍ ការទទួលផលប្រយោជន៍ពិសេស និងប្រទានកម្ម។[77] ការកំណត់បែបនេះគឺដោយសារគោលគំនិតនៃរបបភាគបម្រុង គឺធានាទុកនូវមត៌កមួយភាគសម្រាប់ឲ្យជនដែលមានសិទ្ធិលើភាគបម្រុង ប៉ុន្តែប្រសិនបើកម្រិតនៃកម្មវត្ថុនៃការកាត់បន្ថយត្រឹមតែមត៌កអាចទៅជាបំពានភាគបម្រុងវិញ ដោយសារការធ្វើប្រទាកម្មរបស់មតកជនពេលនៅរស់។

ដូចនេះហើយធ្វើអោយប្រទានកម្មក៏ក្លាយជាកម្មវត្ថុនៃការកាត់បន្ថយគឺដើម្បីអោយមានសមភាពគ្នារវាងសហសន្តតិជន។ ផ្ទុយទៅវិញប្រសិនបើនៅពេលចាប់ផ្តើមសន្តតិកម្ម ដោយមត៌កមានគ្រប់គ្រាន់សម្រាប់បង្គ្រប់ភាគបម្រុងនោះ គឺ មិនចាំបាច់ពិចារណាក្នុងការចាត់ចែងសកម្មភាពរបស់មតកជន ដូចជាប្រទានកម្មមកបង្គ្រប់ភាគបម្រុងនោះទេ។

**ក. លំដាប់នៃការកាត់បន្ថយដោយប្រទានកម្ម**

ក្នុងករណីដែលមតកជនបានធ្វើប្រទានកម្មនូវទ្រព្យជាច្រើន ទៅអោយជនដែលត្រូវបានសន្មតថា ជាសន្តតិជនជាអាទិ៍ ពេលដែលជននោះនៅរស់ ការកាត់បន្ថយប្រទានកម្ម ឬ ផលប្រយោជន៍ពិសេសត្រូវធ្វើចំពោះប្រទានកម្ម ឬ ផលប្រយោជន៍ពិសេសត្រូវចាប់ផ្តើមពីប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលធ្វើនៅក្រោយគេ។ ប៉ុន្តែ បើជនដែលត្រូវបានធ្វើការកាត់បន្ថយជាសន្តតិជនហើយសាមីខ្លួនត្រូវបានបំពានដោយសារការកាត់បន្ថយនេះនោះការកាត់បន្ថយត្រូវធ្វើឡើងដោយដកនូវភាគបម្រុងរបស់សន្តិជនេះតែប៉ុណ្ណោះ។[78]

**ឧទាហរណ៍** មតកជនមានសន្តតិជនជា សហព័ទ្ធ ក និងកូន ខ និង គ ។ មុនពេលទទួលមរណភាព ៣ ឆ្នាំមតកជនបានធ្វើប្រទានកម្មឲ្យ ខ ចំនួន ២.២០០ដុល្លារ សម្រាប់រកស៊ី និងកន្លះឆ្នាំមុនទទួលមរណភាពបានធ្វើប្រទានកម្មឲ្យ ក ចំនួន ៦០០ដុល្លារ ។ ហើយមត៌កសល់តែ ២០០ដុល្លារតែប៉ុណ្ណោះ។ ទោះបីជា គ ត្រូវទទួលបានមត៌កទាំងអស់ ក៏នៅតែត្រូវបំពានភាគបម្រុងរបស់ខ្លួន ៣០០ដុល្លារទៀត។ ហេតុនេះ គ នឹងទាមទារពី ក ដែលបានទទួលប្រទានកម្មចំនួន ៦០០ដុល្លារ ដើម្បីបង្គ្រប់ភាគបម្រុង។ តែកាត់បន្ថយអាចបានតែ ១០០ដុល្លារទេ ដោយដកពីភាគបម្រុងរបស់ ក ដោយហេតុថាបើកាត់លើសពីនេះនឹងបំពានដល់ចំណែករបស់ ក វិញ។ នៅសល់ ២០០ដុល្លារ ទៀតត្រូវទាមទារពី ខ ទើបបាន។

[77] មាត្រា១២៣៣,កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[78] មាត្រា១២៣៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ក្នុងករណី ដែលប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសនោះត្រូវបានធ្វើឡើងលើសពី ២០(ម្ភៃ) ឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម បដិគ្គាហក ឬ សន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេសអាច បដិសេធនូវកាត់ទាមទារកាត់បន្ថយភាគបម្រុងបាន។[79] ក្នុងនោះដែលគោលគំនិតនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិ ដែលវាជាការបន្ថែមចំនួនឆ្នាំដោយគិតថាបើយកកំឡុងពេល ១០(ដប់)ឆ្នាំ ដែលគោលគំនិតនៃរំលត់សិទ្ធិគឺ អាចមានរយៈខ្លីពេក។

**ខ. ការកាត់បន្ថយដោយប្រទានកម្មភ្ជាប់បន្ទុក**

ចំពោះប្រទានកម្មដែលមានភ្ជាប់បន្ទុក តម្លៃនៃកម្មវត្ថុដកចេញនូវតម្លៃនៃបន្ទុក ជាកម្មវត្ថុនៃការធ្វើការ កាត់បន្ថយបានដើម្បីបង្គ្រប់ភាគបម្រុង។[80]

**ឧទាហរណ៍** នៅពេលនៅរស់មតកជន បានធ្វើប្រទានកម្មជាប្រាក់ចំនួន ៤.០០០ដុល្លារដល់ ក ដើម្បីឲ្យ ក ជួយ ផ្គត់ផ្គង់ ថ្លៃសិក្សាដល់ ខ ចំនួន១០០ ដុល្លារ ក្នុងមួយខែ រយៈពេលមួយឆ្នាំ។ ក្នុងករណីនេះប្រសិនប្រទានកម្ម ដែលមានភ្ជាប់បន្ទុក ក្លាយជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនោះ ត្រូវដកនូវបន្ទុកចេញ ដោយ ៤.០០០-(១០០x១២) =២.៨០០ ដុល្លារ មានន័យថា ២.៨០០ នេះជាកម្មវត្ថុនៃការកាត់បន្ថយ។

**គ. ការកាត់បន្ថយចំពោះកិច្ចសន្យាជាអាទ៍ ដែលត្រូវចាត់ទុកថាជាប្រទានកម្ម**

កិច្ចសន្យាដែលបានធ្វើដោយយកតម្លៃថ្នូរមិនត្រឹមត្រូវ ត្រូវបានចាត់ទុកថាជាប្រទានកម្ម តែក្នុងករណី ដែលត្រូវបានធ្វើឡើង ដោយភាគីសងខាងបានដឹងថា នឹងបណ្តាលឲ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគីបម្រុង ប៉ុណ្ណោះ។[81] ក្នុងករណីនេះ បើអ្នកមានសិទ្ធិលើភាគបម្រុង ទាមទារឲ្យធ្វើការកាត់បន្ថយនោះ អ្នកនោះត្រូវសង តម្លៃថ្នូរនោះមកវិញ។ ការចាត់ទុកប្រភេទកិច្ចសន្យាដែលមិនយកតម្លៃត្រឹមត្រូវមកកាត់បន្ថយដោយគោលគំនិត ច្បងថារបបភាគបម្រុងគឺជារបបនៃការការពារអ្នកដែលមានសិទ្ធិលើភាគបម្រុងពីការចាត់ចែងដោយគ្មាន កម្រៃ។

**ឧទាហរណ៍** នៅពេលនៅរស់ មតកជនបានលក់របស់មួយដែលមានតម្លៃ២.០០០ដុល្លារ ក្នុងតម្លៃតែ៣០០ ដុល្លារតែប៉ុណ្ណោះ។ ប្រសិនបើភាគីសងខាងបានដឹងថាវាបានប៉ះពាល់ដល់ភាគបម្រុងរបស់សន្តតិជនកិច្ច សន្យានេះនឹងចាត់ទុកជាប្រទានកម្ម ហើយនឹងក្លាយជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។ ប៉ុន្តែ នៅពេលកាត់បន្ថយការទិញលក់នេះត្រូវសងឲ្យអ្នកទិញវិញនូវប្រាក់ ៣០០ដុល្លារដើម្បីបានជាការរក្សាសមភាព

[79] មាត្រា១២៣៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[80] មាត្រា១២៤១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[81] មាត្រា១២៤១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

រវាង ភាគី។ ការអនុវត្តនេះត្រូវយកមកចាត់ចែងដូចគ្នាចំពោះការលើកលែងកាតព្វកិច្ចដោយយកតម្លៃថ្នូរមិនត្រឹមត្រូវ។

**ឃ. ការកាត់បន្ថយក្នុងករណីដែលបានចាត់ចែងកម្មវត្ថុនៃប្រទានកម្ម**

បើសហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក ដែលត្រូវទទួលការកាត់បន្ថយបានធ្វើអនុប្បទាននូវកម្មវត្ថុនៃប្រទានកម្មទៅអោយអ្នកដទៃជននោះត្រូវសងចំនួនទឹកប្រាក់ក្នុងកម្រិតនៃតម្លៃនៅពេលដែលបានចាត់ចែងនោះ ទៅឲ្យអ្នកមានសិទ្ធិលើភាគបម្រុង។[82]

ករណីនេះ នៅពេលធ្វើអនុប្បទាននោះ ប្រសិនបើអនុប្បទានិកបានដឹងថា បណ្តាលឲ្យមានការខូចខាតដល់អ្នកដែលមានសិទ្ធិលើភាគបម្រុង នោះអ្នកមានសិទ្ធិលើភាគបម្រុង ក៏អាចទាមទារឲ្យកាត់បន្ថយ ចំពោះអនុប្បទានិកបានដែរ។

**ង. ការសងផលមកវិញ និងបន្ទុកនៃការខាតបង់ដោយអសាធនភាព**

ការខាតបង់ដែលកើតឡើងដោយសារអសាធនភាព របស់សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក ដែលត្រូវទទួលកាត់បន្ថយត្រូវធ្លាក់ជាបន្ទុករបស់អ្នកមានសិទ្ធិលើភាគបម្រុង។[83] ប្រសិនបើសហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក ដែលត្រូវកាត់បន្ថយមិនអាចសងទ្រព្យដែលបានទទួលពីមតកជនវិញបាន ឬ មិនអាចសងនូវតម្លៃនៃទ្រព្យនោះបានឡើយ។

មួយវិញទៀត ទោះជាអ្នកមានកាតព្វកិច្ចជាអ្នកអាសាធនក៏ដោយ នោះអ្នកមានសិទ្ធិលើភាគបម្រុង មិនអាចទាមទារឲ្យអ្នកមានកាតព្វកិច្ចក្នុងលំដាប់បន្ទាប់ សងនូវចំណែកដែលទាមទារមិនគ្រប់នោះទេ។

**ច. សំណងដោយបង់ថ្លៃ**

សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក អាចរួចផុតពីកាតព្វកិច្ចនៃការសងបាន ដោយបង់តម្លៃនៃចំណែកមត៌កដែលបានកំណត់ តម្លៃនៃកម្មវត្ថុនៃអច្ច័យទាន ឬ តម្លៃកម្មវត្ថុនៃប្រទានកម្ម ទៅអោយអ្នកដែលមានសិទ្ធិលើភាគបម្រុង ត្រឹមកម្រិតដែលទទួលការកាត់បន្ថយ។[84] ម្យ៉ាងវិញទៀតក្នុងករណីដែលមានកាតព្វកិច្ចបានអះអាងថានិងសងថ្លៃ ហើយបានព្រមព្រៀងគ្នាលើតម្លៃនោះក្រោយពីបានសងថ្លៃនោះហើយ សិទ្ធិទាមទារឲ្យកាត់បន្ថយរលត់ដោយស្វ័យប្រវត្តិ ហើយលើកទាមទារនោះទៅ នឹងធ្វើឲ្យខូចផលប្រយោជន៍យ៉ាងធ្ងន់ធ្ងរដល់អ្នកមានសិទ្ធិ។ នៅក្នុងសេចក្តីសម្រេចនៃសាលាក្រម ឬ សាដីកា តុលាការគួរតែបញ្ជាក់ថា បង្គាប់ឲ្យសងនូវវត្ថុ

[82] មាត្រា១២៤៣ កថាកខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[83] មាត្រា១២៤០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[84] មាត្រា១២៤៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ដោយការកាត់បន្ថយ ហើយកំណត់តម្លៃជាមុន ហើយប្រសិនបើអ្នកមានកាតព្វកិច្ចបានសង ០០ រៀល អ្នកមានកាតព្វកិច្ចនេះអាចរួចផុតពីការឲ្យសងវត្ថុនោះបាន។

មួយវិញទៀតប្រសិនបើអ្នកមានកាតព្វកិច្ចមិនបានអះអាងថា នឹងសងដោយមិនបង់តម្លៃ នោះអ្នកមានសិទ្ធិលើភាគបម្រុងមិនអាចទាមទារឲ្យសងជាប្រាក់បានទេ គឺអាចត្រឹមតែទាមទារឲ្យសងនូវវត្ថុនោះវិញតែប៉ុណ្ណោះ។ ក្នុងករណីដែលមានការទាមទារឲ្យការបន្ថយភាគបម្រុង ចំពោះអនុប្បទានិកជាអាទិ៍នោះអាចសងដោយបង់ប្រាក់បានដែរ។

### ២.៤.៣ ការរំលត់សិទ្ធទាមទារឲ្យកាត់បន្ថយ

សិទ្ធិទាមទារឲ្យកាត់បន្ថយ អំឡុងពេលរំលត់នៃអាជ្ញាយុកាល នៅក្នុងអំឡុងពេលខ្លី គឺត្រូវចែងតម្រូវទៅនឹងអំឡុងពេលអាជ្ញាយុកាលនៃការអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំអោយខូចខាតផលប្រយោជន៍ ចំណែកឯ អំឡុងពេលវែងវិញត្រូវបានចែងនឹង ៥ ឆ្នាំ ដែលជាអំឡុងពេលទាមទារ ឲ្យធ្វើបដិទានសន្តតិកម្ម។[85]

ការលុបចោលនូវអំពើដែលនាំអោយខូចខាតផលប្រយោជន៍ចាំបាច់ត្រូវអនុវត្តតាមតុលាការចំណែកឯការទាមទារអោយកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងមិនចាំបាច់អនុវត្តតាមផ្លូវតុលាការទេ។[86]

ដូច្នេះអាចអនុវត្តសិទ្ធិនេះក្នុងអំឡុងពេលដែលបានកំណត់នេះចំពោះអ្នកមានកាតព្វកិច្ចសិទ្ធិទាំងមូល ឬមួយភាគនៃកម្មវត្ថុត្រូវផ្ទេរទៅអ្នកមានសិទ្ធិដោយស្វ័យប្រវត្តិដោយមិនចាំបាច់ដាក់ពាក្យបណ្ដឹងទេ។ ប៉ុន្តែប្រសិនបើអ្នកមានកាតព្វកិច្ចមិនបានប្រគល់ ឬ សហប្រតិបត្តិការធ្វើការចុះបញ្ជីទេ ចាំបាច់ត្រូវតែដាក់ពាក្យបណ្ដឹង។

#### ២.៤.៣.១ ការបោះបង់ចោលភាគបម្រុង

ការបោះបង់នូវភាគបម្រុង អាចធ្វើបានដោយការបង្ហាញឆន្ទៈតែម្ខាង ចំពោះអ្នកមានកាតព្វកិច្ច។ ដើម្បីបោះបង់នូវភាគបម្រុងមុនពេលចាប់ផ្ដើមសន្តតិកម្ម ចាំបាច់ត្រូវមានការអនុញ្ញាតពីតុលាការ។[87] ដើម្បីកុំអោយមានការបោះបង់សិទ្ធិនេះទុកជាមុន។ តុលាការដែលទទួល ពាក្យសុំឲ្យអនុញ្ញាតនោះ ត្រូវធ្វើការវិនិច្ឆ័យដោយពិនិត្យមើលថា ការបោះបង់នោះ ជា ឆន្ទៈពិតរបស់ជនដែលមានសិទ្ធិលើភាគបម្រុង ឬទេ តើការបោះបង់នោះមានភាពសមហេតុផលដែលឬទេ តើមានតម្លៃជាថ្នូរដែរឬទេ ជាអាទិ៍។

[85] មាត្រា ១២៤៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[86] មាត្រា ៤២៨, កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[87] មាត្រា ១២៤៦ ,កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ផ្ទុយទៅវិញ ទោះបើសិទ្ធិបានបោះបង់មុនពេលចាប់ផ្តើមសន្តតិកម្មដោយទទួលការអនុញ្ញាតពីតុលាការក៏ដោយអ្នកដែលមានសិទ្ធលើភាគបម្រុងនោះអាចដាក់ពាក្យសុំឲ្យតុលាការលុបចោលការអនុញ្ញាតមុនបាន ប្រសិនស្ថានភាពមានការផ្លាស់ប្តូរក្រោយពេលបោះបង់សិទ្ធិនោះ។

**២.៤.៣.២ ករណីជាសហសន្តតិជន**

ការរលត់ដោយអាជ្ញាយុកាល នៃសិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង របស់សន្តតិជនណាម្នាក់ ឬ ការបោះបង់ភាគបម្រុងដោយសហសន្តតិជនណាម្នាក់ ពុំមានឥទ្ធិពលទៅលើភាគបម្រុងរបស់សហន្តតិជនផ្សេងទៀតទេ។[88]

នៅក្នុងចំណុចនេះ មានន័យថា ការមិនទទួលយកភាគបម្រុងរបស់សន្តតិជនណាម្នាក់ មិនអាចជះឥទ្ធិពលទៅសន្តតិជនផ្សេងទៀតទេ មានន័យថា សន្តតិជនផ្សេងក្រៅពីសន្តតិជនដែលបានដាក់ពាក្យសុំទៅតុលាការពីការបោះបង់ទទួលយកភាគបម្រុងនោះបានអានុភាពត្រឹមសន្តតិជនខ្លួនឯងតែប៉ុណ្ណោះ។

[88] មាត្រា ១២៤៦៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

# ជំពូកទី៣
# ការដោះស្រាយវិវាទបញ្ញើសន្តិកម្មតាមច្បាប់

# ជំពូកទី៣
# ការជម្រះបញ្ជីសន្តតិកម្មតាមច្បាប់

នៅក្នុងជំពូកទី៣ នេះយើងនឹងរៀបរាប់អំពីការប្រព្រឹត្តិផ្សេងៗដែលទាក់ទងនឹងការអនុវត្តសន្តតិកម្មតាមច្បាប់ ដោយក្នុងចំណុច ៣.១ និយាយអំពី “ការយល់ព្រមទទួលយកនិងការបោះបង់ចោលសន្តតិកម្ម” ចំណែកចំណុច ៣.២ “ របបគតិយុត្តនៃការគ្រប់គ្រង និង នីតិវិធីនៃការបែងចែកសន្តតិកម្មតាមច្បាប់” ។

ជាទូទៅ សន្តតិកម្មអាចជាសកម្មភាពមួយដែលធ្វើការផ្លាស់ប្តូរទំនាក់ទំនងគតិយុត្តនូវបុគ្គលដែលគ្រប់គ្រងមត៌ក នៅពេលដែលម្ចាស់មត៌កបានមរណភាព នោះមត៌កដែលបានបន្សល់នឹងផ្ទេរទៅឲ្យកូនចៅជាសាច់ញាតិស្របច្បាប់របស់មតកជននោះ ប៉ុន្តែ ជនដែលត្រូវទទួលមត៌ក ឬ ហៅថាសន្តតិជននោះមានសិទ្ធិអាទិភាពសម្រេចចិត្តក្នុងការទទួលយក ឬមិនទទួលយកនូវចំណែកមត៌ក ទៅតាមវិចារណញ្ញាណរបស់ខ្លួន ដើម្បីធានាថាជីវភាពរបស់ខ្លួនក្រោយទទួលយកសន្តតិកម្មទាំងនេះ គឺមានកាតព្វកិច្ច(បំណុល) ច្រើនជាងសិទ្ធិនិងផលប្រយោជន៍ ព្រោះក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជាទទួលយកគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិក្នុងសន្តតិកម្មកក៏ដោយចុះ។

## ៣.១ ការយល់ព្រមទទួលយកនិងការបោះបង់ចោលសន្តតិកម្ម

ចំណុចដែលយើងនឹងធ្វើការអធិប្បាយនៅក្នុងផ្នែកនេះ ៣.១.១ “ការយល់ព្រមទទួលយកសន្តតិកម្ម” ដោយបែងចែកជាពីរ “ការទទួលយកទាំងស្រុង” និង“ការទទួលយកដោយមានកម្រិត” និង ៣.១.២ “ការបោះបង់សន្តតិកម្ម” ដូចតទៅនេះ៖

### ៣.១.១ ការយល់ព្រមទទួលយកសន្តតិកម្ម

សន្តតិជន ត្រូវធ្វើការយល់ព្រម ឬការបោះបង់សន្តតិកម្ម ទាំងស្រុង ឬ ដោយកម្រិតនៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម។ ប៉ុន្តែ អំឡុងពេលនេះអាចពន្យាទៀតបាន តាមពាក្យសុំរបស់សន្តតិជនទៅតុលាការ។[៦៩] ប្រសិនបើអំឡុងពេលនេះវែងពេក អាចមានឥទ្ធិពលដល់ការអនុវត្តសិទ្ធិរបស់អ្នកមានសិទ្ធិបំណុលចំពោះមតកជន។

ក៏ប៉ុន្តែក្នុងករណីដែលមត៌កស្ថិតនៅច្រើនកន្លែង ជាអាទិ៍ មានការពិបាកនិងសម្រេចបោះបង់ ឬ យល់ព្រមក្នុងអំឡុងពេល ៣ ខែនេះដែរ ដូច្នេះមុនពេល ៣ខែ នេះកន្លងផុតអាចដាក់ពាក្យសុំឲ្យតុលាការពន្យា “អំឡុងពេលឲ្យគិតបានដិតដល់” នេះបាន។ ចំពោះការពន្យារពេលនេះ តុលាការដែលទទួលពាក្យសុំនេះ ត្រូវធ្វើ

[៦៩] មាត្រា ១២៤៨, កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ការកំណត់អំឡុងពេលដែលត្រូវពន្យារនេះ ដោយវិនិច្ឆ័យទៅតាមចំនួន ឬ គុណភាពនៃមត៌ក ឬកាតព្វកិច្ចដែលទទួលដោយសន្តតិកម្មជាអាទិ៍។

ការគណនាត្រូវធ្វើឡើងដោយគិតចាប់ពីពេលដែលសន្តតិជនរបស់ជននោះបានដឹងថាសន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម។[90] ប្រសិនបើសន្តតិជនបានមរណភាព មុនពេលធ្វើការយល់ព្រម ឬការបោះបង់សន្តតិកម្មនៅក្នុងអំឡុងពេលកំណត់នៅក្នុងមាត្រា១២៤៨នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ។

**៣.១.១.១ ទាំងស្រុង**

បើសន្តតិជនយល់ព្រមទាំងស្រុង ត្រូវទទួលបន្តដោយគ្មានកម្រិតនូវសិទ្ធិនិងកាតព្វកិច្ចរបស់មតកជននោះ។[91]

ក្នុងករណីដែលបានកំណត់ដូចខាងក្រោមនេះត្រូវចាត់ទុកថាសន្តតិជនបានយល់ព្រមទាំងស្រុងតាមច្បាប់ (មាត្រា១២៥៥)៖

- បើសន្តតិជនបានចាត់ចែងមត៌កនោះទាំងអស់ ឬ មួយភាគលើកលែងតែសកម្មភាពត្រឹមតែជាការគ្រប់គ្រង ។
- បើសន្តតិជនមិនបានយល់ព្រមដោយកម្រិត ឬ បោះបង់នៅក្នុងអំឡុងពេលកំណត់។
- ទោះបីជាសន្តតិជនបានយល់ព្រមដោយកម្រិត ឬ បោះបង់ក៏ដោយបើសន្តតិជនបានលាក់មត៌កទាំងអស់ ឬ មួយភាគ ឬ បានប្រើប្រាស់មត៌កនោះដើម្បីខ្លួនលើកលែងករណីជនដែលដែលក្លាយជាសន្តតិជនដោយសារការបោះបង់បានយល់ព្រម។

**៣.១.១.២ មានកម្រិត**

ហេតុនៃការយល់ព្រមទាំងស្រុងតាមច្បាប់ បន្ទាប់ពីមានការយល់ព្រមដោយកម្រិត សន្តតិជន អាចយល់ព្រមដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និងអច្ច័យទានរបស់មតកជនបាន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាម រយៈសន្តតិកម្មតែប៉ុណ្ណោះ។[92] ក្នុងន័យនេះ ចង់សំដៅដល់សន្តតិជនក្លាយជាកូនបំណុលដោយទទួលនូវសន្តតិកម្មនៃកាតព្វកិច្ចទាំងអស់របស់មតកជន ប៉ុន្តែសន្តតិជនអាចកម្រិតការទទួលខុសត្រូវបានត្រឹមកម្រិតនៃចំណែកមត៌ក លើកលែងតែសន្តតិជនទទួលយកបំណុលក្នុងការសងដោយស្ម័គ្រចិត្ត។ ការយល់ព្រមដោយកម្រិត កើតឡើងមុនការយល់ព្រមតាមច្បាប់។ សន្តតិជនយល់ព្រមដោយកម្រិត បើមានមូលហេតុដែលជាការទទួលខុសត្រូវទាំងស្រុងតាមផ្លូវច្បាប់ ផលប្រយោជន៍នៃការយល់ព្រមដោយកម្រិតត្រូវមាន

[90] ១២៤៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[91] មាត្រា ១២៥៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[92] មាត្រា ១២៥៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

បាត់បង់ ហើយ សន្តតិជនត្រូវទទួលខុសត្រូវដូចគ្នានឹងអ្នកយល់ព្រមទាំងស្រុង។[93] សន្តតិជនដែលមានបំណងចង់យល់ព្រមដោយកម្រិតត្រូវធ្វើបញ្ជីសារពើភ័ណ្ឌហើយត្រូវដាក់ពាក្យសុំអំពីការយល់ព្រមដោយកម្រិតនោះទៅតុលាការ នៅក្នុងអំឡុងពេលបីខែ ។

ករណីសន្តតិជនច្រើននាក់ សន្តតិជនម្នាក់ ឬ ច្រើននាក់ក្នុងចំណោមសហសន្តតិជនទាំងនោះ មានមូលហេតុនៃការយល់ព្រមទាំងស្រុង នាំឲ្យធ្វើការជម្រះបញ្ជីមត៌ក បន្ទាប់មកបើខ្វះខាតអាចយកទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជនដែលមានមូលហេតុនៃការយល់ព្រមទាំងស្រុងតាមច្បាប់មកសងបន្ថែម។ ករណីសហសន្តតិជន ម្ចាស់បំណុលរបស់មតកជនអាចអនុវត្តសិទ្ធិរបស់ខ្លួនទៅលើសន្តតិជន ឬ សហសន្តតិជនណាម្នាក់នោះចំពោះទឹកប្រាក់នៃសិទ្ធិបំណុល ដោយពុំអាចទទួលការសងដោយមត៌កតាមចំណែកមត៌កនីមួយៗ។

### ៣.១.២ ការបោះបង់នូវសន្តតិកម្ម

ការបោះបង់សន្តតិកម្ម ត្រូវធ្វើឡើងនៅក្នុងអំឡុងពេលបីខែ គិតចាប់ពីពេលដែលសន្តតិជនបានដឹងថាសន្តតិកម្មចំពោះខ្លួនបានកើតឡើង ។ ប៉ុន្តែអំឡុងពេលនេះ អាចពន្យាទៀតបាន តាមរយៈពាក្យសុំរបស់សន្តតិជនទៅតុលាការ ។ បុគ្គលដែលបានបោះបង់សន្តតិកម្មត្រូវចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជនចំពោះសន្តតិកម្មនោះតាំងពីដំបូងមកម្ល៉េះ ។

លើសពីនេះ នឹងមិនមានសន្តតិកម្មជំនួសកើតឡើងឡើយបើក្នុងករណីសន្តតិជនបានបោះបង់សន្តតិកម្មចោល ប៉ុន្តែអ្នកមានលំដាប់បន្តតាមច្បាប់កំណត់នៅតែមានសិទ្ធិទទួលបន្តសន្តតិកម្មដដែល។

## ៣.២ របបនៃការគ្រប់គ្រង និង នីតិវិធីនៃការបែងចែកសន្តតិកម្មតាមច្បាប់

បុគ្គលម្នាក់ៗគឺជាម្ចាស់ដែលមានសិទ្ធិផ្តាច់មុខនៃការគ្រប់គ្រងទៅលើទ្រព្យសម្បត្តិដែលខ្លួនមាន។ ទោះបីជា ក្រោយពីការស្លាប់ទៅក៏គេមិនអាចដកហូតទ្រព្យសម្បត្តិនេះបានដែរ។ ទ្រព្យសម្បត្តិដែលជាកេរមត៌ករបស់បុគ្គលដែលស្លាប់ (មតកជន) គឺត្រូវផ្ទេរទៅឲ្យសាច់ញាតិរបស់គាត់ដែលនៅរស់។ ក៏ប៉ុន្តែការផ្ទេរមត៌កនេះត្រូវគោរពទៅតាម បទប្បញ្ញត្តិដែលមានចែងក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។

### ៣.២.១ ការគ្រប់គ្រងមត៌ក

សន្តតិជនដែលកាន់កាប់មត៌ក នៅពេលមតកជនទទួលមរណភាពត្រូវរក្សាទុកនិងការគ្រប់គ្រងមត៌កនោះ រហូតដល់ពេលធ្វើការបែងចែកមត៌ក។[94] នៅក្នុងករណីដែលជនបានទទួលសន្តតិកម្មតែឯងដោយ

[93] មេធាវី អ៊ីវ ប៉ូលី,ការបែងចែកមត៌ក(១៥ មករា ២០១៨ ),ទំព័រ ៧

[94] មាត្រា ១២៦២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

គ្មានមតកសាសន៍បានយល់ព្រមទាំងស្រុងនូវសន្តតិកម្មមត៌កទាំងអស់ធ្លាក់ទៅអ្នកនោះ ដូច្នេះគ្មានបញ្ហាអ្វីកើតឡើងទេ[95]។

- ការគ្រប់គ្រងមត៌ក មានអ្នកទទួលបន្ទុក៣ប្រភេទដូចខាងក្រោម៖

**ក.** ក្នុងករណីសហសន្តតិកម្ម សន្តតិជនជាអ្នករក្សា និងគ្រប់គ្រង ៖ កាលមរណភាព មតកជន ចំពោះសន្តតិជនណាដែលមានកាតព្វកិច្ចក្នុងការកាន់កាប់មត៌ករបស់មតកជននោះត្រូវរក្សានិងគ្រប់គ្រងមត៌កនៅស្ថិតនៅស្ថានភាពដដែលរហូតដល់ពេលធ្វើការបែងចែកមត៌កនោះរួច។[96]

**ខ.** អ្នកមានមុខងារជាអ្នកប្រតិបត្តិមតកសាសន៍ ៖អ្នករក្សាគ្រប់គ្រងលិខិតមតកសាសន៍មានកាតព្វកិច្ចក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិត្រឹមកម្រិតដែលបានកត់ត្រាក្នុងលិខិតមតកសាសន៍ប៉ុណ្ណោះ។ ចំណែកទ្រព្យសម្បត្តិផ្សេងមិនចាត់ឲ្យសន្តតិជនណាម្នាក់ទេ នៅពេលមតកជនបានទទួលមរណភាពទ្រព្យសម្បត្តិទាំងនោះត្រូវធ្វើការគ្រប់គ្រងដោយសហសន្តតិជន។[97]

**គ.** កាគ្រប់គ្រងមត៌ក ដែលចាត់តាំងដោយតុលាការ បើមិនមានករណីខាងលើទាំងពីរ ដូច្នេះ តុលាការមានឆន្ទានុសិទ្ធិក្នុងការកំណត់គ្រប់គ្រង លុះត្រាតែបានបែងចែកចំណែកមត៌ករួចហើយ ឬ ក៏មានការព្រមព្រៀងចំពោះមត៌ក តាមរយៈពាក្យស្នើសុំពីសន្តតិជន ឬ ម្ចាស់បំណុលរបស់មតកជន ប៉ុន្តែការគ្រប់គ្រងបែបនេះ ហៅថាការគ្រប់គ្រងបណ្តោះអាសន្ន។[98]

### ៣.២.២ ការបែងចែកមត៌ក

ការបែងចែកមត៌កអាចមានជាគោលការណ៍ តាមការពិភាក្សារវាងសហសន្តតិជន ក៏ប៉ុន្តែ ប្រសិនបើការពិភាក្សានោះមិនបានទទួលនៅលទ្ធផលល្អទេ តុលាការនិងធ្វើការបែកមត៌កនោះ។

#### ៣.២.២.១ តាមការពិភាក្សារួមគ្នា

សហសន្តតិជនអាចចាប់ផ្តើមពិភាក្សាបែងចែកមត៌ក នៅពេលណាក៏បាន បើអំឡុងពេល ១ (មួយ) ខែបានកន្លងផុតទៅ ក្រោយពីការចាប់ផ្តើមសន្តតិកម្ម។[99] តាមភាពជាក់ស្តែង ក្នុងអំឡុងពេល១ខែ មិនតម្រូវអោយមានការបែងចែកមត៌កនោះឡើយ ហេតុនេះ ត្រូវរកសហសន្តតិជន បន្ទាប់មក ត្រូវកំណត់ថា តើសហសន្តតិជនយល់ព្រម ឬ បោះបង់សន្តតិកម្មរួចកំណត់នូវទំហំនៃសហសន្តតិជន ធ្វើការពិភាក្សាដើម្បីបែងចែកមត៌ក ។

[95] មាត្រា១២៦២ ,សេចក្តីកំណត់មាត្រានីមួយៗក្នុងក្រមរដ្ឋប្បវេណី,គន្លឹ៨និង៩ ,ទំព័រ ១២៣

[96] មាត្រា១១៦២ ,សេចក្តីកំណត់មាត្រានីមួយៗក្នុងក្រមរដ្ឋប្បវេណី,គន្លឹ៨និង៩, ទំព័រ ១២៣

[97] មាត្រា១១៦២ ,សេចក្តីកំណត់មាត្រានីមួយៗក្នុងក្រមរដ្ឋប្បវេណី,គន្លឹ៨និង៩, ទំព័រ ១២៣

[98] មាត្រា១១៦៤ ,សេចក្តីកំណត់មាត្រានីមួយៗក្នុងក្រមរដ្ឋប្បវេណី,គន្លឹ៨និង៩, ទំព័រ ១២៥

[99] មាត្រា ១២៦៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ក៏ប៉ុន្តែ ក្នុងអំឡុងពេលមួយខែ ក្រោយមរណភាពរបស់មតកជនចាំបាច់ត្រូវផ្តល់ការគោរពចំពោះវិញ្ញាណក្ខ័ន្ធមតកជននោះ។ គេអាចកំណត់បានថា មិនអាចដាក់ពាក្យសុំទាមទារឲ្យតុលាការសម្រេចសេចក្តីអំពីការបែងចែកមត៌ក ។ ផ្ទុយទៅវិញ ទោះបីជាសន្តតិជនផ្សេងទៀតបានព្រមព្រៀងបែងចែកមត៌កតាមផ្ទាល់មាត់ក៏ដោយ ប្រសិនបើមិនធ្វើនីតិវិធីនោះទេ គេនិងវាយតម្លៃថា ការពិភាក្សានៃការបែងចែកមត៌កមិនបានធ្វើឡើងរវាងសហសន្តតិជននោះ ចាំបាច់ត្រូវដាក់ពាក្យសុំទៅតុលាការឲ្យធ្វើការបែងចែកមត៌ក ។

#### ៣.២.២.២ តាមតុលាការ

ជាគោលការណ៍ ក្នុងករណីដែលតុលាការបែងចែកមត៌កជំនួសសហសន្តតិជន ប៉ុន្តែ តុលាការមិនអាចធ្វើការបែងចែកមត៌កដោយឆន្ទានុសិទ្ធិរបស់ខ្លួនបានទេ ពោលគឺអាចធ្វើបានពេលដែលមានពាក្យសុំពីសហសន្តតិជនប៉ុណ្ណោះ ។[100] ក្នុងករណីនេះ តុលាការត្រូវពិចារណាដល់ "ទំនៀមទំលាប់នៅក្នុងតំបន់" និងយកមតិភាគច្រើនលើសពីពាក់កណ្តាលរបស់សហសន្តតិជនផងដែរ។ ទោះជាមានមតិភាគច្រើន ឬ មតិភាគតិចរបស់សហសន្តតិជនយ៉ាងណាក៏ដោយប្រសិនបើមតិនោះមិនសមរម្យ នោះ តុលាការមានសិទ្ធិសម្រេចយកដោយសុក្រឹត្យទៅលើមតិណាដែលសមហេតុផលជាង ។

### ៣.២.៣ អានុភាពនិងការធានាលើទំនួលខុសត្រូវ

ចំណុចនេះយើងនឹងបកស្រាយពី ៣.២.៣.១ "អានុភាពនៃសន្តតិកម្ម" និង ៣.២.៣.២ "ការធានាលើការទទួលខុសត្រូវ"។

#### ៣.២.៣.១ អានុភាពនៃសន្តតិកម្ម

ការបែងចែកមត៌ក មានអានុភាពប្រតិសកម្ម គិតចាប់ពីពេលបានចាប់ផ្តើមសន្តតិកម្ម។[101] នោះមានសេចក្តីថា សន្តតិជនទទួលមត៌ក ពីមតកជនផ្ទាល់ គឺមិនមែនបានទទួលពីសហសន្តតិជនផ្សេងទេ ហេតុនេះសន្តតិជននោះអាចមានមនោសញ្ចេតនាពិសេសចំពោះមត៌កនោះបាន។ មួយវិញទៀត អានុភាពប្រតិសកម្មនៃការបែងចែកមត៌កនេះដោយគ្មានលក្ខខណ្ឌទេនោះ និងធ្វើអោយបាត់បង់នូវសុវត្ថិភាពក្នុងកិច្ចជំនួញ ហើយការបែងចែកមត៌កនេះមិនត្រូវទទួលស្គាល់ចំពោះតតិយជនដែលបានចុះបញ្ជី ឬ មានលក្ខខណ្ឌតតាំងបានឡើយ។ នោះសន្តតិជនដែលទទួលឥទ្ធិពលដោយសារវត្តមានរបស់តតិយជនេះ អាចទាមទារឲ្យសហសន្តតិជនដែលបានបង្កើត ឲ្យមានការទទួលខុសត្រូវបាន ឬ អាចលុបចោលនូវការបែងចែកមត៌កនេះ ដោយការភាន់ច្រឡំជាមូលហេតុ ហើយបែងចែកសារជាថ្មីឡើងវិញ។

[100] មាត្រា ១២៧០, កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[101] មាត្រា ១២៧៣, កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

សិទ្ធិលើបំណុលរបស់មតកជននឹងត្រូវធ្វើការបែងចែកទៅឲ្យសន្តតិជនទៅតាមសមាមាត្រដែលច្បាប់បានកំណត់ដោយស្វ័យប្រវត្តិហើយករណីមានកិច្ចព្រមព្រៀងពីសំណាក់សហសន្តតិជនសិទ្ធិលើបំណុលនោះអាចយកមកធ្វើការបែងចែកចំណែកមត៌កដោយលិខិតយថាភូតត្រូវការបង្ហាញលិខិតនោះទៅអោយកូនបំណុលនៃមតកជន ដើម្បីទុកវិធីសាស្ត្រតតាំងនឹងកូនបំណុល។[102]

ប៉ុន្តែកូនបំណុលដែលបានសងតាមចំណែកមត៌កនៃសន្តតិជននោះហើយ ដោយសងមុនពេលទទួលបានការជូនដំណឹងនៃការបែងចែក គឺអាចតតាំងចំពោះសហសន្តតិជនដែលបានធ្វើលទ្ធកម្មលើបំណុលតាមការបែងចែកនោះបាន។[103]

### ៣.២.៣.២ ការធានាលើទំនួលខុសត្រូវ

សហសន្តតិជនម្នាក់ៗ ត្រូវមានបន្ទុកទទួលខុសត្រូវការធានា ទៅតាមសមាមាត្រនៃចំណែកមត៌កនោះប្រៀបបីដូចជាអ្នកលក់ដែរ ក្នុងករណីដែលវត្ថុ ឬ សិទ្ធិដែលសន្តតិជនបានទទួលតាមលទ្ធផលនៃការបែងចែកមត៌កមានវិការៈ។[104] មានន័យថា ការបែងចែកមត៌ក គឺជា ការធ្វើឲ្យមត៌កដែលនៅក្នុងស្ថានភាពជាកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន ឲ្យទៅជាកម្មសិទ្ធិតែមួយ ដោយការពិភាក្សារបស់សហសន្តតិជន ដូច្នេះហើយតាមភាពជាក់ស្តែង គឺជាការលក់ទិញ ឬ ការដូរតែប៉ុណ្ណោះ ។ ក្នុងការធានានេះ ប្រសិនបើមានការភ័ន្តច្រឡំក្នុងការបែងចែកមត៌ក គឺនាំអោយមានការបែងចែកជាថ្មី នោះសន្តតិជនអាចធ្វើការទាមទារនោះបាន។

**ឧទាហរណ៍៖** ក្រោយពីឪពុកស្លាប់ទៅ កម្មវត្ថុនៃសន្តតិកម្មគឺមាន ឡាន និងប្រាក់ ១០.០០០(មួយម៉ឺន) ដុល្លារ សន្តតិជនទាំងពីរ មាន ក និង ខ បានព្រមព្រៀងគ្នាក្នុងការបែងចែក ឲ្យឡានជាចំណែករបស់ ក រីឯប្រាក់ ១០.០០០ (មួយម៉ឺន) ដុល្លារជាចំណែកមត៌ករបស់ ខ។ ប៉ុន្តែ ក្រោយពីបានមើលប័ណ្ណសម្គាល់ម្ចាស់យានយន្តហើយ ទើបដឹងថាយានយន្តនោះ គឺជារបស់ម្តាយរបស់ខ្លួនដែលជាអនីតិសង្វាសជន ដូច្នេះ ក ទាមទារឲ្យមានការបែងចែកមត៌កជាថ្មី។

## ៣.២.៤ ការសម្រួលរវាងម្ចាស់បំណុល

ក្នុងករណីមតកជនមានកាតព្វកិច្ច ហើយសន្តតិជនមានកាតព្វកិច្ចផ្ទាល់ខ្លួនក្រោយពេលចាប់ផ្តើមសន្តតិកម្ម ម្ចាស់បំណុលរបស់មតកជនអាចអនុវត្តសិទ្ធិរបស់ខ្លួនចំពោះទ្រព្យសម្បត្តិរបស់សន្តតិជន ហើយអ្នកទទួលក៏អាចអនុវត្តសិទ្ធិរបស់ខ្លួនចំពោះចំណែកមត៌ករបស់សន្តិជននោះ ដែលជាបញ្ញត្តិ ហៅថា គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ។ ករណីនេះម្ចាស់បំណុល នៃមតកជនមានសិទ្ធិអនុវត្តលើទ្រព្យសម្បត្តិដែលជាកម្ម

[102] មាត្រា ១២៧៥ , កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[103] មាត្រា ១២៧៥ , កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[104] មាត្រា ១២៧៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

វត្ថុនៃសន្តតិកម្ម ដោយតាមរយៈការហាមឃាត់មិនឲ្យសន្តតិកជនផ្ទេរកម្មសិទ្ធិវាបាន ដោយម្ចាស់បំណុលអាចទាមទារឲ្យជ្រើសតាំងអ្នកគ្រប់គ្រងបណ្តោះអាសន្នក្នុងការរក្សាគ្រប់គ្រប់គ្រងមត៌កទាំងអស់នោះ លុះត្រាតែគ្មានអ្នកប្រតិបត្តិមតកសាន៍ ក៏បញ្ជាក់ឃើញដែលថា ម្ចាស់បំណុលគ្មានសិទ្ធិក្នុងការគ្រប់គ្រងផ្ទាល់ទៅលើមត៌ករបស់មតកជនឡើយ ។

ការសម្របសម្រួល សំដៅដល់ការពារផលប្រយោជន៍ម្ចាស់បំណុលប៉ុន្តែប្រសិនបើសន្តតិជនបានបោះបង់សន្តតិកម្ម ម្ចាស់បំណុលមិនអាចអនុវត្តសិទ្ធិហើយសន្តតិជនក៏មិនអាចទទួលចំណែកមត៌កនោះដូចដែលបានដែលរៀបរាប់ខាងលើឡើយ ។ មួយវិញទៀត ក្នុងករណីសន្តតិជនបានបានយល់ព្រមដោយកម្រិតសន្តតិជនត្រូវជូនដំណឹងជាសាធារណៈដើម្បីដឹងថា ការយល់ព្រមដោយកម្រិតនេះ ទៅដល់ម្ចាស់បំណុលក្នុងរយៈ ពេល ៥ (ប្រាំ) ថ្ងៃ ដោយកំណត់ផងដែរ ក្នុងអំឡុងពេលជាក់លាក់មួយសម្រាប់ម្ចាស់បំណុលដើម្បីដាក់ពាក្យស្នើសុំ និងចាប់ផ្តើមឲ្យមានវិធីជម្រះបញ្ជី។ [105] ដែលតម្រូវឲ្យសន្តតិជននោះនឹងមានកាតព្វកិច្ចគ្រប់គ្រងមត៌កឲ្យបានល្អព្រមទាំងទទួលបានចំណែកមត៌កសកម្មដែលបាននៅសល់ក្រោយជម្រះបញ្ជី។[106]

ផ្ទុយទៅវិញ ករណីដែលមិនបានស្នើសុំនោះ ក្នុងអំឡុងពេលដែលបានកំណត់ទេនោះ ម្ចាស់បំណុលនឹងត្រូវបាត់បង់ផលប្រយោជន៍អំពីបំណុលរបស់ខ្លួន ព្រោះសន្តតិជនមិនសងលើបំណុលនោះ ព្រោះខ្លួនមិនមានឈ្មោះក្នុងការជម្រះបញ្ជីនោះទេ។ [107] គួរបញ្ជាក់ផងដែរ ករណីខាងលើមិនមានប្រសិទ្ធិភាពទៅលើម្ចាស់បំណុលដែលបានភ្ជាប់សិទ្ធិប្រាតិភោគប្រត្យក្ស ដូចជា ហ៊ីប៉ូតែក ជាអាទិ៍ ។ ក្រោយអំឡុងពេលដែលបានដាក់នោះផុតកំណត់ហើយ នោះសន្តតិជនដែលយល់ព្រមដោយកម្រិត ត្រូវមានកាតព្វកិច្ចសងឲ្យម្ចាស់បំណុលទាំងអស់ដែលខ្លួនបានដឹងលឺតាមសមាមាត្រនៃចំណែកមត៌កដែលខ្លួនបានទទួលធៀបនឹងបំណុលនោះ។[108]

ក្នុងករណីដែលសន្តតិជនបានយល់ព្រមទទួលសន្តិកម្មដោយកម្រិតហើយ វាបានបង្កើតឲ្យម្ចាស់បំណុលបង្កើតនូវសិទ្ធិទទួលបានសំណងក្នុងពេលដែលជម្រះបញ្ជីនោះ ទោះបីមិនទាន់ដល់ពេលកំណត់សងក៏ដោយ។[109] ការសងបំណុលត្រូវធ្វើការសងទៅឲ្យម្ចាស់បំណុលមុននឹងសងឲ្យអច្ច័យលាភី។[110] ក្នុងករណីតម្រូវឲ្យ សងតាមរយៈការលក់មត៌កដោយបង្ខំ ឬ លក់ក្នុងតម្លៃខ្ពស់ជាងការវាយតម្លៃ ដែលត្រូវបានជ្រើសរើសតាំង

[105] មាត្រា ១២៨១, កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[106] មាត្រា ១២៨០, នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[107] មាត្រា ១៣០៤, កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[108] មាត្រា ១២៨៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[109] មាត្រា ១២៨៤ , កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[110] មាត្រា ១២៨៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ដោយតុលាការ ម្ចាស់បំណុលនិង អច្ច័យលាភីមានសិទ្ធិក្នុងការទិញមត៌កនោះ។[111] បើក្នុងករណី សន្តតិជនច្រើនបានយល់ព្រមដោយមានកម្រិតចំពោះសន្តតិជននោះ វាជាតួនាទីរបស់តុលាការ ក្នុងការជ្រើសសន្តតិជនម្នាក់ក្នុងចំណោមអ្នកទាំងនោះជាអ្នកគ្រប់គ្រងចំណែកមត៌កនោះ ដោយរួមទាំងការសងបំណុលក្នុងជាផលប្រយោជន៍របស់ខ្លួនឯង និងសន្តតិជនទាំងអស់ផងដែរ។[112]

## ៣.៣ អំពីស្ថានភាពពិសេសនៃសន្តតិកម្មតាមច្បាប់

ករណីមួយចំនួន ដោយសន្តតិកម្មខ្លះគ្មានសន្តិជនជំនួសនោះទេ ដែលនាំឲ្យមានការស្វែងរកសន្តតិជននោះមកស្នងមត៌កទាំងនោះផងដែរ ។ និងករណីមួយចំនួនទៀត គឺគ្មានសន្តតិជនតែម្តង ដែលធ្វើឲ្យមត៌កទាំងអស់ធ្លាក់ទៅលើជនមាននិស្ស័យពិសេស(នត្ថិភាពនៃសន្តតិជន)ដែលមានយកមកសិក្សាក្នុងចំណុច “៣.៣.១” ។ មួយវិញទៀតប្រសិនបើមានជនដទៃដែលហាក់ដូចជាសន្តតិជន ហើយបានទទួលមត៌ករួចតែគ្មានមូលហេតុគតិយុត្តណាមួយក្នុងការទទួលសន្តតិកម្មនោះទេដែលនាំឲ្យសន្តតិជនទាមទារឲ្យធ្វើបដិទានសន្តតិកម្មមកវិញ ដែលសិក្សាក្នុងចំណុច “៣.៣.២” ករណីទាំងអស់ខាងលើនេះដែលហៅថាស្ថានភាពពិសេសនៃសន្តតិកម្ម ។

### ៣.៣.១ អំពីនត្ថិភាពនៃសន្តតិជន

#### ៣.៣.១.១ នីតិបុគ្គលមត៌ក

ក្នុងករណី គ្មានសន្តតិជនក្នុងការទទួលមត៌កទេនោះ គឺនាំឲ្យម្ចាស់បំណុលពិបាកក្នុងការទាមទារមកវិញនូវបំណុលនោះដែលធ្វើឲ្យម្ចាស់បំណុលត្រូវចាត់ទុកមត៌កជានីតិបុគ្គល ដែលដើរតួជាប្រធានសិទ្ធិ និងកាតព្វកិច្ចក្នុងសន្តតិកម្មនេះ ក្នុងការសងបំណុលក្នុងវិធីជម្រះបញ្ជី។[113]ដាច់ខាតត្រូវជានីតិបុគ្គលជាអ្នកគ្រប់គ្រង ដែលត្រូវបានជ្រើសរើស តាមការស្នើសុំទៅតុលាការដោយអ្នកមានផលប្រយោជន៍ពាក់ព័ន្ធនិងគ្នា មេឃុំ ចៅសង្កាត់នៃលំនៅដ្ឋានចុងក្រោយរបស់មតជន ឬតំណាងអយ្យការ។[114] ដោយតុលាការត្រូវជ្រើសតាំង អ្នកគ្រប់គ្រងមត៌កនៃនីតិបុគ្គលនោះ ប្រសិនបើគិតចាប់ពីពេលបើកសន្តតិកម្ម ២ (ពីរ) ខែយ៉ាងតិច ដែលនៅតែមិនដឹងថាមានសន្តតិជនមកទទួលស្នងមត៌ក។[115] ក្នុងករណី ដែលក្នុងអំឡុងពេលឲ្យប្រកាសជាសាធារណៈក្នុងការរកសន្តតិជនដែលមានថេរវេលាយ៉ាងតិច ៦ (ប្រាំមួយ) ខែហើយគិតចាប់ពីជ្រើសតាំងអ្នកគ្រប់គ្រងមិនមានសន្តតិជនមកទទួលសិទ្ធិទៀតនោះសន្តតិជនទាំងអស់នឹងត្រូវបាត់បង់សិទ្ធិនោះហើយអ្នកគ្រប់គ្រងមានកាតព្វកិច្ចសង

[111] មាត្រា ១២៨៦ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[112] មាត្រា ១២៨៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[113] មាត្រា ១២៩០ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[114] មាត្រា ១២៩១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[115] មាត្រា ១២៩៦ , កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

បំណុល និងបែងចែកមត៌កទៅឲ្យជនដែលមាននិស្ស័យ ឬឲ្យក្លាយទៅជាសម្បត្តិរដ្ឋ។[116]

មួយវិញទៀត ប្រសិនបើសន្តតិជនបានយល់ព្រមទទួលសន្តតិកម្មហើយ អ្នកគ្រប់គ្រងក៏អស់កាតព្វកិច្ចផងដែរ ដោយសារកាតព្វកិច្ចខាងលើត្រូវបានផ្ទេរទៅសន្តតិជនរូបនោះរួចរាល់អស់ហើយ។[117]

**៣.៣.១.២ មត៌កក្លាយជារបស់រដ្ឋ**

ក្នុងករណី ចំពោះចលនវត្ថុដែលជាកម្មវត្ថុរបស់សន្តតិកម្ម ហើយពុំមានអ្នកទទួលស្នងលើអចលនវត្ថុនោះទេ វានឹងក្លាយជាសម្បត្តិរបស់រដ្ឋ ហើយចំណែកមត៌កដែលនៅសល់ពីការបែងចែកទៅឲ្យជនដែលមាននិស្ស័យពិសេសនោះ និងក្លាយជារបស់រដ្ឋផងដែរ។[118]

**៣.៣.១.៣ ជនដែលមាននិស្ស័យពិសេស**

ចំពោះជនដែលមានជីវភាពរស់នៅជាមួយមតកជន ជនដែលបានខិតខំមើលថែ ព្យាបាលមតកជននោះត្រូវចាត់ទុកថា ជាជនដែលមាននិស្ស័យពិសេស ទោះបីបើគ្មានទំនាក់ទំនងញាតិជាមួយមតកជននោះក៏ដោយ ។ ហេតុនេះ ជនដែលមាននិស្ស័យពិសេសចង់បែងចែកចំណែកមត៌ក នោះត្រូវធ្វើការស្នើសុំទៅតុលាការដែលទាមទារចំណែកមត៌កមិនលើសពីពាក់កណ្តាលនៃចំណែកមត៌កទាំងអស់ក្រោយពីជម្រះបញ្ជីនោះទេ។ [119] ថេរវេលានៃការស្នើសុំរបស់ជនដែលមាននិស្ស័យពិសេសគឺ ៣ (បី) ខែ គិតចាប់ពីពេលស្វែងរកសន្តតិជនបានផុតទៅ។[120]

**៣.៣.២ អំពីបដិទាននៃសន្តតិកម្ម**

បដិទានសន្តតិកម្ម សំដៅលើការទាមទារមួយដែលជាសិទ្ធិរបស់សន្តតិជនពិតប្រាកដ ធ្វើការទាមទារចំណែកមត៌កនៃសន្តតិកម្ម ពីបុគ្គលដែលត្រូវបានគេយល់ឃើញថាជាសន្តតិជន តែការពិតពុំមែនជារបស់សន្តតិជនពិតប្រាកដនោះទេ ដូច្នេះសន្តតិជនពិតប្រាកដអាចទាមទារឲ្យជននោះ ប្រគល់ចំណែកមត៌កនៃសន្តតិកម្មនោះមកវិញ។[121] ស្ថានភាពនៃបដិទានសន្តតិកម្មនេះ អាចកើតឡើងដោយៈ

**ទីមួយ** តាមរយៈសំបុត្រកំណើត អាចជាការក្លែងបន្លំ ឬ ការធ្វេសប្រហែស នាំឲ្យបុគ្គលដែលមិនមែនជាកូនរបស់មតកជន ហើយមានឈ្មោះក្នុងសំបុត្រកំណើតនោះអាចទទួលបានចំណែកមត៌កនៃសន្តតិកម្មនោះបាន។

---

[116] មាត្រា ១២៩៩ និង មាត្រា ១៣០០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[117] មាត្រា ១២៩៥ ,កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[118] មាត្រា ១៣០០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[119] មាត្រា ១២៩៩ , កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[120] មាត្រា ១២៩៩ , កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[121] មាត្រា ១៣០២ , កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

**ទីពីរ** មតកជនមានកូនជាមួយអ្នកផ្សេង ប៉ុន្តែមិនមានទំនាក់ទំនងគ្នាជាយូរមកហើយ ហើយបែរជាមានសន្តតិកម្មតែក្នុងរង្វង់គ្រួសារថ្មីនោះធ្វើឲ្យកូនខាងលើមានសិទ្ធិក្នុងការទាមទារធ្វើបដិទាននៃសន្តតិកម្មនោះ។

**ទីបី** សន្តតិជនណាមួយដែលបានទទួលចំណែកមត៌កលើសពីចំណែករបស់ខ្លួនដែលត្រូវទទួលបាន។

ជាគោលការណ៍ ក្នុងករណីដែលជនដែលមិនមែនជាសន្តតិជនបានទទួល ចំណែកមត៌កនៃសន្តតិកម្ម ហើយធ្វើការលក់ទ្រព្យនោះទៅឲ្យតតិយជនបាត់ហើយ សន្តតិជនពិតប្រាកដមានសិទ្ធិទាមទារបាន ប៉ុន្តែមិនមែនទាមទារឲ្យជនមិនមានសិទ្ធិនោះ ឬ អ្នកទិញធ្វើបដិទានទ្រព្យនោះមកវិញទេគឺអាចទាមទារបានតែថ្លៃលក់នៃទ្រព្យនោះមកវិញប៉ុណ្ណោះ។[122]

ផ្ទុយទៅវិញប្រសិនបើអ្នកទិញមានបំណងទុច្ចរិត ឬ មានកំហុសដោយបានដឹងហើយថា ជនដែលជាអ្នកលក់នោះមិនមានសិទ្ធិជាសន្តតិជននោះទេ តែនៅតែធ្វើការទិញពីនោះទៀត សន្តតិជនពិតប្រាកដអាចធ្វើការទាមទារទ្រព្យទាំងនោះមកវិញបាន។[123]

ជនដែលមិនមានសិទ្ធិជាសន្តតិជននោះ ត្រូវធ្វើការប្រគល់មកវិញនូវទ្រព្យដែលជាកម្មវត្ថុនៃសន្តតិកម្មទៅឲ្យសន្តតិជនពិតប្រាកដវិញ ដោយប្រគល់ទាំងផលនិងការប្រាក់ដែលបានទទួលពីទ្រព្យនោះនិងមិនអាចទាមទារសំណង និងសោហ៊ុយបង្កើតតម្លៃនៃទ្រព្យនោះបានទេ ហើជននោះជាបុគ្គលទុច្ចរិត។[124]

ផ្ទុយទៅវិញ ក្នុងករណីដែលជនមិនមានសិទ្ធិនោះ ជាបុគ្គលសុចរិតវិញ ផល ឬ ការប្រាក់ដែលកើតចេញពីទ្រព្យនោះនឹងធ្លាក់ទៅជារបស់បុគ្គលនោះ មិនត្រឹមតែប៉ុណ្ណោះ បុគ្គលនោះនៅមានសិទ្ធិទាមទារឲ្យសន្តតិជនសងសោហ៊ុយដែលបានបង្កើតតម្លៃនៃទ្រព្យនោះ និងសំណងទៅលើកាតព្វកិច្ចដែលខ្លួនបានសងតាមសន្តតិកម្មនោះ។[125]

ការទាមទារខាងលើមានអំឡុងពេល៥ឆ្នាំ (ប្រាំ) គិតចាប់ពីពេលដែលបានផ្ទេរនោះ សម្រាប់ឲ្យសន្តតិជនពិតប្រាកដធ្វើការទាមទារ បើចំណែកមត៌កនៃសន្តតិកម្មនោះបានផ្ទេរទៅឲ្យជនគ្មានសិទ្ធិតាមមតកសាសន៍ ឬ ការបែងចែកមត៌កប៉ុន្តែបើជាករណីដែលជនគ្មានសិទ្ធិតែម្នាក់ទទួលសន្តតិកម្មក្នុងនាមជាសន្តតិជនវិញ អំឡុងពេលនៃការទាមទារក៏មាន ៥(ប្រាំ)ឆ្នាំដែរ តែគិតចាប់ពីពេលដែលមតកជនបានទទួលមរណភាពទៅវិញ។[126]

---

122 មាត្រា ១៣០៣ , កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

123 មាត្រា ១៣០៣ ,កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

124 មាត្រា ១៣០៣ , កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

125 មាត្រា ១៣០៣ , កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

126 មាត្រា ១៣០៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

## ៣.៤ ការអនុវត្តជាក់ស្តែងនៃការបែងចែកមត៌ក

### ក.លំហូរនៃការទទួលរឿងក្តីសន្តតិកម្ម

**១.ចំនួនសន្តតិជនៈ** សាកសួរភាគីលម្អិតអំពីបុគ្គលដែលបានផលប្រយោជន៍ពាក់ព័ន្ធនឹងមត៌ករបស់មតកជន ដើម្បីដឹងឲ្យបានច្បាស់លាស់អំពីចំនួនសន្តតិជន។ ប្រសិនបើអាចកំណត់អត្តសញ្ញាណសន្តតិជនរួចហើយ ត្រូវកំណត់ប្រភេទសន្តតិជនថែមទៀត ដូចជា សន្តតិជននោះជា កូន ជាបច្ចាញាតិផ្ទាល់ ឬ ជាបុគ្គលទទួលតាមសន្តតិកម្មជំនួស ឬជាសហព័ទ្ធឬជាឪពុក ម្តាយ ឬ ជាបងប្អូនបង្កើតជាអាទិ៍។

**២.ចំណែកសន្តតិកម្មៈ** នៅពេលអាចកំណត់ចំនួនសន្តតិជន និងអត្តសញ្ញាណរបស់សន្តតិជនរួចហើយ និងដឹងអំពីទំនាក់ទំនងញាតិរួចហើយ និងធ្វើការពិនិត្យបន្ត ថាតើមានលិខិតបណ្តាំ ឬយ៉ាងណា បើមានត្រូវអនុវត្តតាមសន្តតិកម្មតាមមតកសាសន៍បើគ្មានត្រូវបែងចែកមត៌កតាមច្បាប់ក្នុងចំណោមសន្តតិជនទាំងនោះ។

**៣.ទំហំមត៌កៈ** ដើម្បីមានភាពច្បាស់លាស់ត្រូវធ្វើការស្រាវជ្រាវមត៌កដែលជាកម្មវត្ថុនៃការបែងចែក គឺជាទ្រព្យសកម្មដែលមិនទាន់បានបែងចែកនៅឡើយនៅពេលបែងចែកមត៌ក នៅក្នុងចំណោមសិទ្ធិនិងករណីកិច្ចនៃទ្រព្យសម្បត្តិរបស់មតកជននៅពេលចាប់ផ្តើមសន្តតិកម្ម។ ក្នុងករណីដែលមានវិវាទពាក់ព័ន្ធក្នុងការទទួលយកមត៌កត្រូវដោះស្រាយតាមនីតិវិធីរដ្ឋប្បវេណី។ ចំណុចដែលត្រូវប្រុងប្រយ័ត្នពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធអំពីទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ គឺ មានតែចំណែកកម្មសិទ្ធិអវិភាគរបស់មតកជនប៉ុណ្ណោះដែលក្លាយជាមត៌ក។ ប្រសិនបើកម្មវត្ថុនៃមត៌ករបស់សិទ្ធិលើបំណុលជាប្រាក់ ជាទូទៅសិទ្ធិលើបំណុលនេះនឹងបែងចែកទៅតាមចំណែកនៃសន្តតិកម្មតាមច្បាប់ ប៉ុន្តែបើសិនជាមានការយល់ព្រមរវាងសន្តតិជន សិទ្ធិលើបំណុលនោះអាចជាកម្មវត្ថុនៃការបែងចែក ប៉ុន្តែកាតព្វកិច្ចមិនមែនជាកម្មវត្ថុនៃការបែងចែកមត៌កនោះទេ។ មួយវិញទៀត ផលពីសិទ្ធិនៃ សន្តតិកម្ម ដូចជាប្រាក់សំណងការខូចខាត ជាអាទិ៍ ដែលបានធ្វើលទ្ធកម្ម ដោយការសងជំនួសការបាត់បង់ ការខូចខាត ឬការបំពានកម្មវត្ថុនៃទ្រព្យសម្បត្តិសន្តតិកម្ម ប្រាក់លក់ដែលបានធ្វើលទ្ធកម្មជាអាទិ៍ ដោយកិច្ចសន្យាដែលយកមត៌កជាកម្មវត្ថុ នឹងក្លាយជាកម្មវត្ថុនៃការបែងចែកមត៌កផងដែរ។

**៤.ការវាយតម្លៃមត៌ក** ៖ ការវាយតម្លៃមត៌ក អាចធ្វើឡើងតាមរយៈការព្រមព្រៀងអំពីចំនួន ឬ ការជ្រើសតាំងអ្នកវាយតម្លៃ ឬ ការសន្មតនូវចំនួនជាក់លាក់ណាមួយ។ចំពោះអចលនវត្ថុ នៅប្រទេសជប៉ុន តុលាការអាចបង្គាប់ឲ្យដាក់ឯកសារដូចជា លិខិតវាយតម្លៃទ្រព្យលិខិតប្រកាសពន្ធសន្តតិកម្ម និងលិខិតវាយតម្លៃរបស់ក្រុមហ៊ុនអចលនវត្ថុដើម្បីសម្របសម្រួលយោបល់របស់ភាគីនិងឈានដល់ការការព្រមព្រៀង។

ក្នុងករណីដែលមិនអាចព្រមព្រៀង តុលាការនឹងជ្រើសរើសអ្នកវាយតម្លៃដែលជាបុគ្គលមានចំណេះដឹង ដូចជាអ្នកជំនាញវាយតម្លៃអចនវត្ថុ ជាអាទិ៍ មកធ្វើការវាយតម្លៃ។

ង.**ការកំណត់ចំណែកមត៌កជាក់ស្តែង**៖ ចំណែកសន្តតិកម្មជាក់ស្តែង គឺជាអត្រាចំណែកមត៌កចុងក្រោយដែលបានសម្រួលរួចរាល់ ដោយពិចារណាលើចំណែកសន្តតិកម្មតាមច្បាប់ជាមួយនឹងការទទួលផលប្រយោជន៍ពិសេស និងភាគនៃវិភាគទាន ។ ការសម្រួលចំណែកសន្តតិកម្ម ជាវិធីមួយកំណត់ឲ្យមានសមភាពជាក់ស្តែងនៃទ្រព្យសន្តតិកម្ម។ ទ្រព្យសន្តតិកម្មនៅពេលចាប់ផ្តើមសន្តតិកម្មបូកនឹងផលប្រយោជន៍ពិសេស និងដកភាគនៃវិភាគទានចេញ ត្រូវចាត់ទុកជាមត៌ក។ ចំណែកសន្តតិកម្មនៃសន្តតិជនទាំងអស់ (ចំណែកសន្តតិកម្មបណ្តោះអាសន្ន)ត្រូវគណនាឲ្យទៅតាមចំណែកសន្តតិកម្មតាមច្បាប់ ។

**៥.ដីកាសម្រេចបែងចែកមត៌ក**៖ តុលាការត្រូវសម្រេចករណីបែងចែកមត៌កដោយពិចារណាទៅលើស្ថានភាពមួយចំនួនទី១ ដូចជាការបែងចែកដោយផ្ទាល់ ទី២ ការសម្រួលការបង់ជាប្រាក់ ទី៣ ការបែងចែកដោយប្តូរជាប្រាក់ ទី៤ ការបែងចែកជាវត្ថុអវិភាគដោយគិតគូរជាក់ស្តែងទៅលើស្ថានភាពរបស់សហសន្តតិជន ដូចជា អាយុ មុខរបរ សុខភាព ជីវភាព វត្ថុឬប្រភេទនៃសិទ្ធិដែលមានចំពោះមត៌ក សិទ្ធិអាទិភាពរបស់សហព័ទ្ធ សំណងនៃកាតព្វកិច្ចរបស់មតកជន ទំនៀមទំលាប់ និងមតិយោបល់របស់សហសន្តតិជន ជាអាទិ៍។

**ខ.របៀបសរសេរពាក្យសុំបែងចែកមត៌ក**

- អត្តសញ្ញាណភាគី អាសយដ្ឋាន និងឋានៈភាគី
- ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារឲ្យតុលាការចេញ
- អង្គហេតុដែលជាមូលដ្ឋានៃការទាមទារ

**គ.ឯកសារភ្ជាប់**

ទី១ ឯកសារបញ្ជាក់អត្តសញ្ញាណសន្តតិជន៖ អត្តសញ្ញាណប័ណ្ណ

ទី២ ឯកសារបញ្ជាក់អត្តសញ្ញានសន្តតិជន និងមតកជន៖ សំបុត្រកំណើត សៀវភៅគ្រួសារ និងសៀវភៅស្នាក់នៅ ជាអាទិ៍។

ទី៣ ឯកសារបញ្ជាក់អត្តសញ្ញាណទ្រព្យដែលជាកម្មវត្ថុនៃមត៌ក៖ លិខិតបញ្ជាក់ទ្រព្យទាំងឡាយដែលជាកម្មសិទ្ធិរបស់មតកជន។

ទី៤ សំបុត្រមរណភាព ៖លិខិតដែលបញ្ជាក់អំពីមតកជនស្លាប់

ទី៥ ឯកសារបញ្ជាក់អំពីសិទ្ធិលើបំណុលឬកាតព្វកិច្ច ជាអាទិ៍ ៖កិច្ចសន្យា។

**ឃ.មូលដ្ឋាននៃការវិនិច្ឆ័យ**

1. ការបញ្ជាក់អំពីចំណែកសន្តតិកម្មជាក់ស្តែង
2. ការបញ្ជាក់អំពីខ្លឹមសារជាក់ស្តែង
3. សិទ្ធិអាទិភាពរបស់សហព័ទ្ធ
4. សំណងនៃកាតព្វកិច្ចរបស់មតកជន
5. ការបែងចែកវត្ថុជាក់ស្តែង ការបែងចែកជំនួស និងការប្តូរជាប្រាក់
6. ករណីដីជាកម្មវត្ថុមត៌ក

**ង.សេចក្តីសម្រេចបញ្ចប់។**[127]

[127] ការបែងចែកមត៌កដកស្រង់ចេញពីវិភាគទានច្បាប់(ចែករំលែក),១៥ មករា ២០១៨

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សានិងបកស្រាយប្រធានបទស្តីពី **សន្តតិកម្មតាមច្បាប់** រួចមក អាចសង្ខេបបានថាសន្តតិកម្មតាមច្បាប់ជារបបគតិយុត្តដែលក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧បានចែងអំពីខ្លឹមសារនានា គឺ សំដៅទៅដល់ការផ្ទេរទ្រព្យសម្បត្តិ(មត៌ក)របស់អ្នកស្លាប់(មតកជន)ទៅឲ្យអ្នកស្នងមត៌ក(សន្តតិជន)ម្នាក់ ឬច្រើននាក់ដោយស្របតាមគតិយុត្តជាធរមាន ។

ជាក់ស្តែង ទោះបីជាមានក្រមរដ្ឋប្បវេណីបានចែងអំពីការបែងចែកទ្រព្យសម្បត្តិ ឬហៅថាសន្តតិកម្មយ៉ាងណាក្តី ក្នុងរង្វង់គ្រួសារនៅតែកើតមានទំនាស់កើតឡើង ដោយសារការបែងចែកមត៌កមិនស្មើគ្នា និងការលោភលន់របស់សន្តតិនជនផង។ ហើយការបែងចែកនេះ ភាគច្រើនមិនថាជាទ្រព្យសម្បត្តិរបស់មតកជនឬជននៅរស់នោះទេ ជម្លោះនៅតែកើតមានជារឿយៗ ព្រោះដោយសារការយល់ដឹងរបស់សាធារណៈជនទូទៅនៅមិនទាន់ទូលំទូលាយលើផ្នែកនេះនៅឡើយ ទោះបីជារាជរដ្ឋាភិបាលប្រទេសកម្ពុជា បានតាក់តែងក្រមរដ្ឋប្បវេណីហើយក៏ដោយនោះ ។ យើងដឹងហើយ សង្គមមានការវិវត្តន៍ ប្រទេសជាតិកាន់តែមានការអភិវឌ្ឍ ដូច្នេះក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ក៏ត្រូវទាមទារឲ្យមានការវិវត្តតាមសង្គមផងដែរ។

ដោយយោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានបញ្ញត្តិយ៉ាងក្បោះក្បាយអំពីជនដែលមានសិទ្ធិក្នុងការទទួលបន្តនូវចំណែកមត៌កដែលបន្សល់ទុកដោយមតកជនមានអាទិភាពសំដៅដល់ជនដែលច្បាប់បានកំណត់តាមលំដាប់លំដោយនិងកំណត់យកសន្តតិជនខ្សែស្រឡាយញាតិផ្ទាល់របស់មតកជន មិនមែនជាញាតិពន្ធឡើយ។ ចំណែកឯសន្តតិជនដែលជាកូនជាទូទៅមានកាតព្វកិច្ច តួយ៉ាងដូចជាមើលថែទំនុកបម្រុង មតកជននៅពេលគាត់ចាស់ជរា ដោយសារជាទំលាប់និងកាតព្វកិច្ចរបស់កូនក្នុងការមើលថែរតបស្នងសងគុណឪពុកម្តាយ នោះសន្តតិជននឹងទទួលបានចំណែកមត៌កតាមចំណែក ហើយពេលខ្លះសន្តតិជនក៏អាចទទួលបានចំណែកផងដែរសោះនៅក្នុងទម្រង់ជាផលប្រយោជន៍ពិសេសឬជាប្រទានកម្ម ដែលពួកគេទទួលបាននាពេលរៀបអាពាហ៍ពិពាហ៍ឬក្នុងឱកាសពិសេសណាមួយដែលជាអំណោយពីមតកជនកាលគាត់នៅមានជីវិតជាដើម ។

ក្រៅពីសន្តតិជនទាំងបីថ្នាក់ដែលអាចស្នងមត៌កនៅពេលមតកជនបានស្លាប់ ជនដែលមាននិស្ស័យពិសេសជាមួយមតកជនក៏អាចមានសិទ្ធិស្របច្បាប់និងអាចទទួលបានចំណែកមត៌កបានដែរ បើជាបុគ្គលដែលបានជួយទុក្ខធុរៈពេលមតកជននៅរស់និងជាបុគ្គលដែលមតកជនមានឆន្ទៈក្នុងការផ្តល់ចំណែកមត៌កឲ្យ។

មួយវិញទៀត ជនដែលច្បាប់មិនអាចបំបាត់ចោលបាននោះគឺសហព័ទ្ធ(ប្តីឬប្រពន្ធ)របស់មតកជន មានសិទ្ធិថែរក្នុងការទទួលបានចំណែកមត៌ករបស់មតកជន បើសិនជាសហព័ទ្ធមិនបានប្រព្រឹត្តិខុសឆ្គងដែលត្រូវបានចាត់ថ្នាក់ជាអភ័ព្វបុគ្គល ឬជនដែលផ្តាច់ចេញពីចំណែកមត៌កជាអាទិ៍។ ជាមួយគ្នានេះដែរ ក្រមរដ្ឋប្បវេណីបានកំណត់យកគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ គឺសន្តតិជនទាំងអស់មានសិទ្ធិអាទិភាពក្នុងការបង្ហាញឆន្ទៈរបស់ខ្លួនចំពោះការស្នង មត៌កដោយអាចទទួលយល់ព្រមឬបោះបង់កេរមត៌កនោះទាំងស្រុង

ប្រសិនបើសន្តតិជនយល់ថា មានកាតព្វកិច្ច(បំណុល)ច្រើនពេកដែលអាចខ្លួនមិនអាចទទួលយកបានឬអាចធ្វើឲ្យប៉ះពាល់ដល់ជីវភាពប្រចាំថ្ងៃខ្លួន ។

ព្រមជាមួយគ្នានេះ បើក្នុងករណីដែលសន្តតិជនណាម្នាក់បានអវត្តមាននៅពេលបែងចែកមត៌កនិងមិនបានចំណែករបស់ខ្លួន សន្តតិជននោះមានសិទ្ធិក្នុងការទាមទារភាគបម្រុងរបស់ខ្លួន ឲ្យតែសន្តតិជនគិតថាមានការរំលោភបំពានពីសន្តតិជនផ្សេង។ បើមិនមានការស្រុះស្រួលគ្នាលើការបែងចែកចំណែកមត៌កនោះ ទំនាស់និងកើតឡើងមានឡើងរវាងសហសន្តតិជនទាំងនោះនិងអាចឈានដល់ការប្តឹងផ្តល់គ្នាឡើងតុលាការទៀតផងដើម្បីឲ្យតុលាការជួយវិនិច្ឆ័យនិងចេញសេចក្តីសម្រេចស្របតាមច្បាប់បានចែងក្នុងក្រមរដ្ឋប្បវេណីដោយធ្វើការបែងចែកដោយសុក្រឹត្យភាព តម្លាភាព និងយុត្តិធម៌ជូនសហសន្តតិជនទាំងនោះដោយសន្តិវិធី រួមទាំងបង្រួបបង្រួមបងប្អូន សាច់ញាតិជាសន្តតិជនឲ្យចេះថែរក្សានិងរក្សាគ្នាទៅវិញទៅមកក្នុងគ្រួសារ។

សរុបរួមមក សន្តតិកម្មតាមច្បាប់ពិតជាមានសារៈសំខាន់សម្រាប់ការអនុវត្តនៅក្នុងសង្គមយើងបច្ចុប្បន្ន ហើយក៏ជាចំណេះដឹងដែលមិនអាចខ្វះបានសម្រាប់ប្រជាពលរដ្ឋគ្រប់រូបអំពីការផ្ទេរចំណែកមត៌ករបស់មតកជន ឬហៅថាសន្តតិកម្មតាមច្បាប់នេះ ព្រោះដើម្បីឲ្យជនគ្រប់រូបបានទទួលការបែងចែកនូវមត៌កដោយសមភាព យុត្តិធម៌ និងគោរពតាមឆន្ទៈរបស់មតកជន ជាពិសេសដើម្បីឲ្យការបែងចែងម៌តកនៅប្រទេសកម្ពុជា ជៀសផុតពីវិវាទនិងការប៉ះពាល់ដល់ផលប្រយោជន៍លើសន្តតិជនផ្សេងទៀតនិងចូលរួមចំណែកកាត់បន្ថយលើវិវាទមត៌ករវាងញាតិស្រឡាយខ្លួនឯងនិងជាពិសេសជួយលើកតម្កើងការអនុវត្តសន្តតិកម្មតាមច្បាប់នៅកម្ពុជាឲ្យបានកាន់តែទូលំទូលាយជាងមុនទៀត។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីនាងខ្ញុំទាំងពីរបានបកស្រាយនូវប្រធានបទខាងលើរួចមកបញ្ញត្តិច្បាប់និងបទដ្ឋានគតិយុត្ត ទាំងឡាយដែលមានចែងក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ និងសេចក្តីកំណត់មាត្រា នីមួយៗនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ភាគ៦ គន្ថីទី៨ និងគន្ថីទី៩ បានសបញ្ជាក់ឲ្យឃើញថា ពិតជាមានលក្ខណៈសម្បត្តិពេញលេញនិងគ្រប់គ្រាន់ក្នុងការយកមកអនុវត្តការក្នុងបែងចែកចំណែកមត៌កនៅ ក្នុងសង្គមយើងសព្វថ្ងៃនេះ ។ ដោយឡែកនាពេលអនាគតកាល ប្រទេសជាតិនឹងមានរីកចម្រើនជាងមុន ដូច្នេះ យើងមិនអាចកំណត់វិសាលភាពនៃច្បាប់និងលិខិតគតិយុត្តនានា អាចអនុវត្តបានស្របគ្រប់កាលៈទេសៈ នោះទេ។

ក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវ នាងខ្ញុំមានមតិយោបល់បន្តិចបន្តួចនិងអនុសាសន៍ខ្លះៗដូចមានរៀបរាប់ បន្តទៀតនេះដើម្បីចូលរួមចំណែកធ្វើឲ្យការបែងចែកចំណែកមត៌កនៅព្រះរាជាណាចក្រកម្ពុជាកាន់តែល្អប្រសើរ។ មតិយោបល់នេះបានផ្តួចផ្តើមឡើងបន្ទាប់ពីពួកយើងបានសិក្សាអំពីសន្តតិកម្មនេះមកពួកយើងអាចសង្កេត ឃើញថា សន្តតិកម្មតាមច្បាប់ អាចកើតមានឡើងបាន លុះត្រាតែមិនមានវត្តមានលិខិតមតកសាសន៍របស់ មតកជនដូចនេះសហសន្តតិជនអាចធ្វើការបែងចែកបែកមត៌កដោយការព្រមព្រៀងគ្នាតាមរយៈវិធីសាស្ត្រ ពិភាក្សាដោយសន្តិវិធី ដោយយកគោលការណ៍ ឈ្នះ-ឈ្នះ ឬការបែងចែកតាមរយៈមូលដ្ឋានរូបមន្តច្បាប់ជា ដើម។ ការបែងចែកនេះគ្រប់សន្តតិជនទាំងអស់ត្រូវឈរលើមូលដ្ឋានច្បាប់បានបញ្ញត្តិទុក ព្រោះនីតិករបានគិត គូរយ៉ាងដិតដល់ដល់គ្រប់ភាគីពាក់ព័ន្ធក្នុងការទទួលបានផលប្រយោជន៍ទាំងលក្ខខណ្ឌនៃលំដាប់សន្តតិជន និងកាតព្វកិច្ចនានា ដោយភាពសមធម៌ យុត្តិធម៌ និងសាមគ្គីភាពសម្រាប់សន្តតិជន។ ក្រៅពីជម្រើសខាងលើ នេះ សន្តតិជនអាចដំណើរការទៅតាមរយៈតុលាការ បើពុំមានការចុះសម្រុងនិងឯកភាពគ្នានោះ ។ ប៉ុន្តែគួរ បញ្ជាក់ផងដែរ ការប្តឹងទៅតុលាការ មិនមែនជាជម្រើសដ៏ល្អនោះ ព្រោះថា វានឹងអាចប៉ះពាល់ដល់ទំនាក់ទំនង ញាតិ ភាពជាបងប្អូន និង ពិសេសខាតទាំងពេលវេលា លុយកាក់ ហើយពេលខ្លះអាចធ្វើឲ្យមានការកាត់កាល ចោលរវាងសាច់ញាតិជា ដើម។ ដូច្នេះមុនសម្រេចចិត្តដឹកដៃបងប្អូនសាច់ញាតិខ្លួនឯងប្តឹងទៅតុលាការដើម្បី ចង់បានចំណែកឪពុកម្តាយរបស់ខ្លួននោះ ត្រូវតែពិចារណាឲ្យបានវែងឆ្ងាយ ដូចពាក្យចាស់តែនិយាយថា គិត មុនគូរ ជាដើម ។

ជាចុងក្រោយ យើងទាំងពីរអនុញ្ញាតស្នើសុំទៅស្ថាប័ននានាទាក់ទងនឹងវិស័យច្បាប់នៅប្រទេសកម្ពុជា ដូចជា ស្ថាប័ននីតិប្បញ្ញត្តិចំពោះបញ្ហានេះសូមអនុញ្ញាតឲ្យមានការសិក្សា និងបកស្រាយបន្ថែម ដើម្បីឲ្យ ប្រធាន បទ **សន្តតិកម្មតាមច្បាប់** នេះស្របតាមកាលៈទេសៈនៃសង្គមជាតិសម័យទំនើបមួយនេះ និងមានការបក ស្រាយឲ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីឲ្យអ្នកសិក្សាជំនាន់ក្រោយបានជ្រាបកាន់តែច្បាស់បន្ថែមទៀត។

# ឯកសារយោង

# ឯកសារយោង

## ១.បទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- ច្បាប់ភូមិបាលឆ្នាំ២០០១
- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
- ច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១១
- ច្បាប់ស្ដីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស

## ២.សៀវភៅផ្សេងៗ

- សេចក្ដីកំណត់មាត្រានីមួយៗក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧,គន្លឹ៨និង៩ រៀបរៀងដោយក្រុមការងារជប៉ុន ដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មាទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី ឆ្នាំ២០១០។
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ ,សទ្ទានុក្រមផ្នែករដ្ឋប្បវេណី
- សទ្ទានុក្រមផ្នែករដ្ឋប្បវេណី ,រៀបរៀងដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះពុម្ពដោយទីស្ដីការគណៈរដ្ឋមន្ត្រីនៅឆ្នាំ ២០០៧

## ៣. ស្នាដៃនិពន្ធ

- លោក ខាន់ សុខា និង លោកស្រី ឌី លីឡា, សន្តតិកម្មនិងអច្ច័យទាន
- លោកមេធាវី អ៊ីវ ប៉ូលី ,សៀវភៅ សន្តតិកម្ម ឆ្នាំ២០១០
- លោកមេធាវី អ៊ីវ ប៉ូលី, វិភាគទានច្បាប់(ចែករំលែក) ,ការបែងចែកមត៌ក,១៥ មករា ២០១៨
- លោកមេធាវី អ៊ីវ ប៉ូលី លោកស្រីមេធាវី ទេព បូផល,ដកស្រង់ពី,សន្តតិជន

# ឧបសម្ព័ន្ធ

# ក្រមរដ្ឋប្បវេណី
# នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# គន្ថីទី ៨
# សន្តតិកម្ម

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ផ្នែកទី ១
### ការចាប់ផ្តើមធ្វើសន្តតិកម្ម

**មាត្រា ១១៤៥.-** មូលហេតុនៃការចាប់ផ្តើមធ្វើសន្តតិកម្ម

១-សន្តតិកម្ម ត្រូវចាប់ផ្តើមដោយមរណភាពរបស់មតកជន ។

២-សន្តតិកម្ម ត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ឬ ដោយផ្អែកតាមឆន្ទៈរបស់មតកជន ។ សន្តតិកម្មដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ហៅថា សន្តតិកម្មតាមច្បាប់ សន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជន ហៅថា សន្តតិកម្មមានបណ្តាំ ។

**មាត្រា ១១៤៦.-** ទីកន្លែងចាប់ផ្តើមសន្តតិកម្ម

សន្តតិកម្ម ត្រូវចាប់ផ្តើមនៅលំនៅឋានរបស់មតកជន នាពេលទទួលមរណភាព ។

### ផ្នែកទី ២
### អានុភាពនៃសន្តតិកម្ម

**មាត្រា ១១៤៧.-** ការទទួលបន្តនូវមតិក

១-សន្តតិជន ត្រូវទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ចទាំងអស់ ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន ចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្ម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសិទ្ធិ និង ករណីយកិច្ចផ្តាច់មុខទាំងស្រុងរបស់មតកជន ។

២-ចំពោះកម្មសិទ្ធិលើវត្ថុសម្រាប់ជំនឿសាសនា និង ចេតិយ ឬ ចលនវត្ថុដែលជារតនសម្បត្តិគ្រួសារនៃបុព្វជន បើមានជនដែលត្រូវទទួលបន្តកម្មសិទ្ធិទាំងនោះ ដូចជាជន

ដែលត្រូវដឹកនាំពិធីបុណ្យនៃបុព្វជន ដោយយោងតាមការកំណត់របស់មតកជន ជននោះត្រូវទទួលបន្ត ។ បើមតកជនពុំបានកំណត់ទេ ជនដែលត្រូវដឹកនាំពិធីបុណ្យនៃបុព្វជនត្រូវទទួលបន្តនូវកម្មសិទ្ធិទាំងនោះ ដោយយោងតាមទំនៀមទម្លាប់ ។ ប្រសិនបើទំនៀមទម្លាប់មិនច្បាស់លាស់ទេ តុលាការត្រូវកំណត់ជនដែលត្រូវទទួលបន្តនោះ ។

**មាត្រា ១១៤៨.-** ការទទួលបន្តសិទ្ធិលើទ្រព្យសម្បត្តិ ក្នុងករណីដែលមានសន្តតិជនច្រើននាក់

១-ប្រសិនបើមានសន្តតិជនច្រើននាក់ សហសន្តតិជនម្នាក់ៗ ត្រូវទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ច តាមសមាមាត្រនៃចំណែកមត៌កនោះ ។ ប៉ុន្តែ សិទ្ធិ ឬ ករណីយកិច្ចដែលមិនអាចបែងចែកបាន តាមលក្ខណៈនៃសិទ្ធិ ឬ ករណីយកិច្ចនោះ ត្រូវទទួលបន្ត ដោយអវិភាគីយ៍ ។

២-មត៌កនេះ នឹងត្រូវស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន ។

## ផ្នែកទី ៣
## ភាពគ្រប់លក្ខណសម្បត្តិជាសន្តតិជន

**មាត្រា ១១៤៩.-** បុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ជាសន្តតិជន ជាអាទិ៍

១-មានតែជនដែលមានជីវិតរស់នៅ នាពេលចាប់ផ្តើមសន្តតិកម្ម ក្រៅពីបុគ្គលដែលបញ្ញត្តចាប់ពីមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) រហូតដល់មាត្រា ១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍) ខាងក្រោមនេះទេ ទើបអាចទទួលសន្តតិកម្មបាន ។

២-ទោះមានបញ្ញត្តិដូចកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៩ (ទារកនៅក្នុងគភ៌) នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះទារកដែលនៅក្នុងគភ៌ ។

**មាត្រា ១១៥០.–** អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍

បុគ្គលដែលបានកំណត់ដូចខាងក្រោមនេះ ពុំអាចក្លាយជាសន្តតិជន ឬ ពុំអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បានឡើយ :

ក-បុគ្គលដែលបានទទួលទោស ដោយមានចេតនាធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាតលើមតកជន ឬ លើជនដែលមានលំដាប់សន្តតិកម្មមុន ឬ លំដាប់ស្មើគ្នា ទោះដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី ។

ខ-បុគ្គលដែលដឹងអំពីការសម្លាប់មតកជន តែមិនបានរាយការណ៍ ឬ មិនបានប្តឹង ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះ មិនអាចវិនិច្ឆ័យអំពើល្អ ឬ អាក្រក់បាន ឬ ករណីដែលអ្នកសម្លាប់ជាសហព័ទ្ធ ឬ ញាតិលោហិតខ្សែផ្ទាល់របស់បុគ្គលនោះ ។

គ-បុគ្គលដែលបានរារាំងមតកជនក្នុងការធ្វើ លុបចោល ឬ កែប្រែមតក-សាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង ។

ឃ-បុគ្គលដែលបានឱ្យមតកជនធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង ។

ង-បុគ្គលដែលបានក្លែង កែបន្លំ បំផ្លាញចោល ឬ លាក់ទុកនូវលិខិតមតក-សាសន៍ស្តីពីសន្តតិកម្ម របស់មតកជន ។

**មាត្រា ១១៥១.–** ការផ្តាច់មត៌កពីសន្តតិជន

១-មតកជន កាលនៅរស់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យផ្តាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ មិនឱ្យទទួលសន្តតិកម្មបាន បើជនដែលត្រូវបានសន្មតថាជាសន្តតិជនដែលមានភាគបម្រុង បានប្រព្រឹត្តនូវសកម្មភាពដែលបានកំណត់ខាងក្រោមនេះ :

ក-បើបានធ្វើបាបចំពោះមតកជន ។

ខ-បើបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ ។

គ-បើអាចមកមើលថែទាំមតកជននៅពេលដែលមានជម្ងឺ ប៉ុន្តែមិនមកថែទាំ ។

ឃ-បើត្រូវបានទទួលសាលក្រម ឬ សាលដីកាផ្តន្ទាទោសឱ្យជាប់ពន្ធនាគារមួយ

ជីវិត ។

ង-បើបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឱ្យកត់សំគាល់ ជាអាទិ៍ ។

មតកជន ក៏អាចបង្ហាញឆន្ទៈអំពីការផ្តាច់មត៌កនេះ តាមមតកសាសន៍បានដែរ ។

២-ជនដែលត្រូវបានសន្មតថាជាសន្តតិជនដែលបានទទួលការទាមទារផ្តាច់មត៌កនេះ អាចធ្វើវិវាទអំពីអត្ថិភាព ឬ នត្ថិភាព នៃមូលហេតុនៃការផ្តាច់មត៌កនេះ នៅក្នុងការសម្រេចសេចក្តីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

**មាត្រា ១១៥២.-** ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍

បើមតកជនបានធ្វើមតកសាសន៍ដូចបានកំណត់នៅក្នុងមាត្រា ១១៥១ (ការផ្តាច់មត៌កពីសន្តតិជន) ខាងលើនេះ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវដាក់ពាក្យសុំទៅតុលាការឱ្យផ្តាច់មត៌កពីសន្តតិជន ដោយគ្មានការយឺតយ៉ាវ នៅក្រោយពេលដែលមតកសាសន៍នោះបានបង្កើតអានុភាព ។ ក្នុងករណីនេះ ការផ្តាច់មត៌កពីសន្តតិជននោះ មានអានុភាពប្រតិសកម្ម ចាប់ពីពេលដែលមតកជនបានទទួលមរណភាព ។

**មាត្រា ១១៥៣.-** ការកាន់កាប់មត៌ក ដោយអភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍

បើបុគ្គលដែលជាអភ័ព្វបុគ្គលនៃសន្តតិកម្ម ឬ បុគ្គលដែលមិនអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បាន តាមបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) ឬ បុគ្គលដែលត្រូវបានកាត់ផ្តាច់ពីសន្តតិកម្ម តាមបញ្ញត្តិនៃមាត្រា ១១៥១ (ការផ្តាច់មត៌កពីសន្តតិជន) និង មាត្រា ១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមតក-សាសន៍) ខាងលើនេះ កំពុងកាន់កាប់មត៌ក បុគ្គលនោះត្រូវបានចាត់ទុកថាជាអ្នកកាន់កាប់ដោយទុច្ចរិត គិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម ។

**មាត្រា ១១៥៤.-** ការលុបចោលនូវការផ្តាច់មត៌កពីសន្តតិជន

១-មតកជន កាលនៅរស់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យលុបចោលនូវការផ្តាច់មត៌កពីជន ដែលត្រូវបានសន្មតថាជាសន្តតិជន នៅពេលណាក៏បាន ។

២-បញ្ញត្តិនៃមាត្រា ១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍) ខាង

លើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការលុបចោលនូវការផ្តាច់មត៌កពីសន្តតិ-ជន ។

**មាត្រា ១១៥៥.-** ករណីដែលសន្តតិជនជាអាទិ៍ ជាជនជាតិបរទេស

១-បើសន្តតិជន ឬ បុគ្គលដែលទទួលទ្រព្យសម្បត្តិតាមមតកសាសន៍ ពុំមានសញ្ជាតិជាខ្មែរទេ ជននោះពុំអាចទទួលដីធ្លី តាមសន្តតិកម្ម ឬ តាមអច្ច័យទានបានឡើយ ។

២-បើសហសន្តតិជនម្នាក់ ឬ ច្រើននាក់ ពុំមានសញ្ជាតិជាខ្មែរទេ មត៌កត្រូវបែងចែក ដោយពិចារណាយ៉ាងហ្មត់ចត់ទៅលើបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

៣-បើសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ ពុំមានសញ្ជាតិជាខ្មែរទេ ដីធ្លីនៅក្នុងចំណោមមត៌ក ត្រូវក្លាយជានីតិបុគ្គល ហើយការគ្រប់គ្រង និង ការចាត់ចែងដីធ្លីនោះ ត្រូវធ្វើឡើងដោយសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ ។

៤-បើសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ បានលក់ដីធ្លី ក្នុងនាមជាម្ចាស់សិទ្ធិចាត់ចែងមត៌ក ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ បានយល់ព្រមទាំងស្រុង ឬ បានយល់ព្រមដោយមានកម្រិត ថ្លៃលក់ដីធ្លីនោះត្រូវក្លាយជាមត៌ក ហើយនីតិបុគ្គលមត៌កដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវរលត់ ។

៥-បើសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ មិនបានលក់ដីធ្លី ក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ បានយល់ព្រមទាំងស្រុង ឬ បានយល់ព្រមដោយមានកម្រិត ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៤ ខាងលើនេះ កម្មសិទ្ធិលើដីធ្លីនោះ ត្រូវបានធ្វើសន្តតិកម្មដោយសន្តតិជនដែលមានលំដាប់ក្រោយបន្ទាប់ ហើយដែលមានសញ្ជាតិជាខ្មែរ ។ ក្នុងករណីនេះនីតិបុគ្គលមត៌កដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវបានចាត់ទុកថាគ្មានអត្ថិភាព ។

## ជំពូកទី ២
## សន្តតិកម្មតាមច្បាប់

### ផ្នែកទី ១
### សន្តតិជន

**មាត្រា ១១៥៦.-** សន្តតិជនដែលមានលំដាប់ទី ១

១-កូនរបស់មតកជន ត្រូវក្លាយជាសន្តតិជនដែលមានលំដាប់ទី ១ ។

២-កូនរបស់មតកជន ទោះបីជាកូនបង្កើតក្តី ឬ កូនសុំក្តី ត្រូវមានចំណែកមត៌ក ស្មើៗគ្នា ។

**មាត្រា ១១៥៧.-** សន្តតិកម្មជំនួស

១-បើកូនរបស់មតកជន បានទទួលមរណភាព នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម ដោយត្រូវនឹងល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) ខាងលើនេះ ឬ ដោយការផ្តាច់មត៌ក កូនរបស់បុគ្គលនោះ ត្រូវក្លាយទៅជាសន្តតិជនជំនួស ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះបុគ្គលដែលមិនមែនជាបច្ឆាញាតិផ្ទាល់របស់មតកជន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តជាបន្តបន្ទាប់ ចំពោះករណីដែលមានមូលហេតុដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះ ចំពោះអ្នកទទួលសន្តតិកម្មជំនួស ។

**មាត្រា ១១៥៨.-** ចំណែកមត៌ក ក្នុងករណីនៃសន្តតិកម្មជំនួស

ចំណែកមត៌ក របស់បច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន ដោយយោងតាមបញ្ញត្តិនៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) ខាងលើនេះ ត្រូវដូចគ្នានឹងចំណែកមត៌កដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិផ្ទាល់នោះត្រូវទទួលបាន ។ ប្រសិនបើបច្ឆាញាតិផ្ទាល់មានចំនួនច្រើននាក់ ចំណែកមត៌កដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិផ្ទាល់រៀងៗខ្លួន

នោះ ត្រូវទទួលបាន ត្រូវបែងចែកស្មើៗគ្នា រវាងបច្ឆាញាតិទាំងឡាយនោះ ។

**មាត្រា ១១៥៩.-** សន្តតិជនដែលមានលំដាប់ទី ២

១-បើមតកជនពុំមានបច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ បុព្វញាតិផ្ទាល់របស់មតកជននោះ ត្រូវក្លាយជាសន្តតិជន ។ ប៉ុន្តែ រវាងបុគ្គលដែលមានថ្នាក់ញាតិខុសគ្នា ត្រូវយកបុព្វញាតិដែលនៅជិតជាង ជាមុន ។

២-ប្រសិនបើបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន មានចំនួនច្រើននាក់ បុព្វ-ញាតិផ្ទាល់នីមួយៗត្រូវទទួលចំណែកមត៌កស្មើៗគ្នា ។

**មាត្រា ១១៦០.-** សន្តតិជនដែលមានលំដាប់ទី ៣

១-បើមតកជនពុំមានទាំងបច្ឆាញាតិផ្ទាល់ ទាំងបុព្វញាតិផ្ទាល់ ដែលត្រូវក្លាយជាសន្តតិជនទេ បងប្អូនបង្កើតរបស់មតកជននោះ ត្រូវក្លាយជាសន្តតិជន ។

២-បើបងប្អូនបង្កើតមានចំនួនច្រើននាក់ បងប្អូនបង្កើតម្នាក់ៗត្រូវបានចំណែកមត៌កភាគស្មើៗគ្នា ។ ប៉ុន្តែ ចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុក ឬ ម្ដាយតែម្ខាងដូចគ្នា ត្រូវមាន ១ ភាគ ២ (មួយភាគពីរ) នៃចំណែកមត៌ករបស់បងប្អូនដែលមានឪពុក និង ម្ដាយទាំងសងខាងដូចគ្នា ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) និង បញ្ញត្តិនៃមាត្រា ១១៥៨ (ចំណែកមត៌ក ក្នុងករណីនៃសន្តតិកម្មជំនួស) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបងប្អូនបង្កើតរបស់មតកជនដែលត្រូវក្លាយជាសន្តតិជន យោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ បានទទួលមរណភាពនៅមុនពេលចាប់ផ្ដើមសន្តតិកម្ម ។

# ផ្នែកទី ២
# សន្តតិកម្មរបស់សហព័ទ្ធ

**មាត្រា ១១៦១.-** សន្តតិកម្មរបស់សហព័ទ្ធ

១-សហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច ។

២-នៅក្នុងករណីដែលសហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជន បើមានបុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវជាសន្តតិជនដែរ ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) ខាងលើនេះ សហព័ទ្ធនោះត្រូវមានលំដាប់ស្មើគ្នានឹងបុគ្គលនោះ ។

**មាត្រា ១១៦២.-** ចំណែកមត៌ក ក្នុងករណីដែលមានសហព័ទ្ធ

ក្នុងករណីដែលសហព័ទ្ធរបស់មតកជន និង បុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវក្លាយជាសន្តតិជន ចំណែកមត៌ករបស់សន្តតិជន នឹងត្រូវមានតាមកំណត់ដូចខាងក្រោមនេះ :

ក-បើសហព័ទ្ធ និង បច្ឆាញាតិផ្ទាល់របស់មតកជននោះ ជាសន្តតិជន សហព័ទ្ធ និង កូននីមួយៗ របស់មតកជននោះ នឹងត្រូវទទួលចំណែកមត៌កស្មើគ្នា ។

ខ-បើសហព័ទ្ធ និង ឪពុក ម្ដាយរបស់មតកជន ជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធ ត្រូវជា ១ ភាគ ៣ (មួយភាគបី) ឯចំណែកមត៌ករបស់ឪពុក ម្ដាយ ត្រូវជា ២ ភាគ ៣ (ពីរភាគបី) ។ ប៉ុន្តែ បើឪពុក ឬ ម្ដាយ របស់មតកជនតែម្នាក់នៅរស់ ឪពុកម្ដាយនោះ និង សហព័ទ្ធ ត្រូវបានចំណែកមត៌កស្មើគ្នា ។

គ-បើសហព័ទ្ធ និង បុព្វញាតិផ្ទាល់ក្រៅពីឪពុក ម្ដាយរបស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសបុគ្គលទាំងនោះ ជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធ ត្រូវជា ១ ភាគ ២ (មួយភាគពីរ) ឯចំណែកមត៌ករបស់បុព្វញាតិផ្ទាល់ក្រៅពីឪពុក ម្ដាយ របស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសនោះ ត្រូវជា ១ ភាគ ២ (មួយភាគពីរ) ។

# ផ្នែកទី ៣
# ការសម្រួលចំណែកមត៌ក

**មាត្រា ១១៦៣.-** ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស

១-នៅក្នុងចំណោមសហសន្តតិជនទាំងអស់ បើមានបុគ្គលណាដែលបានទទួលប្រទានកម្ម នៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬ ហេតុការណ៍ផ្សេងទៀត ឬ ដើម្បីមូលធននៃជីវភាពរស់នៅ ឬ ដែលបានទទួលអច្ច័យទានពីមតកជននោះ តម្លៃសរុបនៃមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ដោយបូកបញ្ចូលនូវតម្លៃនៃប្រទានកម្ម ត្រូវបានចាត់ទុកថាជាមត៌ក ហើយចំនួនទឹកប្រាក់ដែលនៅសល់ ក្រោយពីដកតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាននោះ ចេញពីចំណែកមត៌កដែលត្រូវបានគណនាតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) និង ផ្នែកទី ២ (សន្តតិកម្មរបស់សហព័ទ្ធ) គឺជាចំណែកមត៌ករបស់បុគ្គលនោះ ។

២-បើតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាន ស្មើគ្នានឹងតម្លៃនៃចំណែកមត៌ក ឬ លើសពីតម្លៃនៃចំណែកមត៌ក សហសន្តតិជននោះពុំអាចទទួលយកចំណែកមត៌កនោះបានឡើយ ។

**មាត្រា ១១៦៤.-** តម្លៃនៃប្រទានកម្ម

បើបដិគ្គាហក បានចាត់ចែងទ្រព្យសម្បត្តិដែលខ្លួនទទួលដោយប្រទានកម្ម នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ បើទ្រព្យសម្បត្តិនោះត្រូវបានបាត់ ឬ វិនាស នៅមុនពេលចាប់ផ្តើមសន្តតិកម្ម តម្លៃនៃប្រទានកម្មដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) ខាងលើនេះ ត្រូវគណនា ដោយគិតតម្លៃនៅពេលដែលបានចាត់ចែង ឬ នៅពេលបាត់បង់ ឬ វិនាសនោះ ។ ប្រសិនបើតម្លៃនៃប្រទានកម្មនោះត្រូវបានផ្លាស់ប្តូរ ដោយសារលទ្ធផលដែលបដិគ្គាហក បានផ្លាស់ប្តូរទ្រព្យសម្បត្តិនោះមួយផ្នែក តម្លៃនៃប្រទានកម្មនោះ ត្រូវគណនាដោយចាត់ទុកថា មានស្ថានភាពដើម នៅពេលចាប់ផ្តើមសន្តតិកម្ម ។ ការប្រាក់ និង ផលចំណេញ ដែលកើតចេញពីប្រទានកម្ម ដែលសន្តតិជននោះបានទទួល ពុំត្រូវគណនាចូលក្នុងតម្លៃនោះឡើយ ។

**មាត្រា ១១៦៥.-** ករណីដែលតម្លៃទទួលផលប្រយោជន៍ពិសេសនោះ លើសពីតម្លៃនៃចំណែកមត៌ក

១-ទោះបីជាតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាន ដែលសហសន្តតិជនបានទទួលមានចំនួនលើសពីតម្លៃនៃចំណែកមត៌កក៏ដោយ សហសន្តតិជននោះ ពុំចាំបាច់បង្វិលមកវិញ នូវទ្រព្យសម្បត្តិដែលទាក់ទងនឹងប្រទានកម្ម ដើម្បីសហសន្តតិជនផ្សេងទៀតឡើយ លើកលែងតែត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំណែកមត៌ករបស់សហសន្តតិជនផ្សេងទៀត ត្រូវមានចំនួនទឹកប្រាក់ តាមការគណនា ដោយយកមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ទៅបែងចែកតាមសមាមាត្រនៃចំណែកមត៌ករបស់សហសន្តតិជននីមួយៗ ដែលត្រូវបានកំណត់ដោយយោងតាមបញ្ញត្តិនៃកថា-ខណ្ឌទី ១ មាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) ខាងលើនេះ ។

**មាត្រា ១១៦៦.-** ភាគនៃវិភាគទាន

១-ក្នុងចំណោមសហសន្តតិជនទាំងឡាយ បើមានបុគ្គលណាបានធ្វើវិភាគទានពិសេស ដើម្បីថែរក្សា ឬ បង្កើនទ្រព្យសម្បត្តិរបស់មតកជន ដោយការផ្តល់សេវកម្មលើកិច្ចការរបស់មតកជន ឬ ដោយការផ្តល់តាវកាលិកលើទ្រព្យសម្បត្តិ ឬ ដោយការថែទាំព្យាបាលមតកជន ឬ ដោយវិធីផ្សេងទៀត តម្លៃដែលដកភាគនៃវិភាគទានរបស់បុគ្គលនោះដែលបានកំណត់តាមការពិភាក្សារបស់សហសន្តតិជន ចេញពីតម្លៃមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ត្រូវចាត់ទុកថាជាមត៌ក ហើយចំនួនទឹកប្រាក់នៃភាគនៅក្នុងសន្តតិកម្ម ដែលបានគណនាតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) និង ផ្នែកទី ២ (សន្តតិកម្មរបស់សហព័ទ្ធ) បូកនឹងភាគវិភាគទាន ត្រូវជាចំណែកមត៌ករបស់ជននោះ ។

២-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់ភាគនៃវិភាគទាន តាមពាក្យសុំរបស់បុគ្គលដែលបានធ្វើវិភាគទានដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នោះ ដោយ

ពិចារណាទៅលើពេល វិធី និង កម្រិតនៃវិភាគទាននោះ ចំនួនទឹកប្រាក់នៃមត៌ក និង ស្ថានភាពទាំងអស់ផ្សេងទៀត ។

៣-ភាគនៃវិភាគទាន មិនអាចឱ្យលើសពីចំនួនទឹកប្រាក់ដែលបានដកចេញនូវតម្លៃនៃអច្ច័យទាន និង តម្លៃនៃទ្រព្យសម្បត្តិ ដែលមតកជនបានកំណត់ថាជាចំណែកមត៌ករបស់សហសន្តតិជន ឬ ជាវិធីបែងចែកមត៌ក ពីចំនួនតម្លៃនៃមត៌ក ដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្មឡើយ ។

៤-ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាចធ្វើបានក្នុងករណីដែលមានពាក្យសុំ ដោយយោងតាមកថាខណ្ឌទី ១ នៃមាត្រា ១២៧០ (ការបែងចែកដោយតុលាការ) ឬ មានពាក្យបណ្តឹង ដោយយោងតាមមាត្រា ១២៧៤ (ការទាមទាររបស់ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមត៌ក) ។

**មាត្រា ១១៦៧.-** ទំនាក់ទំនងជាមួយនឹងតតិយជន

ការសម្រួលចំណែកមត៌កដែលយោងតាមបញ្ញត្តិនៃផ្នែកទី ៣ (ការសម្រួលចំណែកមត៌ក) នេះ មិនអាចយកមកអះអាងនឹងតតិយជនបានឡើយ បើមិនមានល័ក្ខខ័ណ្ឌតតាំងចំពោះលទ្ធផលនៃការបែងចែកមត៌ក ដោយផ្អែកលើការសម្រួលនោះទេ ។

## ជំពូកទី ៣
## សន្តតិកម្មតាមមតកសាសន៍

### ផ្នែកទី ១
### សមត្ថភាពក្នុងការធ្វើមតកសាសន៍

**មាត្រា ១១៦៨.-** បុគ្គលដែលអាចធ្វើមតកសាសន៍បាន

១-បុគ្គលដែលជានីតិជន និង អនីតិជនដែលបានអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬ អំណាចមេបា អាចធ្វើមតកសាសន៍បាន ។

២-បញ្ញត្តិនៃមាត្រា ២៦ (សិទ្ធិលុបចោលសកម្មភាព) និង មាត្រា ៣០ (សិទ្ធិលុប

# ជំពូកទី ៤
# ភាគបម្រុង

## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១២៣០.–** អ្នកមានសិទ្ធិលើភាគបម្រុង

១-បច្ឆាញាតិផ្ទាល់ ឬ ឳពុកម្ដាយ ឬ ជីដូនជីតា និង សហព័ទ្ធរបស់មតកជន អាចធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិ ដូចខាងក្រោមនេះ :

ក-១ ភាគ ៣ (មួយភាគបី) នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីដែលមានតែសន្តតិជនជាឳពុកម្ដាយ ឬ ជីដូន ជីតាប៉ុណ្ណោះ ។

ខ-១ ភាគ ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីផ្សេង ។

២-ក្នុងករណីដែលមានសន្តតិជនច្រើននាក់ អ្នកមានសិទ្ធិលើភាគបម្រុងនីមួយៗ អាចទទួលភាគបម្រុង តាមសមាមាត្រនៃចំណែកមត៌កបាន ។

៣-បញ្ញត្តិនៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) និង មាត្រា ១១៥៨ (ចំណែកមត៌កក្នុងករណីនៃសន្តតិកម្មជំនួស) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះភាគបម្រុង ។

**មាត្រា ១២៣១.–** ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

១-ភាគបម្រុង ត្រូវគណនាដោយយកទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ផ្ដើមធ្វើសន្តតិកម្ម បូកតម្លៃនៃផលប្រយោជន៍ពិសេស ដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) និង តម្លៃនៃទ្រព្យសម្បត្តិប្រទានកម្មដែលបានកំណត់ក្នុងមាត្រា ១២៣២ (ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង) នៃក្រមនេះ ហើយដកនូវចំនួនប្រាក់សរុបនៃកាតព្វកិច្ចចេញ ។

២-សិទ្ធិដែលភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌ ឬ សិទ្ធិដែលអំឡុងពេលមានអត្ថិភាពមិនច្បាស់លាស់ ត្រូវកំណត់តម្លៃនោះ ដោយផ្អែកតាមការវាយតម្លៃរបស់អ្នកវាយតម្លៃ ដែល

ត្រូវបានជ្រើសតាំងដោយតុលាការ ។

៣-កាតព្វកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវរាប់បញ្ចូលផងដែរ នូវសោហ៊ុយបុណ្យសពតាមឋានៈរបស់មតកជន ។

**មាត្រា ១២៣២.–** ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

១-ប្រទានកម្មដែលបានកំណត់ដូចខាងក្រោមនេះ ត្រូវក្លាយជាមូលដ្ឋានក្នុងការគណនាភាគបម្រុង លើកលែងតែផលប្រយោជន៍ពិសេសដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) នៃក្រមនេះ :

ក- ប្រទានកម្មដែលបានធ្វើក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ នៅមុនពេលចាប់ផ្ដើមសន្តតិកម្ម ។

ខ- ក្រៅពីប្រទានកម្មដែលបានកំណត់ក្នុងចំណុច ក ខាងលើនេះ ប្រទានកម្មដែលត្រូវបានធ្វើឡើង ដោយភាគីសងខាងបានដឹងថា នឹងបណ្ដាលឱ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង ។

២-នៅក្នុងជំពូកទី ៤ (ភាគបម្រុង) នេះ ការលើកលែងកាតព្វកិច្ចដោយមិនយកតម្លៃថ្នូរ ត្រូវចាត់ទុកថាជាប្រទានកម្ម ។

**មាត្រា ១២៣៣.–** ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

អច្ច័យទាន ការកំណត់ចំណែកមត៌កតាមមតកសាសន៍ ការទទួលផលប្រយោជន៍ពិសេស និង ប្រទានកម្មដែលបានកំណត់នៅក្នុងមាត្រា ១២៣២ (ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង) ខាងលើនេះ គឺជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។ ប៉ុន្តែ ក្នុងករណីដែលអច្ច័យទានចំពោះសន្តតិជន ការកំណត់ចំណែកមត៌ក និង ការទទួលផលប្រយោជន៍ពិសេស ត្រូវក្លាយជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង កម្មវត្ថុនៃការកាត់បន្ថយនោះ មានត្រឹមតែផ្នែកដែលលើសពីចំនួនទឹកប្រាក់នៃភាគបម្រុងរបស់សន្តតិជននោះប៉ុណ្ណោះ ។

**មាត្រា ១២៣៤.–** ចំនួនទឹកប្រាក់នៃការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

ចំនួនទឹកប្រាក់ដែលអ្នកមានសិទ្ធិលើភាគបម្រុងអាចទាមទារបានដោយការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺជាចំនួនទឹកប្រាក់ដែលត្រូវបានគណនា ដោយយកចំនួនទឹកប្រាក់នៃភាគបម្រុង ដកចំនួនសរុបនៃទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលដោយសន្តតិកម្ម និង ចំនួននៃផលប្រយោជន៍ពិសេស ហើយបូកបញ្ចូលនូវចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលបុគ្គលនោះត្រូវទទួលបន្ទុកដោយសន្តតិកម្ម ។

## ផ្នែកទី ២
## វិធីកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

**មាត្រា ១២៣៥.–** ការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

អ្នកមានសិទ្ធិលើភាគបម្រុង និង អ្នកទទួលបន្តនោះ អាចទាមទារឱ្យធ្វើការកាត់បន្ថយអច្ច័យទាន ជាអាទិ៍ ចំពោះជនដែលបានទទួលទ្រព្យសម្បត្តិ ឬ ផលប្រយោជន៍ដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ត្រឹមកម្រិតដែលចាំបាច់ដើម្បីរក្សាភាគបម្រុងនោះ ។

**មាត្រា ១២៣៦.–** លំដាប់នៃការកាត់បន្ថយ

ប្រទានកម្ម និង ការទទួលផលប្រយោជន៍ពិសេស ពុំអាចកាត់បន្ថយបានឡើយ បើមិនបានកាត់បន្ថយពីអច្ច័យទាន និង ចំណែកមត៌កដែលបានកំណត់តាមមតកសាសន៍ជាមុនទេ ។

**មាត្រា ១២៣៧.–** ការកាត់បន្ថយអច្ច័យទាន ជាអាទិ៍

១-ដំបូង ត្រូវធ្វើការកាត់បន្ថយពីអច្ច័យទាន និង ចំណែកមត៌កដែលបានកំណត់ចំពោះសន្តតិជន នៅក្នុងពេលជាមួយគ្នា ហើយប្រសិនបើនៅតែខ្វះ ត្រូវធ្វើការកាត់បន្ថយពីអច្ច័យទានដែលបានធ្វើចំពោះបុគ្គលផ្សេងក្រៅពីសន្តតិជន ។

២-អច្ច័យទាន ត្រូវធ្វើការកាត់បន្ថយទៅតាមសមាមាត្រនៃតម្លៃរបស់កម្មវត្ថុនោះ ។

បញ្ញត្តិនេះ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះចំណែកមត៌កដែលបានកំណត់តាមវិធីធ្វើអនុប្បទានទ្រព្យសម្បត្តិដែលមានកំណត់ តែមួយចំណុច ឬ ច្រើនចំណុច ។ ប៉ុន្តែក្នុងករណីដែលអច្ច័យទានដែលធ្វើចំពោះសន្តតិជន និង ចំណែកមត៌កដែលបានកំណត់នោះ ជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ផ្នែកដែលលើសពីចំនួនប្រាក់នៃភាគបម្រុងរបស់សន្តតិជននោះ ត្រូវចាត់ទុកថាជាតម្លៃនៃកម្មវត្ថុ ។

៣-ចំណែកមត៌កតាមមតកសាសន៍ ដែលបានកំណត់ជាភាគនៃមត៌ក ត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ដោយធ្វើការផ្លាស់ប្តូរភាគនោះ ។

៤-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ទី ២ និង ទី ៣ ខាងលើនេះក៏ដោយ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈពិសេសផ្សេង ក្នុងមតកសាសន៍ ត្រូវអនុលោមទៅតាមឆន្ទៈនោះ ។

**មាត្រា ១២៣៨.–** លំដាប់នៃការកាត់បន្ថយប្រទានកម្ម ជាអាទិ៍

១-ការកាត់បន្ថយប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេស ត្រូវចាប់ផ្តើមពីប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើក្រោយគេ បន្ទាប់មក ត្រូវធ្វើចំពោះប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើពីមុនមកជាបន្តបន្ទាប់ ។

២-បើបានធ្វើប្រទានកម្ម ឬ ទទួលផលប្រយោជន៍ពិសេស លើសពី ២០ (ម្ភៃ) ឆ្នាំនៅមុនពេលចាប់ផ្តើមសន្តតិកម្ម បដិគ្គាហក ឬ សន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេសនោះអាចបដិសេធនូវការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ។

**មាត្រា ១២៣៩.–** ការសងផលមកវិញ

សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក ក្រៅពីទ្រព្យសម្បត្តិ ឬ ប្រាក់សំណងដែលត្រូវសងមកវិញនោះ ត្រូវសងមកវិញផងដែរនូវផលដែលកើតឡើងក្រោយពីថ្ងៃដែលបានទាមទារឱ្យធ្វើការកាត់បន្ថយ ។

**មាត្រា ១២៤០.–** បន្ទុកនៃការខាតបង់ ដោយអសាធនភាព

ការខាតបង់ដែលកើតឡើងដោយសារអសាធនភាព របស់សហសន្តតិជន អច្ច័យ-

លាភី ឬ បដិគ្គាហក ដែលត្រូវទទួលការកាត់បន្ថយ ត្រូវធ្លាក់ជាបន្ទុករបស់អ្នកមានសិទ្ធិលើភាគបម្រុង ។

**មាត្រា ១២៤១.-** ការកាត់បន្ថយប្រទានកម្មដែលមានភ្ជាប់បន្ទុក

ចំពោះប្រទានកម្មដែលមានភ្ជាប់បន្ទុក ដែលបានដកតម្លៃនៃបន្ទុកចេញពីក្នុងតម្លៃនៃកម្មវត្ថុនោះ អាចទាមទារឱ្យធ្វើការកាត់បន្ថយបាន ។

**មាត្រា ១២៤២.-** ការកាត់បន្ថយចំពោះកិច្ចសន្យា ជាអាទិ៍ ដែលត្រូវចាត់ទុកថាជាប្រទានកម្ម

១-កិច្ចសន្យាដែលបានធ្វើដោយយកតម្លៃថ្នូរមិនត្រឹមត្រូវ ត្រូវចាត់ទុកថាជាប្រទាន-កម្ម តែក្នុងករណីដែលត្រូវបានធ្វើឡើង ដោយភាគីទាំងសងខាងបានដឹងថា នឹងបណ្តាលឱ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុងប៉ុណ្ណោះ ។ ក្នុងករណីនេះ បើអ្នកមានសិទ្ធិលើភាគបម្រុង ទាមទារឱ្យធ្វើការកាត់បន្ថយនោះ អ្នកនោះត្រូវសងតម្លៃថ្នូរនោះមកវិញ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការលើកលែងកាតព្វកិច្ច ដោយយកតម្លៃថ្នូរមិនត្រឹមត្រូវ ។

**មាត្រា ១២៤៣.-** ការកាត់បន្ថយក្នុងករណីដែលបានចាត់ចែងកម្មវត្ថុនៃប្រទានកម្ម

១-បើសហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក ដែលត្រូវទទួលការកាត់បន្ថយបានធ្វើអនុប្បទាននូវកម្មវត្ថុនៃប្រទានកម្ម ទៅឱ្យអ្នកដទៃ ជននោះត្រូវសងចំនួនទឹកប្រាក់ក្នុងកម្រិតនៃតម្លៃនៅពេលដែលបានចាត់ចែងនោះ ទៅឱ្យអ្នកមានសិទ្ធិលើភាគបម្រុង ។ ប៉ុន្តែ ប្រសិនបើអនុប្បទានិកនោះបានដឹងថា នឹងបណ្តាលឱ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង នៅពេលធ្វើអនុប្បទាន អ្នកមានសិទ្ធិលើភាគបម្រុងក៏អាចទាមទារឱ្យកាត់បន្ថយចំពោះអនុប្បទានិកនោះ បានដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក បានបង្កើតសិទ្ធិលើកម្មវត្ថុនៃប្រទានកម្មនោះ ។

**មាត្រា ១២៤៤.-** សំណងដោយបង់តម្លៃ

១-សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក អាចរួចផុតពីកាតព្វកិច្ចនៃការសង បាន ដោយបង់តម្លៃនៃចំណែកមត៌កដែលបានកំណត់ តម្លៃនៃកម្មវត្ថុនៃអច្ច័យទាន ឬ តម្លៃនៃកម្មវត្ថុនៃប្រទានកម្ម ទៅឱ្យអ្នកដែលមានសិទ្ធិលើភាគបម្រុង ត្រឹមកម្រិតដែលត្រូវទទួលការកាត់បន្ថយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រា ១២៤៣ (ការកាត់បន្ថយក្នុងករណីដែលបានចាត់ចែងកម្មវត្ថុនៃប្រទានកម្ម) ខាងលើនេះ ។

## ផ្នែកទី ៣
## ការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយ

**មាត្រា ១២៤៥.-** អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយ

សិទ្ធិទាមទារឱ្យកាត់បន្ថយ ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ១ (មួយ) ឆ្នាំ បានកន្លងហួស គិតចាប់ពីពេលដែលអ្នកមានសិទ្ធិលើភាគបម្រុងបានដឹងអំពីការចាប់ផ្តើមសន្តតិកម្ម និង ការកំណត់ចំណែកមត៌ក អច្ច័យទាន ប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលត្រូវកាត់បន្ថយ ។ សិទ្ធិទាមទារឱ្យកាត់បន្ថយ ក៏ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ៥ (ប្រាំ) ឆ្នាំ បានកន្លងហួស គិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម ។

**មាត្រា ១២៤៦.-** ការបោះបង់ភាគបម្រុង

ភាគបម្រុង អាចបោះបង់ចោលទាំងអស់ ឬ មួយផ្នែកបាន ។ ប៉ុន្តែ ការបោះបង់ភាគបម្រុងនៅមុនពេលចាប់ផ្តើមសន្តតិកម្ម មានអានុភាព លុះត្រាតែបានទទួលការអនុញ្ញាតពីតុលាការ ។

**មាត្រា ១២៤៧.-** ករណីជាសហសន្តតិជន

ការរលត់ដោយអាជ្ញាយុកាល នៃសិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងរបស់សន្តតិជនណាម្នាក់ ឬ ការបោះបង់ភាគបម្រុងដោយសហសន្តតិជនណាម្នាក់ ពុំមានឥទ្ធិពលទៅលើភាគបម្រុងរបស់សហសន្តតិជនផ្សេងទៀតទេ ។

## ជំពូកទី ៥

## ការយល់ព្រម និង ការបោះបង់សន្តតិកម្ម

### ផ្នែកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១២៤៨.-** អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់

១-សន្តតិជន ត្រូវធ្វើការយល់ព្រម ឬ ការបោះបង់សន្តតិកម្ម ទាំងស្រុង ឬ ដោយកម្រិត នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួន បានចាប់ផ្ដើម ។ ប៉ុន្តែ អំឡុងពេលនេះ អាចពន្យារទៀតបាន តាមពាក្យសុំរបស់សន្តតិ-ជនទៅតុលាការ ។

២-សន្តតិជន អាចធ្វើការស្រាវជ្រាវមត៌កបាន នៅមុនពេលធ្វើការយល់ព្រម ឬ ការបោះបង់ ។

**មាត្រា ១២៤៩.-** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនទទួលមរណភាព

បើសន្តតិជនបានទទួលមរណភាព នៅមុនពេលធ្វើការយល់ព្រម ឬ ការបោះបង់ អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជនរបស់ជននោះ បានដឹងថា សន្តតិកម្មចំពោះខ្លួន បានចាប់ផ្ដើម ។

**មាត្រា ១២៥០.-** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនជាអនីតិជន ជាអាទិ៍

បើសន្តតិជន ជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេល

ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់នោះ បានដឹងថា សន្តតិកម្មចំពោះជនដែលជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅនោះ បានចាប់ផ្តើម ។

**មាត្រា ១២៥១.-** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនមិនដឹងអំពីអត្ថិភាពនៃកាតព្វកិច្ច

១-ក្នុងករណីដែលមតកជនមានកាតព្វកិច្ចដែលមានចំនួនទឹកប្រាក់ច្រើន ហើយមិនអាចយកមត៌កទៅសងឱ្យគ្រប់ចំនួនបានទេ បើសន្តតិជនមិនអាចដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ តាមស្ថានភាពនៃជីវភាពរបស់មតកជន ស្ថានភាពនៃទ្រព្យសម្បត្តិរបស់មតកជន ឬ ស្ថានភាពផ្សេងៗទៀត អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជនបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសន្តតិជនបានចាត់ចែងមត៌កដើម្បីសងកាតព្វកិច្ចផ្សេង ដែលត្រូវបានទទួលតាមរយៈសន្តតិកម្ម នៅមុនពេលបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះ បញ្ញត្តិនៃចំណុច ក មាត្រា ១២៥៥ (ការយល់ព្រមទាំងស្រុងតាមច្បាប់) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ។

**មាត្រា ១២៥២.-** ការលុបចោលការយល់ព្រម ឬ ការបោះបង់

១-ការយល់ព្រម និង ការបោះបង់សន្តតិកម្ម មិនអាចលុបចោលបានឡើយ ទោះជានៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ក៏ដោយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងចំពោះការលុបចោលនូវការយល់ព្រម ឬ បោះបង់សន្តតិកម្ម ដោយយកមូលហេតុមានវិការៈក្នុងការបង្ហាញឆន្ទៈឡើយ ។ ប៉ុន្តែ សិទ្ធិលុបចោលនេះ ត្រូវរលត់ បើពុំបានអនុវត្ត នៅក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ

គិតចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិបាន ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលពុំបានអនុវត្តសិទ្ធិលុបចោលនៅក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្តើមធ្វើសន្តតិកម្ម ។

៣-បុគ្គលដែលមានបំណងចង់លុបចោល ការយល់ព្រមដោយកម្រិត ឬ ការបោះបង់ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវដាក់ពាក្យសុំលុបចោលនោះ ទៅតុលាការ ។

**មាត្រា ១២៥៣.-** ការហាមឃាត់មិនឱ្យធ្វើបណ្តឹងចំពោះសន្តតិជន នៅមុនការយល់ព្រម

សិទ្ធិទាមទារចំពោះបេតិកភ័ណ្ឌ ពុំអាចយកមកអះអាងក្នុងបណ្តឹងចំពោះសន្តតិជន នៅមុនពេលយល់ព្រមលើសន្តតិកម្មបានឡើយ ។

## ផ្នែកទី ២
## ការយល់ព្រម

**មាត្រា ១២៥៤.-** ការយល់ព្រមទាំងស្រុង

បើសន្តតិជនបានយល់ព្រមទាំងស្រុង ត្រូវទទួលបន្តដោយគ្មានកម្រិត នូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជននោះ ។

**មាត្រា ១២៥៥.-** ការយល់ព្រមទាំងស្រុងតាមច្បាប់

ក្នុងករណីដែលកំណត់ដូចខាងក្រោមនេះ ត្រូវចាត់ទុកថា សន្តតិជនបានយល់ព្រមទាំងស្រុងតាមច្បាប់ :

ក-បើសន្តតិជនបានចាត់ចែងមត៌កនោះ ទាំងអស់ ឬ មួយភាគ ។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះសកម្មភាពរក្សា និង សកម្មភាពត្រឹមតែជាការគ្រប់គ្រង ។

ខ-បើសន្តតិជនមិនបានយល់ព្រមដោយកម្រិត ឬ បោះបង់ នៅក្នុងអំឡុងពេល

ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ។

គ-ទោះបីជាសន្តតិជនបានយល់ព្រមដោយកម្រិត ឬ បោះបង់ ក៏ដោយ បើសន្តតិជនបានលាក់មត៌កទាំងអស់ ឬ មួយភាគ ឬ បានប្រើប្រាស់មត៌កនោះដើម្បីខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ នៅក្រោយពេលដែលជនដែលបានក្លាយជាសន្តតិជនដោយសារការបោះបង់របស់សន្តតិជនលំដាប់មុនបានយល់ព្រម ។

**មាត្រា ១២៥៦.-** ការយល់ព្រមដោយមានកម្រិត

១-សន្តតិជនអាចយល់ព្រម ដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និង អច្ច័យទានរបស់មតកជនបាន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម តែប៉ុណ្ណោះ ។

២-បើសន្តតិជនមានច្រើននាក់ ការយល់ព្រមដោយកម្រិតនេះ អាចធ្វើបាន លុះត្រាតែសហសន្តតិជននោះបានធ្វើដោយរួមគ្នាទាំងអស់ ។

**មាត្រា ១២៥៧.-** វិធីនៃការយល់ព្រមដោយកម្រិត

សន្តតិជនដែលមានបំណងចង់យល់ព្រមដោយកម្រិត ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ ហើយត្រូវដាក់ពាក្យសុំអំពីការយល់ព្រមដោយកម្រិតនោះ ទៅតុលាការ នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ។

**មាត្រា ១២៥៨.-** អានុភាពនៃការយល់ព្រមដោយកម្រិត

១-ក្នុងករណីដែលសន្តតិជនបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតក-ជន ពុំអាចតាមទាមទារឱ្យសន្តតិជនទទួលខុសត្រូវ ចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជននោះបានឡើយ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ សិទ្ធិ និង កាតព្វកិច្ចរបស់សន្តតិជនដែលមានចំពោះមតកជននោះ ត្រូវចាត់ទុកថាមិនបានរលត់ដោយព្យាកុល-

ភាពឡើយ ។

**មាត្រា ១២៥៩.-** ករណីដែលហេតុនៃការយល់ព្រមតាមច្បាប់ កើតឡើង ក្រោយការយល់ព្រមដោយកម្រិត

១-ក្នុងករណីដែលជនដែលបានធ្វើសន្តតិកម្មតែម្នាក់ឯង បានយល់ព្រមដោយកម្រិត បើសន្តតិជននោះមិនបានសរសេរទ្រព្យសម្បត្តិទាំងអស់ ឬ មួយភាគ នៅក្នុងបញ្ជីសារពើភ័ណ្ឌ ដោយទុច្ចរិត ឬ បើមានហេតុដែលបានកំណត់នៅក្នុងចំណុច ក ឬ គ នៃមាត្រា ១២៥៥ (ការយល់ព្រមទាំងស្រុងតាមច្បាប់) នៃក្រមនេះ កើតឡើងចំពោះសន្តតិ-ជននោះ ត្រូវចាត់ទុកថា សន្តតិជននោះបានយល់ព្រមទាំងស្រុង ហើយសេចក្តីថ្លែងការណ៍នៃការយល់ព្រមដោយកម្រិត មិនបង្កើតអានុភាព តាំងពីដំបូងមក ។

២-បើមានមូលហេតុដូចកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះសហ-សន្តតិជនម្នាក់ ឬ ច្រើននាក់ ដែលបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជនអាចអនុវត្តសិទ្ធិរបស់ខ្លួនទៅលើសហសន្តតិជនម្នាក់ ឬ ច្រើននាក់នោះ ចំពោះចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល ដែលពុំអាចទទួលការសងដោយមតិក តាមចំណែកមតិកនីមួយៗនោះបាន ។

## ផ្នែកទី ៣
## ការបោះបង់

**មាត្រា ១២៦០.-** ការបោះបង់សន្តតិកម្ម

បុគ្គលដែលមានបំណងបោះបង់សន្តតិកម្ម ត្រូវដាក់ពាក្យសុំការបោះបង់សន្តតិកម្មនោះ ទៅតុលាការ ។

**មាត្រា ១២៦១.-** អានុភាពនៃការបោះបង់

បុគ្គលដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូងមក ។

# ជំពូកទី ៦
# ការគ្រប់គ្រង និង ការបែងចែកមត៌ក

## ផ្នែកទី ១
## ការគ្រប់គ្រងមត៌ក

**មាត្រា ១២៦២.–** ការរក្សាទុក និង ការគ្រប់គ្រងមត៌ក

១-សន្តតិជនដែលកាន់កាប់មត៌ក នៅពេលមតកជនបានទទួលមរណភាព ត្រូវរក្សាទុក និង គ្រប់គ្រងមត៌កនោះ រហូតដល់ពេលធ្វើការបែងចែកមត៌ក ។ ប៉ុន្តែ ការរក្សាទុក និង ការគ្រប់គ្រងនេះ ត្រូវអនុលោមតាមបញ្ញត្តិនៃមាត្រា ១២៦៣ (ការរក្សាទុកដោយអ្នកប្រតិបត្តិមតកសាសន៍) ខាងក្រោមនេះ ។

២-ទោះបីជានៅមុនពេលយល់ព្រម ឬ បោះបង់សន្តតិកម្មក៏ដោយ សន្តតិជនត្រូវគ្រប់គ្រងមត៌កនោះ ដោយប្រុងប្រយ័ត្ន ដូចគ្នានឹងទ្រព្យសម្បត្តិផ្ទាល់ខ្លួនផងដែរ ។ ទោះបីជានៅក្រោយពេលបោះបង់សន្តតិកម្មក៏ដោយ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ រហូតដល់ពេលបុគ្គលដែលបានក្លាយជាសន្តតិជន ដោយសារការបោះបង់នោះ អាចចាប់ផ្តើមធ្វើការគ្រប់គ្រងមត៌កនោះបាន ។

**មាត្រា ១២៦៣.–** ការរក្សាទុកដោយអ្នកប្រតិបត្តិមតកសាសន៍

បើបានកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍ហើយ អ្នកប្រតិបត្តិមតកសាសន៍នោះ ត្រូវធ្វើការគ្រប់គ្រងមត៌ក ។ ប៉ុន្តែ ប្រសិនបើមតកសាសន៍ទាក់ទងនឹងទ្រព្យសម្បត្តិដែលមានកំណត់ ត្រូវគ្រប់គ្រងតែទ្រព្យសម្បត្តិនោះប៉ុណ្ណោះ ។

**មាត្រា ១២៦៤.–** អ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន

១-បើគ្មានអ្នកប្រតិបត្តិមតកសាសន៍ គ្រប់គ្រងមត៌កទាំងមូលទេ សន្តតិជន អច្ច័យលាភី ឬ ម្ចាស់បំណុលរបស់មតកជន អាចដាក់ពាក្យសុំទៅតុលាការ ឱ្យធ្វើការជ្រើសតាំងអ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្នបាន រហូតដល់ពេលធ្វើការបែងចែកមត៌ក ។

២-ទោះបីជាមានបញ្ញត្តិនៃមាត្រា ១២៥៣ (ការហាមឃាត់មិនឱ្យធ្វើបណ្ដឹងចំពោះសន្តតិជន នៅមុនការយល់ព្រម) នៃក្រមនេះ ក៏ដោយ អ្នកគ្រប់គ្រងជាបណ្ដោះអាសន្ន ដែលត្រូវបានជ្រើសតាំងដោយបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ គឺជាអ្នកទទួលបន្ទុកក្នុងបណ្ដឹងនោះ ចំពោះសិទ្ធិទាមទារដែលទាក់ទងនឹងមត៌ក នៅក្នុងនាមជាអ្នកទទួលបន្ទុកក្នុងបណ្ដឹងរបស់សន្តតិជននៃមតកជន ដោយបញ្ជាក់ឈ្មោះមតកជននោះផង រហូតដល់ពេលដែលសន្តតិជនយល់ព្រមទទួលសន្តតិកម្មនោះ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ៣ នៃមាត្រា ៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកគ្រប់គ្រងជាបណ្ដោះអាសន្ន ។

**មាត្រា ១២៦៥.-** សោហ៊ុយដែលទាក់ទងទៅនឹងមត៌ក

សោហ៊ុយដែលទាក់ទងទៅនឹងមត៌ក ត្រូវចំណាយចេញពីក្នុងទ្រព្យសម្បត្តិនោះ ។ ប៉ុន្តែ សោហ៊ុយដែលកើតចេញពីកំហុសរបស់សន្តតិជន គឺជាបន្ទុករបស់សន្តតិជននោះ ។

## ផ្នែកទី ២
## ការបែងចែកមត៌ក

**មាត្រា ១២៦៦.-** ការពិភាក្សាបែងចែកមត៌ក

១-សហសន្តតិជនអាចចាប់ផ្ដើមពិភាក្សាបែងចែកមត៌ក នៅពេលណាក៏បាន បើអំឡុងពេល ១ (មួយ) ខែ បានកន្លងផុត ក្រោយពីការចាប់ផ្ដើមសន្តតិកម្ម ។ ប៉ុន្តែ ចំពោះការផ្លាស់ប្ដូរឈ្មោះម្ចាស់សិទ្ធិលើមត៌ក ដោយសារលទ្ធផលនៃការបែងចែកមត៌ក ត្រូវអនុលោមតាមបញ្ញត្តិនៃមាត្រា ១២៧៧ (ការហាមឃាត់មិនឱ្យផ្លាស់ប្ដូរឈ្មោះម្ចាស់សិទ្ធិ) នៃក្រមនេះ ឬ ចំពោះករណីដែលមតកជនហាមឃាត់ការបែងចែកមត៌កតាមមតកសាសន៍ ការបែងចែកមត៌កពុំអាចធ្វើបានឡើយ នៅក្នុងអំឡុងពេលដែលហាមឃាត់នោះ ។

២-ដើម្បីផ្ទេរសិទ្ធិចំពោះវត្ថុតាមការបែងចែកមត៌ក ការបែងចែកត្រូវធ្វើជាលាយល័ក្ខណ៍អក្សរទៅតាមទម្រង់នីមួយៗ ដែលចាំបាច់នៅក្នុងការផ្ទេរសិទ្ធិនោះ ។

**មាត្រា ១២៦៧.–** មូលដ្ឋាននៃការបែងចែក

១-បើពុំបានកំណត់វិធីបែងចែកនៅក្នុងមតកសាសន៍ទេ ការបែងចែកមត៌កនេះ ត្រូវធ្វើដោយពិចារណាទៅលើប្រភេទ និង លក្ខណៈនៃវត្ថុ ឬ សិទ្ធិដែលមាននៅក្នុងមត៌ក ឬ អាយុ មុខរបរ ស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត ស្ថានភាពជីវភាព របស់សហសន្តតិជននីមួយៗ និង ស្ថានភាពផ្សេងទៀត ។

២-ក្នុងករណីដែលការបែងចែកបណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់តម្លៃ បើយល់ឃើញថាសមរម្យ សហសន្តតិជនអាចឱ្យសហសន្តតិជនណាម្នាក់ ធ្វើលទ្ធកម្មទ្រព្យសម្បត្តិនោះបាន ដោយដាក់ល័ក្ខខ័ណ្ឌឱ្យបង់ប្រាក់សម្រួល ចំពោះសហសន្តតិជនផ្សេងទៀត តាមការពិភាក្សា ។

**មាត្រា ១២៦៨.–** សិទ្ធិអាទិភាពរបស់សហព័ទ្ធ

ក្នុងករណីដែលសហព័ទ្ធក្លាយជាសន្តតិជន បើមានទ្រព្យសម្បត្តិដែលទទួលបានជាកម្មសិទ្ធិអវិភាគជាមួយនឹងមតកជន ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ នៅក្នុងការបែងចែកមត៌ក សហព័ទ្ធនេះមានអាទិភាពជាងសហសន្តតិជនផ្សេងទៀត ក្នុងការទទួលយកចំណែកកម្មសិទ្ធិអវិភាគដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិនោះ រហូតដល់គ្រប់ចំនួននៃចំណែកមត៌កនោះ ។

**មាត្រា ១២៦៩.–** សំណងនៃកាតព្វកិច្ចរបស់មតកជន ជាអាទិ៍

បើមតកជនមានកាតព្វកិច្ច សហសន្តតិជនត្រូវបែងចែកមត៌ក ដោយពិចារណាពីការណ៍ថា ខ្លួនត្រូវសងកាតព្វកិច្ចនោះ និង មិនអាចប្តូរភាគបន្ទុកនៃកាតព្វកិច្ចនោះ ដោយគ្មានការយល់ព្រមពីសំណាក់ម្ចាស់បំណុលឡើយ ។

**មាត្រា ១២៧០.–** ការបែងចែកដោយតុលាការ

១-បើការពិភាក្សារវាងសហសន្តតិជន ចំពោះការបែងចែកមត៌ក ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ សហសន្តតិជនណាម្នាក់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យធ្វើការបែងចែកមត៌កនោះបាន ។

២-ក្នុងការបែងចែកមត៌ក ក្រៅពីបញ្ញត្តិចាប់ពីមាត្រា ១២៦៧ (មូលដ្ឋាននៃការបែងចែក) រហូតដល់មាត្រា ១២៦៩ (សំណងនៃកាតព្វកិច្ចរបស់មតកជន ជាអាទិ៍) ខាងលើនេះ តុលាការត្រូវធ្វើការពិចារណានូវទំនៀមទម្លាប់នៅក្នុងតំបន់នោះ និង មតិលើសពីពាក់កណ្តាលរបស់សហសន្តតិជន ។

**មាត្រា ១២៧១.–** ការប្តូរជាប្រាក់ដោយការលក់

ចំពោះទ្រព្យសម្បត្តិដែលមិនអាចទទួលការព្រមព្រៀងអំពីការបែងចែក ឬ អំពីបុគ្គលដែលត្រូវទទួល រវាងសហសន្តតិជនទេ តុលាការអាចលក់ ហើយធ្វើការបែងចែកប្រាក់ដែលបានមកពីការលក់នោះបាន ។

**មាត្រា ១២៧២.–** ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្ម ដោយផ្អែកលើការចាត់ចែងទ្រព្យសម្បត្តិ នៅមុនពេលបែងចែក ជាអាទិ៍

ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្ម ដោយការសងជំនួសការបាត់បង់ ការខូចខាត ឬការបំពានយកកម្មវត្ថុមត៌ក ឬ តាមកិច្ចសន្យាដែលយកមត៌កជាកម្មវត្ថុ ដោយផ្អែកលើសិទ្ធិដែលស្ថិតនៅក្នុងមត៌កនោះ ត្រូវស្ថិតនៅក្នុងមត៌ក ។

**មាត្រា ១២៧៣.–** អានុភាពនៃការបែងចែក

១-ការបែងចែកមត៌ក មានអានុភាពប្រតិសកម្ម គិតចាប់ពីពេលដែលបានចាប់ផ្តើមសន្តតិកម្ម ។ ប៉ុន្តែ ការបែងចែកនេះ ពុំអាចបំពានសិទ្ធិរបស់តតិយជនដែលបានចុះបញ្ជី ឬបានទទួលល័ក្ខខ័ណ្ឌតតាំងបានឡើយ ។

២-សហសន្តតិជននីមួយៗ ត្រូវទទួលយកលិខិតបញ្ជាក់សិទ្ធិដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិដែលខ្លួនបានធ្វើលទ្ធកម្ម ។

**មាត្រា ១២៧៤.–** ការទាមទាររបស់ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមត៌ក

ក្នុងករណីដែលជនដែលបានក្លាយជាសន្តតិជន ដោយសារជននោះត្រូវបានទទួលស្គាល់ ក្រោយពេលមតកជនបានទទួលមរណភាព មានបំណងទាមទារឱ្យបែងចែកមត៌ក

បើសហសន្តតិជនផ្សេងទៀតបានបែងចែកមត៌ក ឬ បានធ្វើការចាត់ចែងផ្សេងទៀតចំពោះមត៌ក ជននោះមានសិទ្ធិទាមទារឱ្យសងដោយតម្លៃតែប៉ុណ្ណោះ ។

**មាត្រា ១២៧៥.–** ល័ក្ខខ័ណ្ឌតតាំង ជាអាទិ៍ នៃការបែងចែកសិទ្ធិលើបំណុល

១-នៅក្នុងការបែងចែកមត៌ក ក្នុងករណីដែលបានបែងចែកសិទ្ធិលើបំណុលដែលមតកជនមាន ទៅតាមភាគក្រៅពីចំណែកមត៌កដែលកំណត់ដោយច្បាប់ បើសហសន្តតិ-ជនទាំងអស់មិនបានជូនដំណឹងពីការបែងចែកនោះ ឬ បើការបែងចែកមត៌កនោះ ត្រូវបានធ្វើដោយលិខិតយថាភូត តែមិនបានបង្ហាញលិខិតនោះ ឬ ប្រគល់លិខិតចម្លងនោះទៅឱ្យកូនបំណុលទេ ពុំអាចតតាំងជាមួយកូនបំណុលបានឡើយ ។

២-កូនបំណុលនៃមតកជន ដែលបានសងសំណងតាមចំណែកមត៌កដែលកំណត់ដោយច្បាប់ ចំពោះសហសន្តតិជន នៅមុនពេលបានទទួលដំណឹង ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចតតាំងចំពោះសហសន្តតិជនដែលបានធ្វើលទ្ធកម្មសិទ្ធិលើបំណុល តាមការបែងចែកមត៌កនោះបាន ។

**មាត្រា ១២៧៦.–** ការទទួលខុសត្រូវក្នុងការធានា របស់សហសន្តតិជន

សហសន្តតិជនម្នាក់ៗ ត្រូវមានបន្ទុកទទួលខុសត្រូវក្នុងការធានា ទៅតាមសមាមាត្រនៃចំណែកមត៌កនោះ ដូចជាអ្នកលក់ដែរ ចំពោះសហសន្តតិជនដទៃទៀត ។

## ផ្នែកទី ៣

## ការសម្រួលរវាងម្ចាស់បំណុល

**មាត្រា ១២៧៧.–** ការហាមឃាត់មិនឱ្យផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិ

សន្តតិជន និង អ្នកគ្រប់គ្រងមត៌ក មិនអាចផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិលើមត៌កទៅឱ្យសន្តតិជន ឬ អច្ច័យលាភី បានឡើយ រហូតដល់ពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ បានកន្លងហួស ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ

ចំពោះករណីដែលផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិលើមត៌ក តាមភាពចាំបាច់ដើម្បីសងកាតព្វកិច្ច របស់មតកជន ។

**មាត្រា ១២៧៨.-** ម្ចាស់បំណុលរបស់មតកជន

ម្ចាស់បំណុលនៃមតកជនពុំអាចអនុវត្តសិទ្ធិរបស់ខ្លួន ចំពោះទ្រព្យសម្បត្តិផ្ទាល់របស់សន្តតិជនបានឡើយ រហូតដល់ពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ បានកន្លងហួស ។

**មាត្រា ១២៧៩.-** ម្ចាស់បំណុលរបស់សន្តតិជន

ម្ចាស់បំណុលរបស់សន្តតិជន មិនអាចអនុវត្តសិទ្ធិរបស់ខ្លួន ចំពោះមត៌កបានឡើយ រហូតដល់ពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ បានកន្លងហួស ។

## ផ្នែកទី ៤
## ការជម្រះ ជាអាទិ៍ នៅក្នុងករណីដែលមានការយល់ព្រមដោយកម្រិត

**មាត្រា ១២៨០.-** ការគ្រប់គ្រងមត៌កនៅក្រោយពេលយល់ព្រមដោយកម្រិត

អ្នកយល់ព្រមដោយកម្រិត ត្រូវបន្តការគ្រប់គ្រងមត៌ក ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

**មាត្រា ១២៨១.-** ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន

១-អ្នកយល់ព្រមដោយកម្រិត ត្រូវជូនដំណឹងជាសាធាណៈ នៅក្នុងអំឡុងពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានយល់ព្រមដោយកម្រិតហើយ ចំពោះម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភីទាំងអស់ អំពីការណ៍ដែលខ្លួនបានយល់ព្រមដោយកម្រិត និង ការណ៍ដែលម្ចាស់បំណុល និង អច្ច័យលាភីទាំងនោះ ត្រូវស្នើសុំអំពីការទាមទារនៅក្នុងអំឡុងពេលដែលកំណត់ ។ ប៉ុន្តែ អំឡុងពេលនេះ មិនត្រូវឱ្យតិចជាង ២ (ពីរ) ខែ ឡើយ ។

២-នៅក្នុងការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកយល់ព្រមដោយកម្រិត ត្រូវសរសេរបន្ថែមថា បើម្ចាស់បំណុលមិនបានស្នើសុំនៅក្នុងអំឡុងពេលកំណត់នោះទេ សិទ្ធិលើបំណុលនោះនឹងត្រូវដកចេញពីការជម្រះ ។ ប៉ុន្តែ អ្នកយល់ព្រមដោយកម្រិតនេះ មិនអាចដកម្ចាស់បំណុលដែលខ្លួនបានដឹងចេញបានឡើយ ។

៣-អ្នកយល់ព្រមដោយកម្រិត ត្រូវដាស់តឿនដោយឡែកៗ ចំពោះម្ចាស់បំណុលដែលខ្លួនបានដឹងឱ្យធ្វើការស្នើសុំ ។

**មាត្រា ១២៨២.-** សិទ្ធិបដិសេធការសងនៅក្នុងអំឡុងពេលដាស់តឿន

នៅមុនពេលផុតអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) ខាងលើនេះ អ្នកយល់ព្រមដោយកម្រិត អាចបដិសេធការសង ចំពោះម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភីបាន ។

**មាត្រា ១២៨៣.-** ការសងតាមការចែកចំណែក

ក្រោយពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) ខាងលើនេះ បានកន្លងហួស អ្នកយល់ព្រមដោយកម្រិត ត្រូវយកមត៌កនោះមកសងឱ្យម្ចាស់បំណុលដែលបានស្នើសុំនៅក្នុងអំឡុងពេលនោះ និង ម្ចាស់បំណុលផ្សេងទៀតដែលខ្លួនបានដឹង ទៅតាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនីមួយៗនោះ ។ ប៉ុន្តែ ការសងនេះ ពុំអាចបំពានសិទ្ធិរបស់ម្ចាស់បំណុលដែលមានសិទ្ធិអាទិភាពបានឡើយ ។

**មាត្រា ១២៨៤.-** ការសងកាតព្វកិច្ច ជាអាទិ៍ នៅមុនពេលកំណត់

១-ទោះបីជាសិទ្ធិលើបំណុលមិនទាន់ដល់ពេលកំណត់សងក៏ដោយ អ្នកយល់ព្រមដោយកម្រិត ត្រូវសងដោយយោងតាមបញ្ញត្តិនៃមាត្រា ១២៨៣ (ការសងតាមការចែក

ចំណែក) ខាងលើនេះ ។

២-ចំពោះសិទ្ធិលើបំណុលដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ ឬ សិទ្ធិលើបំណុលដែលអំឡុងពេលបន្តអត្ថិភាពមិនពិតប្រាកដ អ្នកយល់ព្រមដោយកម្រិតត្រូវសងសិទ្ធិលើបំណុលនោះ ដោយយោងតាមការវាយតម្លៃរបស់អ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការ ។

**មាត្រា ១២៨៥.-** ការសងចំពោះអច្ច័យលាភី

អ្នកយល់ព្រមដោយកម្រិត មិនអាចសងទៅឱ្យអច្ច័យលាភីបានឡើយ បើមិនទាន់បានសងចំពោះម្ចាស់បំណុលនីមួយៗ តាមបញ្ញត្តិនៃមាត្រា ១២៨៣ (ការសងតាមការចែកចំណែក) និង មាត្រា ១២៨៤ (ការសងកាតព្វកិច្ច ជាអាទិ៍ នៅមុនពេលកំណត់) ខាងលើនេះ ។

**មាត្រា ១២៨៦.-** ការប្តូរមត៌កជាប្រាក់

១-ប្រសិនបើចាំបាច់ត្រូវលក់មត៌កដើម្បីសង ដោយយោងតាមបញ្ញត្តិចាប់ពីមាត្រា ១២៨៣ (ការសងតាមការចែកចំណែក) រហូតដល់មាត្រា ១២៨៥ (ការសងចំពោះអច្ច័យលាភី) ខាងលើនេះ អ្នកយល់ព្រមដោយកម្រិត ត្រូវលក់មត៌កនោះ តាមវិធីលក់ដោយបង្ខំ ឬ លក់ក្នុងតម្លៃខ្ពស់ជាងការវាយតម្លៃរបស់អ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការ ។

២-អ្នកយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជន ឬ អច្ច័យលាភី អាចក្លាយជាអ្នកទិញដោយផ្ទាល់ខ្លួន នៅក្នុងការលក់ដោយបង្ខំ ឬ ការលក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

**មាត្រា ១២៨៧.-** ការទទួលខុសត្រូវក្នុងការសងមិនត្រឹមត្រូវ

១-ប្រសិនបើអ្នកយល់ព្រមដោយកម្រិតមានការធ្វេសប្រហែស ក្នុងការជូនដំណឹងជាសាធារណៈ ឬ ការដាស់តឿនដែលបានកំណត់នៅក្នុងមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) នៃក្រមនេះ ឬ បើពុំអាចសងទៅឱ្យម្ចាស់បំណុល ឬ អច្ច័យលាភីដទៃទៀត ដោយសារបានសងទៅឱ្យម្ចាស់បំណុល ឬ អច្ច័យលាភីណាផ្សេង

នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈដែលបានកំណត់ នៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះទេ អ្នកយល់ព្រមដោយកម្រិតនោះ ត្រូវសង សំណងការខូចខាតដែលកើតឡើងដោយសារហេតុនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងការទាមទារសំណងការខូចខាត របស់ម្ចាស់បំណុល ឬ អច្ច័យលាភីដទៃ ចំពោះម្ចាស់បំណុល ឬ អច្ច័យលាភីដែលបាន ទទួលការសង ដោយដឹងអំពីភាពមិនត្រឹមត្រូវនៃការសងនោះ ។

**មាត្រា ១២៨៨.–** ករណីដែលពុំបានស្នើសុំ

ម្ចាស់បំណុល និង អច្ច័យលាភី ដែលពុំបានស្នើសុំនៅក្នុងអំឡុងពេលដែលបាន កំណត់នៅក្នុងការជូនដំណឹងជាសាធារណៈ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃ មាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) នៃក្រមនេះ ហើយដែល អ្នកយល់ព្រមដោយកម្រិតពុំអាចដឹងបាន អាចអនុវត្តសិទ្ធិរបស់ខ្លួនបាន ត្រឹមតែចំពោះ ទ្រព្យសម្បត្តិដែលនៅសេសសល់ប៉ុណ្ណោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះជនដែលមានសិទ្ធិប្រាតិភោគលើវត្ថុ ឬ សិទ្ធិដែលបានកំណត់ជាក់លាក់ក្នុងចំណោម មត៌ក ។

**មាត្រា ១២៨៩.–** ករណីដែលមានសន្តតិជនច្រើននាក់

១-នៅក្នុងករណីដែលមានសន្តតិជនច្រើននាក់ បើមានការយល់ព្រមដោយកម្រិត តុលាការត្រូវជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក ពីក្នុងចំណោមសន្តតិជនទាំងនោះ ។

២-អ្នកគ្រប់គ្រង ត្រូវបំពេញរាល់សកម្មភាពចាំបាច់ក្នុងការគ្រប់គ្រងមត៌ក និង សង កាតព្វកិច្ច ដើម្បីខ្លួនឯងផ្ទាល់ និង ជំនួសសហសន្តតិជនដទៃទៀត ។

៣-បញ្ញត្តិចាប់ពីមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) រហូតដល់មាត្រា ១២៨៨ (ករណីដែលពុំបានស្នើសុំ) ខាងលើនេះ ត្រូវយកមកអនុវត្តដូច គ្នាផងដែរ ចំពោះអ្នកគ្រប់គ្រង ។ ប៉ុន្តែ អំឡុងពេលដែលត្រូវជូនដំណឹងជាសាធារណៈ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) នៃក្រមនេះ មានចំនួន ១០ (ដប់) ថ្ងៃ បន្ទាប់ពីបានជ្រើសតាំងអ្នក

គ្រប់គ្រង ។

## ជំពូកទី ៧
## នត្ថិភាពនៃសន្តតិជន

**មាត្រា ១២៩០.-** នីតិបុគ្គលមត៌ក

ប្រសិនបើពុំច្បាស់ថាមានសន្តតិជនទេ មត៌កនោះត្រូវក្លាយជានីតិបុគ្គល ។

**មាត្រា ១២៩១.-** ការជ្រើសតាំងអ្នកគ្រប់គ្រង

១-ក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ១២៩០ (នីតិបុគ្គលមត៌ក) ខាងលើនេះ តុលាការត្រូវជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក តាមពាក្យសុំរបស់បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋាន ចុងក្រោយរបស់មតកជន ឬ តំណាងអយ្យការ ។

២-បើបានជ្រើសតាំងអ្នកគ្រប់គ្រងមត៌កហើយ តុលាការត្រូវធ្វើការជូនដំណឹងជាសាធារណៈអំពីការណ៍នោះ ដោយគ្មានការយឺតយ៉ាវ ។

**មាត្រា ១២៩២.-** សិទ្ធិ និង កាតព្វកិច្ចរបស់អ្នកគ្រប់គ្រង

១-អ្នកគ្រប់គ្រង ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌដែលទាក់ទងទៅនឹងមត៌ក ដោយគ្មានការយឺតយ៉ាវ ។

២-អ្នកគ្រប់គ្រង ត្រូវថែរក្សា និង គ្រប់គ្រងមត៌ក ។ បើមានការចាំបាច់ដើម្បីថែរក្សា និង គ្រប់គ្រងមត៌កនោះ អ្នកគ្រប់គ្រងអាចប្តូរមត៌កជាប្រាក់ ឬ អាចចាត់ចែងមត៌កនោះបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

៣-បើមានការទាមទារពីម្ចាស់បំណុលរបស់មតកជន ឬ អច្ច័យលាភី អ្នកគ្រប់គ្រងត្រូវរាយការណ៍អំពីស្ថានភាពនៃមត៌កទៅឱ្យជននោះ ។

៤-អ្នកគ្រប់គ្រងត្រូវអនុវត្តតាមចំណុចនីមួយៗ ដែលបានកំណត់ក្នុងបញ្ញត្តិចាប់ពីមាត្រា ១២៨២ (សិទ្ធិបដិសេធការសងនៅក្នុងអំឡុងពេលដាស់តឿន) រហូតដល់មាត្រា

១២៨៨ (ករណីដែលពុំបានស្នើសុំ) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៩៦ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុល ជាអាទិ៍) ខាងក្រោមនេះ ។

៥-តាមការបង្គាប់របស់តុលាការ អ្នកគ្រប់គ្រង ត្រូវស្រាវជ្រាវអង្គហេតុ ហើយត្រូវធ្វើសេចក្ដីរាយការណ៍អំពីលទ្ធផលនោះទៅតុលាការ ។

**មាត្រា ១២៩៣.-** កម្រៃសម្រាប់ អ្នកគ្រប់គ្រង

តុលាការអាចផ្ដល់កម្រៃសមរម្យ ចេញពីក្នុងចំណោមមត៌ក ឱ្យទៅអ្នកគ្រប់គ្រងបាន ដោយគិតពិចារណាទៅលើស្ថានភាពនៃមត៌ក និង ស្ថានភាពផ្សេងទៀត ។

**មាត្រា ១២៩៤.-** ករណីដែលដឹងច្បាស់អំពីសន្តតិជន

ប្រសិនបើដឹងច្បាស់ថាមានសន្តតិជន នីតិបុគ្គលមត៌កត្រូវចាត់ទុកថាពុំមានអត្ថិភាពតាំងពីដំបូង ។ ប៉ុន្តែ បញ្ញត្តិនេះពុំរារាំងអានុភាពនៃសកម្មភាពដែលអ្នកគ្រប់គ្រងបានធ្វើហើយ នៅក្នុងទំហំនៃសិទ្ធិអំណាចរបស់ខ្លួនឡើយ ។

**មាត្រា ១២៩៥.-** ពេលរលត់សិទ្ធិអំណាចរបស់អ្នកគ្រប់គ្រង

១-សិទ្ធិអំណាចរបស់អ្នកគ្រប់គ្រង ត្រូវរលត់ នៅពេលដែលសន្តតិជនបានយល់ព្រមទទួលសន្តតិកម្ម ។

២-បើសន្តតិជនបានយល់ព្រមទទួលសន្តតិកម្មហើយ អ្នកគ្រប់គ្រងត្រូវគណនាអំពីការគ្រប់គ្រងនោះ ចំពោះសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

**មាត្រា ១២៩៦.-** ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុលជាអាទិ៍

១-បើពុំបានដឹងច្បាស់អំពីអត្ថិភាពនៃសន្តតិជន នៅក្នុងអំឡុងពេល ២ (ពីរ) ខែ បន្ទាប់ពីបានធ្វើការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ១២៩១ (ការជ្រើសតាំងអ្នកគ្រប់គ្រង) នៃក្រមនេះទេ អ្នកគ្រប់គ្រង ត្រូវជូនដំណឹងជាសាធារណៈ ដោយគ្មានការយឺតយ៉ាវ ចំពោះម្ចាស់បំណុលរបស់មតកជន និង អច្ច័យ-

លាភីទាំងអស់ អំពីការណ៍ដែលម្ចាស់បំណុល និង អច្ច័យលាភីទាំងនោះ ត្រូវស្នើសុំអំពីការទាមទារក្នុងអំឡុងពេលដែលកំណត់ ។ ប៉ុន្តែ អំឡុងពេលនេះ មិនត្រូវឱ្យតិចជាង ២ (ពីរ) ខែ ឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) និង បញ្ញត្តិចាប់ពីមាត្រា ១២៨២ (សិទ្ធិបដិសេធការសងនៅក្នុងអំឡុងពេលដាស់តឿន) រហូតដល់មាត្រា ១២៨៨ (ករណីដែលពុំបានស្នើសុំ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។ ប៉ុន្តែ អ្នកគ្រប់គ្រង ពុំអាចក្លាយជាអ្នកទិញនៅក្នុងការលក់ដោយបង្ខំ ឬ ការលក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨៦ (ការប្តូរមត៌កជាប្រាក់) នៃក្រមនេះ ដែលត្រូវបានយកមកអនុវត្តដូចគ្នា បានឡើយ ។

**មាត្រា ១២៩៧.–** ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន

១-ក្រោយពីអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៩៦ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុល ជាអាទិ៍) ខាងលើនេះ បានកន្លងហួស ប្រសិនបើនៅតែមិនទាន់ដឹងច្បាស់ថាមានសន្តតិជននៅឡើយ តាមពាក្យសុំរបស់អ្នកគ្រប់គ្រង ឬ តំណាងអយ្យការ តុលាការត្រូវធ្វើការជូនដំណឹងជាសាធារណៈថា ប្រសិនបើមានសន្តតិជន សន្តតិជននោះត្រូវធ្វើការស្នើសុំអំពីការណ៍នោះ នៅក្នុងអំឡុងពេលដែលកំណត់ ។ ប៉ុន្តែ អំឡុងពេលនេះ មិនត្រូវឱ្យតិចជាង ៦ (ប្រាំមួយ) ខែ ឡើយ ។

២-បើប៉ាន់ប្រមាណឃើញថាគ្មានសេសសល់មត៌កទេ អ្នកគ្រប់គ្រង ឬ តំណាងអយ្យការ មិនអាចធ្វើការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះឡើយ ។

**មាត្រា ១២៩៨.–** ការដកហូតសិទ្ធិតាមការជូនដំណឹងជាសាធារណៈ

បើគ្មានការស្នើសុំថា ខ្លួនជាសន្តតិជន នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងបញ្ញត្តិនៃមាត្រា ១២៩៧ (ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន) ខាងលើនេះទេ សន្តតិជន ព្រមទាំងម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភី ដែលអ្នកគ្រប់គ្រងមិន

អាចដឹងបាន ពុំអាចអនុវត្តសិទ្ធិបានឡើយ ។

**មាត្រា ១២៩៩.–** ការចែកមត៌កឱ្យទៅជនដែលមាននិស្ស័យពិសេស

១-នៅក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ១២៩៨ (ការដកហូតសិទ្ធិតាមការជូនដំណឹងជាសាធារណៈ) ខាងលើនេះ បើយល់ឃើញថាសមរម្យ តុលាការអាចចែកមួយផ្នែកនៃមត៌កដែលនៅសេសសល់ក្រោយការជម្រះ ទៅឱ្យជនដែលមានជីវភាពជាមួយគ្នានឹងមតកជន ជនដែលបានខិតខំមើលថែទាំព្យាបាលមតកជន និង ជនដែលមាននិស្ស័យពិសេសផ្សេងទៀត តាមពាក្យសុំរបស់ជននោះ ។ ប៉ុន្តែ ចំនួនសរុបនៃតម្លៃទ្រព្យដែលត្រូវចែកទៅឱ្យនោះ មិនត្រូវលើសពីចំនួនពាក់កណ្តាលនៃមត៌កដែលនៅសេសសល់នោះទេ ។

២-ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើនៅក្នុងអំឡុងពេល ៣ (បី) ខែ ក្រោយពីអំឡុងពេលដែលបានកំណត់នៅក្នុងមាត្រា ១២៩៧ (ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន) ខាងលើនេះ បានកន្លងហួស ដោយបញ្ជាក់អំពីហេតុនៃនិស្ស័យពិសេសនោះឱ្យបានច្បាស់លាស់ ។

៣-ក្នុងការចែកទ្រព្យដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចស្រាវជ្រាវអំពីអង្គហេតុបាន ។ បើនៅក្នុងការស្រាវជ្រាវនេះ តុលាការអាចសួរយោបល់របស់មេឃុំ ឬ ចៅសង្កាត់បាន ។

**មាត្រា ១៣០០.–** មត៌កដែលធ្លាក់ទៅជាទ្រព្យរដ្ឋ

មត៌កដែលមិនត្រូវបានចាត់ចែង តាមបញ្ញត្តិនៃមាត្រា ១២៩៩ (ការចែកមត៌កឱ្យទៅជនដែលមាននិស្ស័យពិសេស) ខាងលើនេះ ត្រូវធ្លាក់ទៅជាទ្រព្យរដ្ឋ ។ ក្នុងករណីនេះ អ្នកគ្រប់គ្រងត្រូវគណនាអំពីការគ្រប់គ្រងនោះ ហើយដាក់ជូនទៅតុលាការ ដោយគ្មានការយឺតយ៉ាវ ។

# ជំពូកទី ៨
# ការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម

**មាត្រា ១៣០១.–** គោលបំណងនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម

សន្តតិជនដែលត្រូវបានដកហូតសិទ្ធិសន្តតិកម្ម អាចទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ដើម្បីទទួលបដិទាននៃមត៌កទាំងអស់ ឬ មួយភាគ បាន ។

**មាត្រា ១៣០២.–** អត្ថន័យនៃការទាមទារឱ្យធ្វើបដិទាននូវសន្តតិកម្ម

១-សន្តតិជនអាចទាមទារចំពោះជនដែលបានទទួលមត៌ក តាមសិទ្ធិសន្តតិកម្មដែលពុំត្រូវបានទៅជននោះ ឱ្យប្រគល់មកវិញ នូវទ្រព្យដែលបានទទួលនោះ ។

២-ទ្រព្យដែលភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម បានទទួល តាមកិច្ចសន្យាដែលយកមត៌កធ្វើជាកម្មវត្ថុ ក៏ត្រូវក្លាយជាកម្មវត្ថុនៃការទាមទារឱ្យធ្វើបដិទាននូវសន្តតិកម្មផងដែរ ។

**មាត្រា ១៣០៣.–** ខ្លឹមសារនៃករណីយកិច្ចប្រគល់វិញ

១-ភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ត្រូវប្រគល់មត៌កមកឱ្យសន្តតិជនដែលបានទាមទារវិញ ។ បើភាគីម្ខាងទៀតសុចរិត ជននោះមានសិទ្ធិរក្សាទុកនូវផល និង ការប្រាក់ដែលបានទទួល សិទ្ធិទាមទារឱ្យសងវិញនូវសោហ៊ុយដែលបានបង្កើនតម្លៃចំពោះទ្រព្យនោះ ហើយមានសិទ្ធិទាមទារសំណងចំពោះកាតព្វកិច្ចដែលត្រូវបានទទួលតាមរយៈសន្តតិកម្ម ដែលបានសងរួចហើយនោះ ។

២-បើភាគីម្ខាងទៀតទុច្ចរិត ជននោះមានកាតព្វកិច្ចត្រូវប្រគល់វិញនូវផល និង ការប្រាក់ដែលបានទទួល ហើយមិនត្រឹមតែគ្មានសិទ្ធិទាមទារសំណងចំពោះកាតព្វកិច្ចដែលត្រូវបានទទួលតាមរយៈសន្តតិកម្មដែលបានសងនោះទេ ថែមទាំងគ្មានសិទ្ធិទាមទារឱ្យសងវិញនូវសោហ៊ុយដែលបានបង្កើនតម្លៃចំពោះទ្រព្យនោះផង ។

**មាត្រា ១៣០៤.–** អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យធ្វើបដិទានសន្តតិកម្ម

អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យធ្វើបដិទានសន្តតិកម្ម នៅក្នុងករណីដែលមត៌កត្រូវបានផ្ទេរទៅភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម តាមមតកសាសន៍ ឬ ការបែងចែកមត៌ក មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលនោះ រីឯក្នុងករណីដែលជនតែម្នាក់បានទទួលសន្តតិកម្មក្នុងនាមជាសន្តតិជន មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីថ្ងៃដែលមតកជនបានទទួលមរណភាព ។